ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- គម្រោងចំនួនបីដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម...
- សិទ្ធិរបស់ជនជាប់ចោទ

លេខ ៦៧ ខែកក្កដា ឆ្នាំ២០០៥

# ស្វែងរកការពិត

លេខ៦៧ ខែកក្កដា ឆ្នាំ២០០៥

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រៈ គម្រោងចំនួនបីដើម្បីជួយឲ្យអ្នករស់រានមានជីវិត............១

**ផ្នែកឯកសារ**

◆ ឡាំ រីរី អតីតនិស្សិតវិស្វករអគ្គិសនីនៅសហភាពសូវៀត...........៤

◆ បញ្ជីឈ្មោះជនរងគ្រោះមន្ទីរស-២១.................................. ៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អតីតអ្នកទោសគុកសង់បានធូរស្រាលពីជំងឺផ្លូវចិត្ត............. ៨

◆ គ្រួសារ វ៉ាន់ ង៉ាង...................................................១០

◆ រូបជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ................................ ១៥

**ផ្នែកច្បាប់**

◆ សិទ្ធិរបស់ជនជាប់ចោទ................................................

**វេទិកាពិភាក្សាសាធារណៈ**

◆ ទំនៀមទម្លាប់បូជាសពតាមគន្លងព្រះពុទ្ធសាសនា................... ៣១

◆ វ៉ាន់ដាៈ តើមានសង្ឃឹមសម្រាប់ប្រទេសនេះដែរឬទេ? ...........៣៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ កុមារភាពរបស់ខ្ញុំ.................................................... ៤៩

◆ ជីវិតក្នុងភាពនឹងថ្កល់.............................................៥៧





មាន លី ថតប្រហែលក្នុងឆ្នាំ១៩៧៥

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** យិន នាន, សឹម សុរិយា, វេនទី ខូវហ្គៀល, អាដុង លី, ញាណ សុជាតិ, ញ៉ែម បុនថា **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **អ្នកបកប្រែៈ** ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# គម្រោងចំនួនបីដើម្បីជួយឱ្យអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបានទទួលយុត្តិធម៌ និងដើម្បីជួយឱ្យសាធារណជនចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ

*ប្រជាជនកម្ពុជាប្រមាណពីរលាននាក់បានបាត់បង់ជីវិតនៅក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ បើគិតជាភាគរយ ការបាត់បង់ជីវិតប្រជាជនប្រមាណ២៥ភាគរយនៃចំនួនប្រជាជនសរុបនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យគឺជាការបាត់បង់ជីវិតដែលច្រើនបំផុតដោយសារអំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់មនុស្សជាតិ ។ បន្ទាប់ពីរបបនេះដួលរលំនៅក្នុងខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមនៅតែបន្តកាន់កាប់តំបន់ដាច់ស្រយាលមួយចំនួន ហើយនៅតែបន្តវាយឆ្មក់និងបំភិតបំភ័យសង្គមកម្ពុជារហូតដល់ឆ្នាំ១៩៩៩ ។*

*បើទោះបីជាក្នុងរយៈពេលប្រមាណ៦ឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាមានសភាពស្ងប់ស្ងាត់ជាងមុនក្តី ក៏កម្ពុជានៅតែស្ថិតនៅក្នុងចំណោមប្រទេសដែលក្រីក្របំផុតនៅអាស៊ី ។ ប្រជាជនប្រមាណជាង៤០ភាគរយរកប្រាក់ចំណូលបានតែ១ដុល្លារក្នុងមួយថ្ងៃឬតិចជាងនេះ ។ កំណើនប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័សរហូតដល់១២លាននាក់នាពេលបច្ចុប្បន្ន ហើយប្រទេសកម្ពុជាកំពុងតែប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំងក្នុងការបង្កើតមូលដ្ឋានគ្រប់គ្រងបែបប្រជាធិបតេយ្យនិងអភិវឌ្ឍសេដ្ឋកិច្ច ។ ស្ថាប័នទាំងអស់ដែលអាចជួយប្រទេសឲ្យធូរស្បើយពីព្រឹត្តិការណ៍ដែលប៉ះពាល់ផ្នែកស្មារតីបានចុះខ្សោយឬអវត្តមានតែម្តង ដោយសារតែការបំផ្លិចបំផ្លាញរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ កង្វះខាតធនធានមនុស្សកំពុងតែបន្តប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាជនកម្ពុជាសព្វថ្ងៃនេះទៀត ។*

*ប្រឈមមុខទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្របែបនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងចំនួនបីគឺ "គម្រោងជួយដល់ជនរងគ្រោះដោយអំពើទារុណកម្ម" "គម្រោងឯកសាររស់" និង "ការិយាល័យពត៌មានសាធារណៈ" ។ គម្រោងទាំងបីនេះនឹងជួយប្រជាជនកម្ពុជាឲ្យយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ចូលរួមយ៉ាងសកម្មនៅក្នុងប្រព័ន្ធយុត្តិធម៌ និងចាប់ផ្តើមផ្សះផ្សានៅក្នុងចិត្តរបស់ខ្លួនឯងចំពោះអតីតកាលរបស់ខ្លួននិងចំពោះអ្នកដទៃ ។*

*នៅក្នុងខែមីនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយប្រទេសកម្ពុជាដើម្បីបង្កើតតុលាការពិសេសមួយដើម្បីជំនុំជម្រះសេចក្តីមេដឹកនាំខ្មែរក្រហមដែលជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបកម្ពុជាប្រជាធិបតេយ្យ (ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩) ។ នៅក្នុងខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានផ្តល់សច្ចាប័នលើ"កិច្ចព្រមព្រៀងស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" និងវិសោធនកម្មច្បាប់ស្តីអំពី"ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដើម្បីឆ្ពោះទៅរកការជំនុំជម្រះសេចក្តីមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែមានការឧបត្ថម្ភថវិកាគ្រប់គ្រាន់ពីសហគមន៍*

*អន្តរជាតិ ឥឡូវនេះក្តីសង្ឃឹមដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញជិតក្លាយជាការពិតហើយ ។*

## គម្រោងទាំងបី

### គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្មៈ ជួយជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ

*កេរដំណែលមួយរបស់របបកម្ពុជាប្រជាធិបតេយ្យគឺទុក្ខលំបាកវេទនាដែលរបបនេះបានបន្សល់ទុកឲ្យអ្នកដែលរស់រានមានជីវិត ។ ភាគច្រើននៃអ្នករស់រានជីវិតទាំងនេះមានបញ្ហាផ្នែកស្មារតី ដោយសារគាត់ធ្លាប់បានឆ្លងកាត់យុគសម័យមួយដែលព្យាយាមកែប្រែសង្គមដោយប្រើប្រាស់ចលនាបដិវត្តន៍ជិះជាន់ប្រជាជនយ៉ាងព្រៃផ្សៃបំផុតក្នុងការបំផ្លាញអត្តសញ្ញាណរបស់បុគ្គលនិងក្រុមផ្សេងៗរបស់សង្គម ។ អ្នកសិក្សាស្រាវជ្រាវបានប៉ាន់ប្រមាណថាប្រជាជនកម្ពុជា២នាក់ក្នុងចំណោម៥នាក់មានជំងឺប៉ះពាល់ស្មារតីធ្ងន់ធ្ងរ ។ នៅក្នុងប្រទេសកម្ពុជា ការព្យាបាលជនរងគ្រោះដោយជំងឺប្រភេទនេះនៅមានកម្រិតទាបនៅឡើយ ដោយសារបច្ចុប្បន្ននេះប្រទេសកម្ពុជាមានអ្នកជំនាញចិត្តសាស្ត្រតែ២០នាក់ប៉ុណ្ណោះ ។ ចំណុចមួយទៀតគឺទាក់ទងនឹងជនរងគ្រោះ ។ ប្រវត្តិសាស្ត្ររបស់របបនេះមិនទាន់ត្រូវបានបិទនៅឡើយ ដោយសារតែមេដឹកនាំរបស់របបនេះមិនទាន់ត្រូវបានជំនុំជម្រះសេចក្តីពីបទឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្តបើគិតមកទល់នឹងពេលនេះគឺជាង២៥ឆ្នាំទៅហើយបន្ទាប់ពីរបបនេះដួលរលំ ។*

*ឱកាសដើម្បីនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាន់តុលាការតម្រូវឲ្យមានការពិចារណាដិតដល់អំពីផលប៉ះពាល់ដល់ជនរងគ្រោះដែលនឹងត្រូវប្រឈមមុខចំពោះរឿងរ៉ាវឈឺចាប់របស់ខ្លួន ។ អង្គជំនុំជម្រះវិសាមញ្ញនេះអាចរំឭកការចងចាំដ៏ឈឺចាប់របស់អ្នកដែលមានការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ វាចាំបាច់ក្នុងការបង្កើតយន្តការការពារឲ្យបានសមរម្យសម្រាប់អ្នកដែលប្រហែលជានឹងមានការប៉ះពាល់ដោយការរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួនឡើងវិញ ។*

*ដោយទទួលស្គាល់អំពីភាពចាំបាច់ទាំងនេះ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិកំពុងតែឧបត្ថម្ភមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការចិត្តសង្គមអន្តរវប្បធម៌លើកម្មវិធីមួយដែលចងក្រងអំពើបំពារបំពានពីអតីតកាលនៅតាមតំបន់ខ្លះ ដោយបង្កបរិយាកាសឲ្យជនរងគ្រោះដោយអំពើទារុណកម្មអាចចេញមុខដោះស្រាយនូវតម្រូវការផ្នែកស្មារតីរបស់ខ្លួនឯង របស់ក្រុមគ្រួសារ និងរបស់សហគមន៍តាមរយៈការប្រឹក្សាយោបល់ ។ គម្រោងនេះក៏បានស្ទុះស្វែងសិក្សាអំពីការយល់ឃើញរបស់ជនរងគ្រោះ អំពីការចងចាំនិងយុត្តិធម៌ និងដើម្បីលើកកម្ពស់ការផ្សះផ្សាសហគមន៍នៅក្នុងប្រទេសកម្ពុជា ។*

### គម្រោងឯកសាររស់ៈ បង្កើតមធ្យោបាយដើម្បីសម្រួលការចូលរួមរបស់សាធារណជននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ

*បើទោះបីជាសារព័ត៌មាន ទូរទស្សន៍ វិទ្យុ អ៊ីនធឺណែត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ងាយស្រួលរកនៅក្នុងទីក្រុងភ្នំពេញនិងទីប្រជុំជនផ្សេងៗទៀតរបស់ប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែមានប្រជាជនកម្ពុជាតិចតួចប៉ុណ្ណោះក្នុងចំណោមប្រជាជនទូទាំងមួយពាន់ប្រាំពីររយឃុំ (ជាពិសេសអ្នកដែលនៅតាមជនបទ) មានមធ្យោបាយទទួលបានព័ត៌មានស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ នេះជាការពិតចំពោះអ្នកដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែលភាគច្រើនជាមនុស្សក្រីក្រនិងមិនចេះអក្សរ ។*

*ការទទួលបាននូវយុត្តិធម៌ប្រហែលជាអ្វីដែលមានសារសំខាន់បំផុតនៅក្នុងដំណើរការព្យាបាលរបួសផ្លូវចិត្តរបស់អ្នកដែលរស់រានមានជីវិត ។ ជីវិតរបស់ប្រជាជនជិតពីរលាននាក់ដែលបានបាត់បង់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យមិនអាចត្រឡប់មកវិញទេ ហើយឱកាសសប្បាយរីករាយនៅក្នុងសង្គមរុងរឿងមួយប្រសិនបើគ្មានរបបខ្មែរក្រហមនោះក៏មិនអាចត្រឡប់មកវិញដែរ ។ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញនឹងផ្តល់ឱកាសដល់អ្នករួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យឲ្យដឹងថា ពិភពលោកបានទទួលស្គាល់ការឈឺចាប់របស់កម្ពុជា និងឲ្យដឹងថាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្ត ។*

ឱកាសសម្រាប់ប្រជាជនកម្ពុជាចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នេះមិនត្រូវបានធានាទាល់តែសោះ ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា ខ្លួនគ្មានគម្រោងផ្លូវការឬក្រៅផ្លូវការដើម្បីផ្តល់ព័ត៌មានដល់សាធារណជនអំពីដំណើរការនៃការជំនុំជម្រះក្តីមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យទេក្រៅពីតាមរយៈបណ្តាញសារព័ត៌មានដែលមានស្រាប់ ហើយអង្គការសហប្រជាជាតិក៏ប្រហែលជាគ្មានគោលនយោបាយឬហិរញ្ញវត្ថុដើម្បីធានាតួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះដែរ ។ ដូច្នេះហើយបានជាមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតគម្រោងមួយដើម្បីធានាការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

នៅក្នុងឆ្នាំទីមួយនៃ**គម្រោងឯកសាររស់**របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រជាពលរដ្ឋប្រមាណ២០០នាក់ (ក្នុងមួយក្រុមៗមានសមាជិកប្រមាណ៣០នាក់) មកពីតាមឃុំនឹងធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីចូលរួមនៅក្នុងសវនាការរយៈពេលមួយសប្តាហ៍ ។ ដំណើរការនេះនឹងធ្វើឡើងនៅរៀងរាល់៥សវនាការ ហើយគម្រោងនេះនឹងអនុញ្ញាតឲ្យប្រជាជនប្រមាណមួយពាន់ពីររយនាក់បានចូលរួមនៅក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរយៈពេល៣ឆ្នាំនេះ ។

គម្រោងនេះក៏នឹងជួយកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាតាមរយៈការផ្តល់ឱកាសឲ្យអ្នកចូលរួមបានធ្វើជាសាក្សីនិងចៅក្រមនៅក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ការចូលរួមនេះក៏នឹងផ្តល់ឱកាសដល់អ្នកចូលរួមទាំងនោះក្នុងការពិភាក្សាស្វែងយល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានព័ត៌មាន ព្រមទាំងបង្កើតជាចលនាដ៏មានប្រជាប្រិយភាពមួយទាមទារសេរីភាពឲ្យទូលាយជាងមុនក្នុងការទទួលព័ត៌មាន ។ ការចូលរួមនេះក៏នឹងផ្តល់ដល់អ្នកតំណាងឃុំនីមួយៗនូវឱកាសដើម្បីបង្ហាញខ្លួននៅចំពោះមុខក្រសែភ្នែកសាធារណជន (ក្នុងការនិយាយដឹកនាំការពិភាក្សា និងលើកជាសំណួរ) ហើយសកម្មភាពនេះនឹងជួយកសាងសមត្ថភាពរបស់មេដឹកនាំសម្រាប់ការបោះឆ្នោតភូមិ-ឃុំនៅពេលអនាគត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅពង្រីកផលប្រយោជន៍នេះតាមរយៈការផ្តល់ការកែលម្អឃុំនិងការហ្វឹកហ្វឺនភាពជាអ្នកដឹកនាំដល់មេដឹកនាំភូមិឃុំនៅពេលអនាគតថែមទៀត ។

**ការិយាល័យព័ត៌មានសាធារណៈ បង្កើនការទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ**

មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលចងក្រងឯកសារចំនួនជាង៦សែនទំព័រដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិប-តេយ្យ ។ ឯកសារទាំងនេះរួមមាន ញត្តិនិងបទសម្ភាសដែលធ្វើជាមួយជនរងគ្រោះ និងសម្ភារផ្សេងៗជាច្រើនទៀតដែលអាចធ្វើជាវត្ថុតាងដ៏មានសារសំខាន់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ បើទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាកន្លែងតែមួយគត់ដែលថែរក្សាឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ជាកន្លែងធំបង្អស់ដែលមានថែរក្សាឯកសារប្រភេទនេះ ។

ដើម្បីបំពេញនូវតម្រូវការផ្នែកឯកសារដែលត្រូវប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងការកើនឡើងនូវការប្រើប្រាស់បណ្ណសាររបស់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកការិយាល័យព័ត៌មានសាធារណៈ (PIR) កាលពីចុងខែមេសា ឆ្នាំ២០០៤ ។ បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបើកជូនបុគ្គលិកផ្នែកច្បាប់ (ទាំងខាងមេធាវីចុងចោទ ទាំងខាងព្រះរាជអាជ្ញា) អ្នកស្រាវជ្រាវ អ្នកសារព័ត៌មាននិងសាធារណជនទូទៅ ។

រហូតមកដល់បច្ចុប្បន្ននេះ ការិយាល័យព័ត៌មានសាធារណៈទទួលភ្ញៀវបានចំនួនជាង១៩០០នាក់ ទទួលអ្នកខ្ទេសនាមនិងវាគ្មិនជាង៣០នាក់ឲ្យមកផ្តល់បាឋកថាជុំវិញបញ្ហាអង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងបានបញ្ចាំងខ្សែភាពយន្តឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួនទៀត ។ ថ្មីៗនេះចំនួនភ្ញៀវមកកាន់ការិយាល័យព័ត៌មានសាធារណៈដើម្បីស្នើសុំព័ត៌មានដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យបានកើនឡើងពីចំនួន១ឬ២នាក់ក្នុងមួយខែទៅដល់ជាង៤០នាក់ក្នុងមួយខែ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ឡាំ វីរី អតីតនិស្សិតវិស្វករអគ្គិសនីនៅសហភាពសូវៀត

ឡាំ វីរី ជាអតីតវិស្វករវារីអគ្គិសនីមកពីប្រទេសរុស្ស៊ីដែលបានវិលត្រឡប់មកស្រុកកម្ពុជាវិញនៅឆ្នាំ១៩៧៦ ។ វីរី ជានិស្សិតម្នាក់ក្នុងចំណោមនិស្សិតខ្មែរបញ្ចប់ការសិក្សាពីបរទេសជាច្រើននាក់ដែលចង់ឲ្យអង្គការកសាងសង្គមតាមបែបបច្ចេកទេសទំនើបដោយប្រើប្រាស់ធនធានមនុស្សទៅតាមជំនាញ ។ ដោយសារមូលហេតុនេះ ឡាំ វីរី ត្រូវអង្គការចោទថាក្បត់បដិវត្តន៍ ហើយត្រូវចាប់ខ្លួននៅថ្ងៃ១២ ខែ១០ ឆ្នាំ១៩៧៦ បញ្ជូនមកមន្ទីរឃុំឃាំងស-២១ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែ៣ ឆ្នាំ១៩៧៧ ។

វីរី បានទទួលអាហារូបករណ៍ពីក្រសួងអប់រំជាតិកម្ពុជាទៅសិក្សាផ្នែកវិស្វករនៅទីក្រុងមូស្គូប្រទេសរុស្ស៊ីនៅចុងឆ្នាំ១៩៦៥ ។ នៅទីក្រុងមូស្គូ ហាក់ សៀងឡាយនី, គ្រិន លាន, វឿង ម៉ាច បានមកទាក់ទងជាមួយ វីរី និងបញ្ចុះបញ្ចូលឲ្យគាត់ចូលជាសមាជិកខេមរនិស្សិត ប៉ុន្តែ វីរី ពុំទាន់ឆ្លើយយល់ព្រមនៅឡើយទេ ។

ក្រៅពីអ្នកទាំងបីខាងលើ វីរី បានស្គាល់ ម៉ិល សុវណ្ណ ដែលជានិស្សិតអាហារូបករណ៍រៀននៅប្រទេសរុស្ស៊ីដែរ ។ សុវណ្ណ តែងតែនិយាយប្រាប់ វីរី អំពីនយោបាយនៅក្នុងប្រទេសកម្ពុជា និងលើកសរសើរសង្គមនិយមសូវៀត ។

នៅឆ្នាំ១៩៦៧ វីរី ចាប់ផ្តើមសិក្សាមុខវិជ្ជាវារីបច្ចេកទេសនៅសាលាសភាកសិកម្មរុស្ស៊ី ។

នៅឆ្នាំដដែល ទីកូឡា ស្តាវីណា អធិការនិស្សិតបរទេសផ្នែកនយោបាយនិងសង្គមកិច្ច បានស្នើឲ្យ វីរី ចូលជាសមាជិកកា.ហ្វេ.បេ ដោយសន្យាថានឹងចាត់តាំងឲ្យគាត់ធ្វើជាអ្នកឃោសនានិងស៊ើបការណ៍សម្ងាត់ឲ្យអង្គការកា.ហ្វេ.បេនៅរុស្ស៊ី ។

នៅឆ្នាំ១៩៦៩ វីរី សម្រេចចិត្តចូលជាសមាជិក កា.ហ្វេ.បេ ដោយមានការទទួលស្គាល់ពី យូទី សាវីណូវ (អ្នកទទួលខុសត្រូវលិខិតឆ្លងដែនជនបរទេសនៅវិជ្ជាស្ថានសំណង់ក្រុងមូស្គូ) ។ នៅឆ្នាំដដែល វីរី ស្ម័គ្រចិត្តចូលជាសមាជិកសមាគមនិស្សិតនិងអាណិកជនខ្មែរនៅសហភាពសូវៀត ។ នៅចុងឆ្នាំ១៩៦៩ ព្រហ្ម ភឿន, យូ សិមហ៊ិន, ហេង ពេជ្រ និង វីរី បានក្លាយជាអ្នកគ្រប់គ្រងសមាគមនិស្សិតនេះ ។

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅប្រទេសកម្ពុជានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ វីរី ប្រមែប្រមូលកម្លាំងនិស្សិតខ្មែរឲ្យគាំទ្ររណសិរ្សរួបរួមជាតិដែលមានសម្តេច សីហនុ ជាប្រធាន ។ ក្រោយមក វីរី បានចូលជាសមាជិកយុវជនរណសិរ្សរួបរួមជាតិកម្ពុជានៅប្រទេសរុស្ស៊ី ។

នៅខែ៨ ឆ្នាំ១៩៧១ តាងនាមអង្គការយុវជនរណសិរ្សរួបរួមជាតិកម្ពុជានៅសហភាពសូវៀត វីរី បានធ្វើដំណើរទៅប្រទេសរ៉ូម៉ានីនិងយូហ្គោស្លាវីដើម្បីចូលរួមសមាជនិស្សិតខ្មែរនៅអឺរ៉ុប ។ សមាជនេះមានទិសដៅប្រមែប្រមូលយុវជនខ្មែរទាំងអស់នៅអឺរ៉ុបឲ្យប្រឆាំងនឹងចក្រពត្តិអាមេរិកដែលឈ្លានពានទឹកដីកម្ពុជា ។ អ្នកដែលមកចូលរួមក្នុងសមាជនេះគឺជាតំណាងអង្គការយុវជនរួបរួមជាតិកម្ពុជានៅប្រទេសយូហ្គោស្លាវី ឆេកូស្លូវ៉ាគី សហភាពសូវៀត និងតំណាងសមាគមនិស្សិតនិងអាណិកជនខ្មែរនៅប្រទេសបារាំងនិងអាល្លឺម៉ង់ ។

និស្សិតដែលមកចូលរួមនៅពេលនេះមានទិន្នាការខុសៗគ្នាដែលជាហេតុធ្វើឲ្យសមាជពុំបានសម្រេចទិសដៅរបស់ខ្លួនក្នុងការគាំទ្រគោលនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ ផ្ទុយទៅវិញ ការជួបជុំនៅពេលនេះប្រែក្លាយទៅជាកម្លាំងមួយទៀតដែលប្រណាំងប្រជែងនឹងគោលនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយត្រូវបានរណសិរ្សនេះប្រកាសរំលាយចោល ។

នៅឆ្នាំ១៩៧២ ដោយមានការធានាពី ជា សាន ឯកអគ្គរដ្ឋទូតរណសិរ្សរួបរួមជាតិកម្ពុជានៅសហភាពសូវៀត វីរី បានទៅបន្តការសិក្សាថ្នាក់បណ្ឌិតវិស្វករផ្នែកវារីបច្ចេកទេសនៅវិជ្ជាស្ថានសំណង់ក្រុងមូស្គូ ។ នៅក្នុងពិធីជប់លៀងអបអរពិធីចូលឆ្នាំសកលឆ្នាំ១៩៧២ វីរី បានជួប ឡុង សៀម និង តឹក ជូរ ដែលទើបតែបានចូលធ្វើការនៅវិទ្យុមូស្គូ ។ ឡុង សៀម និង តឹក ជូរ បានសំណូមពរឲ្យ វីរី និងនិស្សិតខ្មែរនៅសហភាពសូវៀតជួយគាំទ្រខ្លួនក្នុងផែនការបើកទីស្នាក់ការរណសិរ្សរួបរួមជាតិមួយទៀតនៅទីក្រុងមូស្គូដើម្បីធ្វើសហប្រតិបត្តិការជិតស្និទ្ធជាមួយសូវៀតនិងដើម្បីបានទទួលជំនួយគ្រប់បែបយ៉ាងពីសូវៀតផង ។ ទទួលបាន

ដំណើរនេះ ជា សាន បានទៅជួបនឹងអគ្គការរដ្ឋសូវៀត ហើយបានរារាំងផែនការរបស់ ឡុង សៀម និង តឹក ជូរ ។ តាំងពីពេលនោះមក វីរី លែងបានជួបអ្នកទាំងពីររហូតដល់ពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៦ ។

តាំងពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៦ វីរី បានបន្ថយសកម្មភាពទាក់ទងនឹងក្រុមកា.ហេ្វ.បេសូវៀត ដោយសារម្យ៉ាងគាត់ជាប់រវល់ក្នុងការរៀនសូត្រ និងម្យ៉ាងទៀតគាត់ត្រូវបំពេញភារកិច្ចដែលក្រុមប្រឹក្សាអ្នកប្រាជ្ញវារីបច្ចេកទេសរបស់សូវៀតដាក់ឲ្យ ធ្វើគឺរៀបចំអត្ថបទវិទ្យាសាស្ត្រអំពីការរបកគំហើញថ្មីរបស់គាត់ដើម្បីយកទៅថ្លែងនៅក្នុងសន្និសីទវិទ្យាសាស្ត្របច្ចេកទេសដែលរៀបចំរៀងរាល់ឆ្នាំនៅវិទ្យាស្ថានសំណង់ទីក្រុងមូស្គូ ។

វីរី បានទទួលសញ្ញាបត្រថ្នាក់បណ្ឌិតវិស្វករនៅថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៧៦ ។

វីរី បានចាកចេញពីទីក្រុងមូស្គូមកទីក្រុងប៉េកាំងនៅថ្ងៃទី៣១ ខែ៧ ឆ្នាំ១៩៧៦ ហើយបន្ទាប់ពីស្នាក់នៅទីក្រុងប៉េកាំង អស់រយៈពេលពីរបីថ្ងៃ គាត់បានត្រឡប់មកប្រទេសកម្ពុជានៅថ្ងៃទី៦ ខែ៨ ។ អង្គការឲ្យ វីរី ទៅស្នាក់នៅក្នុងមន្ទីរ ក-១៥ ។ ដោយទើបនឹងមកដល់ថ្មីៗ វីរី មិនទាន់បានធ្វើសកម្មភាពអ្វីធំដុំនៅឡើយទេ ។ គាត់បានជួបជាមួយមិត្តភក្តិចាស់ៗមួយចំនួនដែលជានិស្សិតពីបរទេសមកដល់មុនគាត់ ហើយជជែកគ្នាអំពីការមិនពេញចិត្តរបស់ខ្លួនចំពោះគោលនយោបាយរបស់អង្គការទាក់ទងនឹងបញ្ហាប្រព័ន្ធគ្រប់គ្រង ការបំបាត់កម្មសិទ្ធិឯកជន ការលុបបំបាត់ក្រដាសប្រាក់ ការបែងចែកវណ្ណៈប្រជាជន និងការបំបាត់អ្វីៗទាំងអស់នៅក្នុងសង្គម ហើយប្រៀបធៀបសង្គមនិយមនៅកម្ពុជាទៅនឹងសង្គមនិយមនៅសហភាពសូវៀត ។ ពីរខែក្រោយមក គឺនៅថ្ងៃទី១២ ខែ១០ គាត់ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកសួរចម្លើយនៅមន្ទីរស-២១ ។

វីរី ត្រូវបានសួរចម្លើយមិនតិចជាងសាមសិបដងដោយសមមិត្តឆាយ នៅក្នុង «ពួកបងរុន» ហើយត្រូវអង្គការសម្លាប់នៅថ្ងៃទី១៨ ខែ៣ ឆ្នាំ១៩៧៧ ។

ឡាំ វីរី មានឪពុកឈ្មោះ ឡាំ សោម ម្តាយឈ្មោះ មេង គិមស៊ិន និងមានបងប្អូនបង្កើត១០នាក់ ។ ប្រពន្ធរបស់ វីរី ជាជនជាតិរុស្ស៊ីឈ្មោះ ណាដេសដា នីកូឡៃយេវ៉ា និងកូនស្រីឈ្មោះ ឡាំ សូភីវីរីយ៉ាន រស់នៅសហភាពសូវៀត ។ **សូ ហ្វារីណា**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយ: យិន នាន**

***(តពីលេខមុន)***

| លរ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២១៣០ | គ្រៀល យ៉ែម | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣១ | សុខ សុផាត | ជួសជុល | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣២ | ហៀង គីមឡេង | បច្ចេកទេស | សហករណ៍ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៣ | សំ បួ | អ្នកដួងខ្សែកាប | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៤ | ស៊ិន ចេង | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៥ | អ៊ឹង ប៊ីហួត | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៦ | ប៊ុន ផា | បង្កើនផល | ស្ទឹងមានជ័យ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៧ | ឡុង ផនស៊ី | ជួសជុលម៉ាស៊ីន | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៨ | ណាប់ យ៉េន | នេសាទ | ស្ទឹងមានជ័យ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៣៩ | អ៊ី ខឿន | កម្មករចាស់ | អគ្គិសនីទី២ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤០ | ទេព ផុន | យន្តការី | អគ្គិសនីទី២ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤១ | ប៊ុង ឆា | ជួសជុលម៉ាស៊ីន | អគ្គិសនីទី២ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤២ | យូ គីមអេង ហៅ អាត | អ្នកចិញ្ចឹមសត្វ | សហករណ៍ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៣ | ឆាយ នឹម | ផាងក្រឡឹង | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៤ | យៀង ទ្រី | កម្មករចាស់ | សហករណ៍ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៥ | អ៊ុង យុាំ | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៦ | ទឹម ស៊ីផាត | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៧ | សៅ ហួត | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៨ | ចាន់ វ៉េត | កម្មករចាស់ | សហករណ៍ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៤៩ | ហ៊ុម ភីម ហៅ ផាន | កម្មករថ្មី | អគ្គិសនីទី១ | ១៥-៣-៧៧ | ៦-៤-៧៧ |
| ២១៥០ | ឈុន ណាវ៉ាឌី | កម្មករថ្មី | ជ្រោយចង្វារ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៥១ | សោម វ៉ានថា ហៅ ថាត (ស្រី) | យុទ្ធនារី | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៥២ | ឃីម សុគីន (ស្រី) | សមាជិកឃ្លាំង | អគ្គិសនីទីកថ្វា | ២៦-៣-៧៧ | ៦-៤-៧៧ |
| ២១៥៣ | វ៉េត កិញ្ញវ៉ា ហៅ វ៉ាន (ស្រី) | យុទ្ធនារី | សហករណ៍ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៥៤ | ឃីម សុខាវដា ហៅ នី (ស្រី) | យុទ្ធនារី | សហករណ៍ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៥៥ | អេង កោយីង ហៅ គៅ (ស្រី) | មេពួក | អគ្គិសនីទី២ | ២៦-៣-៧៧ | ៦-៤-៧៧ |
| ២១៥៦ | ឃីម សុគីម ហៅ ធី (ស្រី) | គណៈកម្មការឃ្លាំង | អគ្គិសនីទីកថ្វា | ២៦-៣-៧៧ | ៦-៤-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២១៥៧ | យុន គឹមអ៊ាន ហៅ ពន្ធី (ស្រី) | បង្រៀនកុមារ | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៥៨ | ជា កិត្តិយា ហៅ កេត (ស្រី) | ប្រធានក្រុម | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៥៩ | តាន់ ឃីម ហៅ សាត | ប្រធានរោងជាង | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៦០ | អ៊ូ អេងឡាង | កម្មករចាស់ | សហករណ៍ | ១-៣-៧៧ | ៦-៤-៧៧ |
| ២១៦១ | ស៊ុយ គឹមថាន | ផ្នែកឡចំហាយ | អគ្គិសនីទី២ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៦២ | សួស សុខិនទ្រី ហៅ សេង | មេក្រុម | សហករណ៍ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៦៣ | ឈាវ គឹម ហៅ ជាង | មេក្រុម | បណ្តាញអគ្គិសនី | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៦៤ | ជុំ ស៊ីរ៉េត ហៅ រេត | ពេទ្យ | សហករណ៍ | ១៧-៣-៧៧ | ៦-៤-៧៧ |
| ២១៦៥ | សេន សាយ ហៅ សុត | កម្មករចាស់ | សហករណ៍ | ១-៣-៧៧ | ៦-៤-៧៧ |
| ២១៦៦ | ឡុង ឆនង៉ន | មេពួក | អគ្គិសនីទី១ | ?-៣-៧៧ | ៦-៤-៧៧ |
| ២១៦៧ | អ៊ុក សារិន ហៅ សាង | កម្មករថ្មី | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៦៨ | សូ សំ ហៅ ស៊ុន | ប្រធានក្រុម | សហករណ៍ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៦៩ | ចៅ វ៉ន | បច្ចេកទេស | អគ្គិសនី | ១៣-៣-៧៧ | ៦-៤-៧៧ |
| ២១៧០ | សឹន ជន | មេក្រុម | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៧១ | ឃ្លោក សុន | កម្មករថ្មី | សាធារណការ | ២៤-៣-៧៧ | ៦-៤-៧៧ |
| ២១៧២ | ចៅ សេង | ប្រធានជួសជុល | អគ្គិសនីទី១ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៧៣ | រិន រឿន | កម្មករ | អគ្គិសនីទី១ | ២៣-៣-៧៧ | ៦-៤-៧៧ |
| ២១៧៤ | គឹម ស្រ៊ុ ហៅ អាន | យុវជន | សហករណ៍ | ១៨-៣-៧៧ | ៦-៤-៧៧ |
| ២១៧៥ | ឆៃ គី (ស្រី) | ម៉ាស៊ីនបូមទឹក | ភូមិព្រែក | ?-៣-៧៧ | ៦-៤-៧៧ |
| ២១៧៦ | ម៉ី ដល្លី ហៅ នុត (ស្រី) | កាត់ដេរ | អគ្គិសនីទី២ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៧៧ | តាំង ឡាន (ស្រី) | ប្រពន្ធ លី | សហករណ៍ | ១១-៣-៧៧ | ៦-៤-៧៧ |
| ២១៧៨ | យស់ សាយ | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៧៩ | អ៊ុន ខឿន | កម្មករចាស់ | អគ្គិសនីទី១ | ១៦-៣-៧៧ | ៦-៤-៧៧ |
| ២១៨០ | សាយ គឹម ហៅ កន | កម្មករថ្មី | អគ្គិសនីទី១ | ៣១-៣-៧៧ | ៦-៤-៧៧ |
| ២១៨១ | ទី សុងគាំង ហៅ កង | មើលកុមារ | សហករណ៍ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៨២ | កែ យាន ហៅ យាន | កម្មករថ្មី | អគ្គិសនីទី២ | ១៨-៣-៧៧ | ៦-៤-៧៧ |
| ២១៨៣ | ខ្វា លាង ហៅ ឡេង | ប្រធានផ្នែក | សហករណ៍ | ១៣-៣-៧៧ | ៦-៤-៧៧ |
| ២១៨៤ | ភាច គឹមសេង ហៅ ស៊ឹម | មើលកុមារ | សហករណ៍ | ១៨-៣-៧៧ | ៦-៤-៧៧ |
| ២១៨៥ | នាក់ សុខាណា ហៅ ខន | ដាំបន្លែ | សហករណ៍ | ១២-៣-៧៧ | ៦-៤-៧៧ |
| ២១៨៦ | មិន សំបូរ ហៅ បាន | មើលកុមារ | សហករណ៍ | ១៨-៣-៧៧ | ៦-៤-៧៧ |
| ២១៨៧ | ពុធ គឹមសេង ហៅ លី | ជាងជួសជុល | អគ្គិសនីទី២ | ១-៣-៧៧ | ៦-៤-៧៧ |

**(នៅមានត)**

# អតីតអ្នកទោសគុកសង់បានធូរស្រាលពីជំងឺផ្លូវចិត្ត

ជារៀងរាល់ឆ្នាំ ឡី ប៉ាក់ មិនដែលទៅចូលរួមពិធីរាប់បាត្រនៅគុកសង់ (ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល) ដើម្បីឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅទីនោះឡើយ ។ គុកសង់ជាកន្លែងដែលខ្មែរក្រហមផ្តាច់ជីវិតកូនស្រីពៅជាទីស្រលាញ់របស់ ឡី ប៉ាក់ និងបន្ទុំឲ្យគាត់រស់នៅយ៉ាងវេទនា ។ ប៉ាក់ ជាអ្នកទោសនៅគុកសង់ម្នាក់ដែលរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ ។ គាត់មិនចង់ឃើញគុកសង់ទេ ព្រោះគាត់មិនចង់រំឭករឿងរ៉ាវឈឺចាប់ ។ ប៉ាក់ បានហៅគុកសង់ថាជាឋាននរក ជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវ ។ ព្រឹត្តិការណ៍ដែលគាត់បានឆ្លងកាត់នៅក្នុងគុកសង់ហាក់ដូចជានៅថ្មីៗនៅឡើយ ។


ឡី ប៉ាក់

ប៉ាក់ ត្រូវខ្មែរក្រហមចាប់ខ្លួនបញ្ជូនទៅគុកសង់ជាមួយកូនតូចៗ៣នាក់ និងម្តាយឪពុកជរារបស់គាត់នៅដើមឆ្នាំ១៩៧៨ បន្ទាប់ពីប្តីរបស់គាត់ត្រូវខ្មែរក្រហមនាំយកទៅរៀនសូត្របាត់ដំណឹងមិនឃើញត្រឡប់មកវិញ ។

ប្តីរបស់ ឡី ប៉ាក់ ត្រូវអង្គការបញ្ជូនទៅរៀនសូត្រក្នុងឆ្នាំ១៩៧៧ ពេលដែល ឡី ប៉ាក់ ទើបតែសម្រាលកូនទី៣បាន៣ខែ ។ កាលណោះក្រុមគ្រួសាររបស់ ប៉ាក់ រស់នៅវត្តព្រះធាតុដែលមានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីភូមិចំបក់គ្រប់ ឃុំព្រែករកា ដែលជាភូមិកំណើតរបស់គាត់ ។ តាំងពីពេលនោះមកគាត់មិនដែលទទួលដំណឹងអ្វីពីប្តីរបស់គាត់ទាល់តែសោះ ។ ដោយបាត់ប្តីមិនដឹងមូលហេតុ ប៉ាក់ ក៏ទៅសួរគណៈឃុំឈ្មោះសន ។ គណៈឃុំរូបនោះឆ្លើយថា "កុំសួរ ។ ឲ្យតែខ្វាំងគឺខ្មោចហើយ" ។ ប៉ាក់ ដឹងច្បាស់ថាប្តីរបស់គាត់ពិតជាត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ ព្រោះអ្នកដែលខ្មែរក្រហមហៅទៅប្រជុំឬទៅរៀនសូត្រមិនដែលឃើញត្រឡប់មកវិញសោះ ។

ក្រោយពីខ្មែរក្រហមយកប្តីរបស់គាត់ទៅបាន៤ខែ ប៉ាក់ ក៏ត្រូវឈ្លបខ្មែរក្រហមបញ្ជូនទៅគុកសង់ដោយបោកបញ្ឆោតថាឲ្យគាត់ទៅស្រុកកំណើតវិញ ។ ប៉ាក់ រំឭកហេតុការណ៍នោះថា "ល្ងាចមួយនៅដើមឆ្នាំ១៩៧៨គេប្រាប់ខ្ញុំថា ឥឡូវឲ្យរើងទៅនៅស្រុកទេសវិញហើយ ។ ខ្ញុំក្តីតែគេឲ្យទៅស្រុកវិញ ខ្ញុំអរណាស់ ។ ស្រាប់តែយប់ឡើងពេលដែលខ្ញុំកំពុងសម្រាន្ត ស្រាប់តែវាព័ទ្ធជុំវិញផ្ទះទាំងអស់ ។ ខ្ញុំដឹងថាខ្មែរក្រហមយកខ្ញុំទៅសម្លាប់ហើយ ណាមួយខ្ញុំទើបតែបាត់ប្តីថ្មីៗផង" ។ ឈ្លបខ្មែរក្រហមពីរបីនាក់បានមកហៅប៉ាក់ឲ្យទៅជាមួយទាំងយប់ ។ ប៉ាក់ ប្រកែកថា បើចង់យកគាត់ទៅសម្លាប់មិនបាច់យកទេ សូមសម្លាប់គាត់នៅទីនេះចុះ ។ បើចង់ឲ្យគាត់ទៅទាល់តែយកម្តាយឪពុករបស់គាត់ទៅដែរ ព្រោះឪពុករបស់គាត់កំពុងតែឈឺធ្ងន់ ។ ឈ្លបខ្មែរក្រហមបានជំនុំគ្នាមួយសន្ទុះក៏ត្រឡប់ទៅវិញ ហើយព្រឹកឡើងរៀបចំរទេះគោមួយមកដឹកម្តាយឪពុករបស់គាត់ទៅជាមួយ ។ រទេះគោបានបរចេញពីវត្តព្រះធាតុសំដៅទៅគុកសង់ដោយកាត់តាមភូមិចំបក់គ្រប់ដែលជាភូមិកំណើតរបស់ ប៉ាក់ ។ ពេលរទេះបរដល់មុខផ្ទះរបស់គាត់ ប៉ាក់ សួរឈ្លបខ្មែរក្រហមដែលកំពុងតែបររទេះថា "ដល់ផ្ទះខ្ញុំហើយម្តេចក៏មិនឈប់?" ឈ្លបខ្មែរក្រហមមិនឆ្លើយ ហើយក៏មិនឈប់រទេះ ។ រទេះគោបាននាំក្រុមគ្រួសាររបស់គាត់ដល់កន្លែងមួយដែលក្រោយមកទើបគាត់ដឹងថាទីនោះជាមន្ទីរឃុំឃាំងរបស់ខ្មែរក្រហម គឺគុកសង់ ។ ប៉ាក់ បានរៀបរាប់ទៀតថា "ពេលមកដល់មុខផ្ទះខ្ញុំ ខ្ញុំក៏សួរឈ្លបថាម៉េចមិនឈប់បើដល់ផ្ទះខ្ញុំហើយ ។ ពួកគេមិនព្រមឈប់ហើយចេះតែបរទៅមុខទៀតហើយ ខ្ញុំមិនដឹងថាពួកគេយកខ្ញុំទៅណាទេ ។ ពេលចូលទៅដល់គុកសង់ ទើបគ្រួសារខ្ញុំទ្រហោយំទាំងអស់គ្នា ។ ស្រាប់តែមួយសន្ទុះ អ្នកនេះក៏មក អ្នកនោះក៏មក សុទ្ធតែរទេះនាំមកហើយពុកូនចៅស្រែកយំ

រញ៉េករញ៉ាក» ។ ទៅដល់គុកសង់ភ្លាម គ្រួសាររបស់ ប៉ាក់ ត្រូវខ្មែរក្រហមដកហូតរបស់ជាកម្មសិទ្ធិដែលមានបន្តិចបន្តួចជាប់ខ្លួនរួចហើយឆ្មាំគុករុញចូលក្នុងបន្ទប់គុកចាក់សោបិទទ្វារជិតឈឹងចំនួនមួយយប់ ។ ប៉ាក់ បាននិយាយពីស្ថានភាពនៅក្នុងគុកងងឹតនោះថា «ខ្មែរក្រហមបញ្ចូលខ្ញុំទៅឲ្យក្នុងគុកបិទទ្វារទាំងអស់គ្នា ។ ទាំងកូនគេទាំងកូនខ្ញុំឃុំពេញក្នុងហ្នឹង ។ ម្នាក់ៗបែកញើសជោកអស់ហើយ ទឹកក៏អត់បានហូប» ។ ព្រឹកថ្ងៃបន្ទាប់ទើបខ្មែរក្រហមបើកទ្វារគុក ហើយអនុញ្ញាតឲ្យអ្នកទោសទាំងអស់ទៅដងទឹកដឹកពីទន្លេបាទីសម្រាប់ផឹកខ្លួនឯង ក្រោមការយាមកាមយ៉ាងតឹងរ៉ឹងពីឆ្មាំគុក ។ ប៉ាក់ បានរៀបរាប់ពីស្ថានភាពនៅក្នុងគុកថា នៅពេលយប់អ្នកទោសទាំងអស់ត្រូវដាក់ខ្នោះ ពេលថ្ងៃអ្នកទោសភេទប្រុសត្រូវដាក់ខ្នោះជាប់គ្នាពីរៗនាក់ ចំណែកអ្នកទោសភេទស្រីមិនត្រូវបានដាក់ខ្នោះទេ ។ អ្នកទោសមិនអនុញ្ញាតឲ្យនិយាយគ្នាពេលចូលដេកទេ ។ រៀងរាល់ព្រឹក អ្នកទោសទាំងអស់ត្រូវតម្រង់ជួរចេញពីគុកដើម្បីទៅធ្វើការតាមការចាត់តាំង ។ ពេលដែលកំពុងធ្វើការ ប៉ាក់ ឃើញឈ្លបខ្មែរក្រហមនាំបណ្តើរមនុស្សទៅ ប៉ាក់ គិតក្នុងចិត្តថា អ្នកទាំងនោះពិតជាត្រូវយកទៅសម្លាប់ហើយ ។ ពេលដែលគាត់សម្លឹងមើលទៅអ្នកទោសដែលឈ្លបខ្មែរក្រហមបណ្តើរទៅ ឆ្មាំគុកម្នាក់ស្រែកឲ្យគាត់ថា «ចុះង៉ែងនៅមើលអី? បើថាឲ្យធ្វើអីធ្វើតែហ្នឹងទៅ កុំងាកមុខក្រោយឲ្យសោះ» ។ ឮដូច្នោះ ប៉ាក់ ភ័យខ្លាចយ៉ាងខ្លាំងហើយមិនដែលធ្វើអ្វីជំទាស់នឹងបញ្ជារបស់ឆ្មាំគុកទេ ។ ពេល ប៉ាក់ មានកំហុសបន្តិចបន្តួច ប្រធានគុកឈ្មោះ ម៉ុង គំរាមគាត់ថា «ង៉ែង ប្រយ័ត្នឲ្យមែនទែន ប្រយ័ត្នងាប់ដូចខ្មោចប្តីង៉ែង» ។ កូនស្រីតូចរបស់ ប៉ាក់ ដែលទើបតែមានអាយុ៧ខែ បានស្លាប់នៅក្នុងគុកដោយសារតែគាត់ខ្វះទឹកដោះឲ្យកូនបៅ ។

រហូតមកដល់ថ្ងៃនេះ ប៉ាក់ នៅមិនដឹងថាហេតុអ្វីបានជាខ្មែរក្រហមចាប់ប្តីរបស់គាត់ទៅសម្លាប់ហើយយកគាត់ទៅដាក់ឃុំឃាំងដូច្នេះទេ ។ ទោះបីជាពេលនោះគាត់មានសេរីភាពច្រើនជាមុនក៏ដោយ ក៏ផ្លូវចិត្តរបស់គាត់គ្មានសេរីភាពដែរ ។ ដោយសារការបាត់បង់ប្តីនិងកូនជាទីស្រឡាញ់ ការគំរាមកំហែងមើលងាយមើលថោកពីសំណាក់ឆ្មាំគុកខ្មែរក្រហម បានធ្វើឲ្យ ប៉ាក់ ក្លាយជាមនុស្សបាក់ស្បាត ភ័យខ្លាចនិងមិនចង់ជួបអ្នកដទៃ និងមានអារម្មណ៍មិននឹងន ។ តាមរយៈ«គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ាក់ ត្រូវបានរកឃើញថាមានបញ្ហាផ្លូវចិត្ត ហើយកំពុងតែទទួលការព្យាបាលសុខភាពផ្លូវចិត្តដោយមានកិច្ចសហការពីអង្គការចិត្តសង្គមអន្តរវប្បធម៌ ។ ការព្យាបាលនេះចាប់ផ្តើមតាំងពីខែមករាឆ្នាំ២០០៥ ហើយនឹងបន្តរហូតដល់ខែកញ្ញាឆ្នាំនេះ ។

បន្ទាប់ពីទទួលការពិគ្រោះនិងព្យាបាលអស់រយៈពេល៦ខែ ស្ថានភាពផ្លូវចិត្តរបស់ ប៉ាក់ បានធូរស្បើយច្រើន ។ គាត់មិនឆាប់តក់ស្លុតដូចពីមុន ឈប់ញ័រទ្រូង និងសម្រាន្តបានច្រើនជាងមុន ។ លោក លាង ឡូ អ្នកជំនាញចិត្តសាស្ត្ររបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ និងជាអ្នកផ្តល់ប្រឹក្សាដល់ ប៉ាក់ ផ្ទាល់ បាននិយាយថា «ឥឡូវនេះ មីងប៉ាក់ បានធូរច្រើន ។ គាត់ចេះវិធីដោះស្រាយបញ្ហាពេលដែលគាត់ជួបភាពតានតឹងក្នុងចិត្ត ។ ដូចជាថ្មីៗនេះ ពេលមានអំពើឃាតកម្មនៅក្នុងភូមិ គាត់ហ៊ានទៅមើលមុខសពនោះ ។ បើកាលពីមុនគ្រាន់តែឮរឿងបែបនេះគាត់ភ័យញ័រទ្រូង ញ័រដៃញ័រជើងជាមិនខាន ។ ចំណែកឯរឿងឈឺចាប់ពីរបបប៉ុលពតគាត់នៅតែនឹកឃើញ ប៉ុន្តែមិនរំខានអារម្មណ៍របស់គាត់ដូចពីមុនទេ ។ គាត់ចេះវិធីធ្វើឲ្យរសាយចិត្តហើយគិតអ្វីដែលល្អសម្រាប់ពេលបច្ចុប្បន្ននិងទៅអនាគត ។ គាត់ចង់និយាយប្រាប់អ្នកដទៃពីបទពិសោធន៍របស់គាត់ពីរបបខ្មែរក្រហម ហើយគាត់អាចទប់អារម្មណ៍ខ្លួនឯងបាន ។ សុខភាពផ្លូវចិត្តរបស់គាត់មានការប្រសើរឡើងច្រើនបើប្រៀបធៀបកាលពីមិនទាន់ព្យាបាល» ។ អង្គការចិត្តសង្គមអន្តរវប្បធម៌នឹងបន្តព្យាបាលបញ្ហាផ្លូវចិត្តរបស់ ប៉ាក់ រហូតដល់ខែកញ្ញាឆ្នាំ២០០៥ ហើយយើងរំពឹងថា ឡី ប៉ាក់ នឹងមានស្ថានភាពផ្លូវចិត្តប្រក្រតីឡើងវិញ ដើម្បីកុំឲ្យគាត់មានការប៉ះទង្គិចខ្លាំងនៅពេលដែលតុលាការខ្មែរក្រហមកើតឡើងនាពេលអនាគតដ៏ខ្លីខាងមុខនេះ ។

**ញាណ សុជាតិ**

# គ្រួសារ វ៉ាន់ ង៉ាង

ឡេង សាម៉េត ហៅ តិច និង វ៉ាន់ ង៉ាង ជាអ្នកជិតខាងនឹងគ្នា ។ តិច គឺជាស្ត្រីមេម៉ាយនៅក្នុងគ្រួសារកសិករមួយ ។ ឪពុកម្តាយរបស់ ង៉ាង (តាវ៉ាន់និងយាយហ៊ូ) លក់នំប៉័ងនិងនំផ្សេងៗនៅផ្សារស្វាយអន្ទរ ។ តាវ៉ាន់ ជាជនជាតិចិនជំនាន់ទី១ ដែលធ្វើអន្តោប្រវេសន៍មករស់នៅប្រទេសកម្ពុជា (ខ្មែរច្រើនហៅថា ចិនឆៅ) ចំណែកឯ យាយហ៊ូ ជាជនជាតិវៀតណាម ។ ង៉ាង និយាយភាសាខ្មែរបានយ៉ាងច្បាស់ ។ បងប្រុសរបស់ តិច បានណែនាំ ង៉ាង និង តិច ឲ្យស្គាល់គ្នា ។ អ្នកទាំងពីររៀបការនៅឆ្នាំ១៩៧៣ នៅភូមិត្របែកវត្តត្រាច ក្នុងឃុំអង្គរទ្រេត ស្រុកព្រៃវែង ខេត្តព្រៃវែង ។ គ្មានអ្នកជិតខាងឬញាតិមិត្តណាម្នាក់យល់ទាស់ចំពោះអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរឡើយ ។ បន្ទាប់ពីរៀបការរួច ប្តីប្រពន្ធនេះបានផ្លាស់ទៅរស់នៅភូមិពោធិចិនដាំ ។ ង៉ាង ប្រកបរបរលក់អង្ករនិងជ្រូករស់នៅផ្សារស្វាយអន្ទរ ។

នៅក្នុងរបបខ្មែរក្រហម ង៉ាង ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅកាប់រំពាក់ហើយបានបាត់ខ្លួនរហូត ។ ហេង ហ៊ុយ ជនជាតិខ្មែរដែលទៅកាប់រំពាក់ជាមួយ ង៉ាង បានត្រឡប់មកផ្ទះវិញ ។ ប្រហែលមួយឆ្នាំក្រោយការបាត់ខ្លួនប្តីរបស់គាត់ តិច ស្ម័គ្រចិត្តផ្លាស់ទៅរស់នៅតំបន់ដីខ្សាច់នៅក្នុងខេត្តពោធិ៍សាត់ ដោយសង្ឃឹមថានឹងរស់នៅបានប្រសើរជាងមុនដូចការឃោសនារបស់អង្គការ ។ នៅទីនោះ កូនរបស់គាត់ពីរនាក់បានស្លាប់ដោយរោគកញ្ជ្រិល ខ្លួនគាត់ត្រូវបង្ខំឲ្យធ្វើការនៅតាមវាលស្រែគ្មានឈប់សម្រាក ហើយមានពេលតែបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីមើលថែកូនតូចៗ ។

នៅពេលត្រឡប់មកភូមិកំណើតនៅឆ្នាំ១៩៧៩ តិច គ្មានផ្ទះ គ្មានដី គ្មានទាំងប្តី ។ តិច ព្រមទាំងកូនប្រុសឈ្មោះ ង៉ុយ និង កូនស្រីឈ្មោះ គុប រស់នៅជាមួយអ្នកជិតខាង ។ តិច រត់គុ នៅក្នុងហាងគុយទាវមួយ ហើយចាប់ពីឆ្នាំ១៩៩៩គាត់ធ្វើជាចុងភៅឲ្យមេព្រៃម្នាក់ ។ ង៉ុយ បានរៀបការនិងមានកូនបីនាក់ ហើយបានផ្លាស់ទៅរស់នៅស្រុកអូររាំងឪ ខេត្តកំពង់ចាម ។ ង៉ុយ ប្រកបរបរទិញជ្រូកលក់ ។ គុប នៅលីវរស់នៅជាមួយគ្រួសារមួយដែលសុំទានយកទៅចិញ្ចឹម ។ ទាំង ង៉ុយ និង គុប មិនចេះភាសាវៀតណាមទេ ។

### គុបៈ កូនស្រីរបស់ វ៉ាន់ ង៉ាង


គុប

ឪពុករបស់ខ្ញុំជាជនជាតិវៀតណាម ។ កាលដែលគាត់នៅរស់ គាត់ស្រលាញ់ខ្ញុំណាស់ ។ គាត់មិនដែលវាយខ្ញុំឬសូម្បីតែគំហកឲ្យខ្ញុំក៏មិនដែលដែរ ។ គាត់និយាយភាសាវៀតណាមជាមួយខ្ញុំ តែខ្ញុំអត់ចេះទេ ។ យាយនិងតាស្រឡាញ់ខ្ញុំណាស់ ហើយខ្ញុំក៏ស្រឡាញ់យាយតានិងពុកម៉ែខ្ញុំដែរ ។

ឪពុកខ្ញុំត្រូវអង្គការបញ្ជូនទៅកាប់រំពាក់ហើយសម្លាប់គាត់ចោល ។ ខ្ញុំដឹងរឿងនេះដោយសារម៉ែប្រាប់ខ្ញុំ ។ ពេលដែលពុកខ្ញុំចេញទៅកាប់រំពាក់ ខ្ញុំអត់បានឃើញពេលគាត់ចេញដំណើរទេ ។ អ្នកដែលទៅជាមួយគាត់បានត្រឡប់មកផ្ទះវិញ បាត់តែគាត់ ។ អ្នកដែលបានត្រឡប់មកវិញគឺជាជនជាតិខ្មែរ ។ ម្តាយខ្ញុំប្រាប់ខ្ញុំឲ្យឈប់យំទៅ ឪពុកខ្ញុំត្រូវគេសម្លាប់ចោលហើយ ។ ម៉ាក់លួងលោមខ្ញុំថា "កូនស្រីសំលាញ់ម្តាយ កុំយំអី យើងមិនអាចធ្វើអ្វីបានទេ ឪពុកកូនគឺជាជនជាតិវៀតណាម" ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាជនជាតិវៀតណាមត្រូវសម្លាប់ចោលដូច្នេះសោះ ។ ខ្ញុំក្រៀមក្រំណាស់កាលនោះ ព្រោះឃើញកូនគេមានឪ ។ ម៉ែយំរាល់យប់ ។

បន្ទាប់ពីសម្លាប់ឪពុកខ្ញុំហើយជនជាតិខ្មែរហៅខ្ញុំថាកូនអត់ឪ ។ ខ្ញុំពិបាកចិត្តណាស់ ព្រោះឃើញគេមានឪនៅជាមួយ ចំណែកខ្ញុំមានតែម៉ែ ។ គ្មានឪពុករបស់ខ្ញុំ ម្តាយខ្ញុំពិបាកណាស់ព្រោះគ្មានអ្នកណាជួយចិញ្ចឹមគ្រួសារ ។ បើឪពុកខ្ញុំនៅរស់គាត់ជាអ្នករកស៊ីចិញ្ចឹមគ្រួសារ ហើយម្តាយខ្ញុំនៅតែផ្ទះ ។ ក្រោយឆ្នាំ១៩៧៩ គ្មានអ្នកណាមើលងាយមើលថោកក្រុមគ្រួសារខ្ញុំទេ ព្រោះគ្រួសារខ្ញុំស្លូតណាស់ ។ អ្នកជិតខាងក៏រាប់អានយើងណាស់ដែរ ។

*តាំងពីឆ្នាំ១៩៧៩ ពេលដែលខ្ញុំអាយុ៨ឆ្នាំ ខ្ញុំទៅរស់នៅជាមួយឪពុកម្ដាយចិញ្ចឹមឈ្មោះ អាន និង ធី ម៉ុម នៅក្បែរផ្សារស្វាយអន្ទរ ។ ខ្ញុំដាំស្វនិងជួយលក់ក្រណាត់ជាមួយគាត់ ។*

*ខ្ញុំចង់ឲ្យឪពុកខ្ញុំត្រឡប់មករកខ្ញុំវិញ ប៉ុន្តែតើខ្ញុំអាចធ្វើអ្វីកើត បើគាត់ស្លាប់បាត់ទៅហើយ? ខ្ញុំខឹងនឹងអ្នកសម្លាប់ពុកខ្ញុំណាស់ ។ គ្មានអ្វីអាចជំនួសការបាត់បង់ឪពុកខ្ញុំទេ ។*

**គិចៈ ប្រពន្ធរបស់ វ៉ាន់ ដាង**

*ប្ដីខ្ញុំស្គាល់ខ្ញុំដោយសារបងប្រុសរបស់ខ្ញុំណែនាំ ។ ក្រោយមកគាត់ក៏ពឹងចាស់ទុំឲ្យចូលស្ដីដណ្ដឹងខ្ញុំរៀបការ ។ ខ្ញុំមិនដែលស្គាល់គាត់ទេពីមុនមក ។ ខ្ញុំជួបគាត់លើកទីមួយនៅភូមិត្របែកនៅវត្តត្រាច ។ មុនពេលរៀបការ គាត់លក់ត្រី ។ ពេលរៀបការហើយយើងផ្លាស់នៅរស់នៅភូមិពោធិចិនដាំ ។ អ្នកភូមិចូលចិត្តយើងណាស់ មិនដែលនិយាយអាក្រក់ពីយើងទេ ។ គាត់និយាយភាសាខ្មែរច្បាស់ណាស់ ហើយមើលទៅរូបរាងគាត់ក៏មិនដូចជាវៀតណាមដែរ ។*

*គាត់កើតនៅខេត្តព្រៃវែង ឪពុករបស់គាត់ជាជនជាតិចិន ចំណែកម្ដាយគាត់ជាជនជាតិវៀតណាម ។ ឪពុកម្ដាយក្មេកខ្ញុំរស់នៅខេត្តព្រៃវែង ។ ម្ដាយក្មេកខ្ញុំស្លាប់មុនពេលខ្ញុំរៀបការ ។ ខ្ញុំរៀបការក្នុងរបបលន់នល់ពីរឆ្នាំមុនរបបខ្មែរក្រហម ។ ខ្ញុំមានកូន៥នាក់ ឥឡូវនេះនៅសល់តែបីនាក់ទេ ។ កូនពីរនាក់ស្លាប់នៅជីខ្លាញ់ ទាំងនៅបៅដោះខ្ញុំនៅឡើយ ។*

*ប្ដីខ្ញុំត្រូវសម្លាប់ក្នុងពេលដំណាលគ្នានឹងប្ដីរបស់ បងអឿន (អ្នកជិតខាងម្នាក់ដែលមានប្ដីជាជនជាតិវៀតណាមដែរ) ប៉ុន្តែប្ដីខ្ញុំត្រូវសម្លាប់មុនគេបន្តិច ។ ក្រោយមកបន្តិចទើប តាជុយ ប្ដីរបស់បងអឿន ត្រូវសម្លាប់ដែរ ។*

*ពេលដែលប្ដីខ្ញុំត្រូវចាប់ខ្លួន យើងទាំងពីរនាក់កំពុងតែនៅផ្ទះ ។ ពេលព្រឹក អង្គការប្រាប់គាត់ឲ្យប្រជុំ ។ នៅក្នុងអង្គប្រជុំ អង្គការបានចុចឈ្មោះបុរសមួយចំនួនដែលត្រូវទៅកាប់រពាក់ ។ ចុងភៅខ្ចប់បាយរួចស្រេចសម្រាប់ឲ្យអ្នកដែលត្រូវទៅកាប់រពាក់ ។ កាលនោះខ្ញុំធ្វើការនៅរោងបាយ ។ ខ្ញុំកម្រទៅជីកប្រឡាយណាស់ ព្រោះកូនខ្ញុំនៅបៅដោះនៅឡើយ ។ ពេលចេញដំណើរទៅ ប្ដីខ្ញុំផ្ដាំខ្ញុំថា «ឯងថែរក្សាកូនយើងឲ្យបានល្អ មិនយូរទេ បួនប្រាំថ្ងៃទៀតខ្ញុំត្រឡប់មកវិញហើយ» ។ អ្នកដែលត្រូវកាប់រពាក់មានទាំងខ្មែរនិងវៀតណាម ប៉ុន្តែក្រោយមកជនជាតិវៀតណាមត្រូវសម្លាប់ចោល ហើយខ្មែរត្រឡប់មកផ្ទះវិញ ។ ខ្ញុំមិនដឹងពីមូលហេតុនៃការសម្លាប់នេះទេ ។ ប្ដីខ្ញុំបាត់ខ្លួនរហូត ។*

*ពេលដែលប្ដីខ្ញុំត្រូវចាប់ខ្លួន កូនពៅរបស់ខ្ញុំទើបតែមានអាយុ៣ខែប៉ុណ្ណោះ ចំណែកកូនប្រុសច្បងអាយុ១០ឆ្នាំ ។ កូនៗមិននៅជាមួយយើងទេ វាកំពុងតែលេងនៅកន្លែងផ្សេង ។ ប្ដីខ្ញុំជិះរទេះចេញទៅម៉ោងប្រហែល៦-៧ល្ងាច ។*

*គាត់ទៅជាមួយមេភូមិពោធិចិនដាំឈ្មោះ សេង ។ បីបួនថ្ងៃក្រោយមក ខ្ញុំសួរអ្នកភូមិថា «គ្រប់គ្នាមកវិញអស់ហើយ ចុះម៉េចក៏ប្ដីខ្ញុំមិនឃើញមក?» យូរក្រោយមកទើបមានអ្នកខ្សឹបប្រាប់ខ្ញុំថា ប្ដីខ្ញុំត្រូវអង្គការសម្លាប់ចោលហើយ ។ អ្នកប្រាប់ខ្ញុំឈ្មោះ ចឹកហ៊ុយ (ហេង ហ៊ុយ) ដែលទៅកាប់រពាក់ជាមួយប្ដីខ្ញុំ ។ ពេលដែល ចឹកហ៊ុយ ត្រឡប់មកវិញ មេកងបានហាមគាត់មិនឲ្យប្រាប់ខ្ញុំពីរឿងប្ដីខ្ញុំត្រូវសម្លាប់ទេ គាត់ឲ្យ ចឹកហ៊ុយ ប្រាប់ខ្ញុំថា ប្ដីខ្ញុំត្រូវមេកងបញ្ជូនទៅកាប់រំពាក់បន្តទៀត ។ ចឹកហ៊ុយ មិនដឹងថាប្ដីខ្ញុំត្រូវសម្លាប់នៅកន្លែងណាទេ ។ គាត់និយាយថា គាត់ទៅជាមួយប្ដីខ្ញុំពិតមែន ប៉ុន្តែគាត់មកផ្ទះមុន ។ គាត់និយាយថា ប្ដីខ្ញុំត្រូវបញ្ជូនទៅកន្លែងផ្សេងដែលគាត់មិនដឹងថាមានរឿងអ្វីកើតឡើង ។ ទើបតែក្រោយមកទេ ដែល ចឹកហ៊ុយ ដឹងថាប្ដីខ្ញុំប្រហែលជាត្រូវអង្គការសម្លាប់ ។ ខ្ញុំសន្និដ្ឋានថាគាត់ត្រូវសម្លាប់ចោលហើយ ព្រោះគាត់ទៅបាត់យូរណាស់ហើយ ពេលនោះខ្ញុំពុថាអង្គការសម្លាប់ជនជាតិវៀតណាម ។*

*ខ្ញុំរង់ចាំគាត់ត្រឡប់មកវិញទាំងអន្ទះសា ។ អស់រយៈពេលយូរក្រោយមកមានអ្នកប្រាប់ខ្ញុំថា អង្គការសម្លាប់ជនជាតិវៀតណាម ដូច្នេះប្ដីខ្ញុំគ្មានសង្ឃឹមថារស់ទេ ។ ខ្ញុំមិនហ៊ានយំនៅមុខគេឡើយ ព្រោះខ្ញុំខ្លាចអង្គការហៅទៅរៀនសូត្រដែរ ។*

*ពេលមកដល់ផ្ទះវិញខ្ញុំមានអារម្មណ៍ណែនក្នុងទ្រូងណាស់ ។ ខ្ញុំឃើញអ្នកដទៃជួបជុំគ្រួសារ ចំណែកខ្ញុំអត់មានប្ដី ។ គួរឲ្យអាណិតណាស់ កាលដែលគាត់ចេញដំណើរទៅ គាត់មានតែខោអាវមួយកំប្លេដែលពាក់ជាប់នឹងខ្លួនប៉ុណ្ណោះ ។*

*ប្រហែលមួយឆ្នាំក្រោយមក មានអង្គប្រជុំដ៏ធំមួយនៅឃុំ*

ស្វាយអន្ទរ ។ ក្នុងអង្គប្រជុំនោះ មានមនុស្សច្រើនណាស់គឺមកពីឃុំស្វាយអន្ទរទាំងមូលតែម្តង ។ អង្គប្រជុំនោះធំរហូតដល់ត្រូវប្រើមីក្រូហ្វូន ។ នៅក្នុងអង្គប្រជុំនោះ អង្គការប្រកាសអំពីការបញ្ជូនប្រជាជនទៅជីខ្វាញ់ ។ ខ្ញុំអត់មានឈ្មោះត្រូវទៅជីខ្វាញ់ទេ ប៉ុន្តែខ្ញុំសុំទៅហើយប្រធានភូមិក៏យល់ព្រម ។ ប្រជាជនរាប់រយនាក់ត្រូវបញ្ជូនទៅអ្នកលឿងដើម្បីឆ្លងទន្លេទៅភ្នំពេញ ។ ពេលយប់យើងទៅដល់ភ្នំពេញ ។ ពេលដែលយើងចុះពីលើកាណូតមានរថយន្តធំៗជាច្រើនចាំដឹកមនុស្ស ។ អង្គការបានចែកភួយ ថ្នាំពេទ្យ អង្ករ ត្រីចំហុយ ទឹកត្រី ខោអាវខ្មៅ និងក្រមា ។ បន្ទាប់ពីចែករបស់របររួចហើយ យើងឡើងជិះឡានបន្ទាប់មកជិះរថភ្លើងបន្តទៀត ។ ពេញមួយយប់នៅលើរថភ្លើង យើងអត់បានដេកមួយស្រឡេតសោះ ។

ទៅដល់ចំណតរថភ្លើងនៅពោធិសាត់ មានអ្នកឆែកឆេរ ហើយយកអីវ៉ាន់របស់យើងទៅដាក់ម្ដុំ សូម្បីតែកាំបិត កន្ត្រៃឬខោអាវ ។ បន្ទាប់មកយើងត្រូវបែងចែកតាមកង ។ ខ្ញុំជាស្ត្រីមេម៉ាយ ដូច្នេះខ្ញុំនៅក្នុងកងមេម៉ាយ ។ យុវជនយុវនារីពេញកម្លាំងត្រូវធ្វើការនៅក្នុងកងទី១ ចំណែកខ្ញុំនៅក្នុងកងទី២ដែលត្រូវរែកកណ្តាប់ ។

កូនៗរបស់ខ្ញុំនៅក្នុងកងកុមារប្រមូលអាចម៍គោ ។ កាលនោះកូនប្រុសខ្ញុំ ង៉ុយ អាយុប្រហែល១០ឆ្នាំ ។ ពេលដែលខ្ញុំបែកវាយូរ ខ្ញុំចំណាំវាមិនបាន ។ វាមិនហ៊ានមកលេងនឹងខ្ញុំទេ ។ បើវាហ៊ានមក ច្បាស់ជាត្រូវមេកងដាក់ទោសដោយបង្អត់បាយមិនខាន ។ ខ្ញុំប្រាប់កូនខ្ញុំថា «កូនប្រុសម្តាយទ្រាំទៅកូន ត្រឡប់ទៅកងវិញទៅ» ។ កូនប្រុសខ្ញុំចង់ដេកនៅផ្ទះមួយយប់ ប៉ុន្តែមេកងរបស់វាមិនអនុញ្ញាត ។ បើវាហ៊ានជម្នះនៅពេលត្រឡប់ទៅវិញ វានឹងត្រូវគេវាយធ្ងន់ធ្ងរ ។ ខ្ញុំអាណិតកូនខ្ញុំណាស់ ។

ខ្ញុំត្រូវមេកងចាត់តាំងឲ្យច្រូតស្រូវ ប៉ុន្តែខ្ញុំធ្វើមិនកើត ព្រោះស្រូវនៅក្នុងទឹកជម្រៅត្រឹមកមនុស្សដែលមានកម្ពស់ខ្ពស់ ចំណែកខ្ញុំទាបពេកមិនអាចចុះក្នុងទឹកនោះបានទេ ។ មេកងក៏ឲ្យខ្ញុំប្រមូលកណ្តាប់ស្រូវនៅកន្លែងណាគោកៗវិញ ។ ក្រៅពីនេះខ្ញុំត្រូវរកត្រីសម្រាប់ផ្គត់ផ្គង់ក្រុមច្រូតទៀត ។ ពេលទៅដល់ជីខ្វាញ់ដំបូងខ្ញុំបានហូបឆ្អែត ព្រោះខ្ញុំជាអ្នករកត្រី ប៉ុន្តែក្រោយៗមកខ្ញុំបានរបបបាយតែបីវែកប៉ុណ្ណោះ ។ ទោះជាគេឲ្យប៉ុន្មានក៏ដោយ ខ្ញុំត្រូវតែទ្រាំ ។ សូម្បីតែពេលកូនខ្ញុំឈឺក៏ខ្ញុំមិនហ៊ានសុំច្បាប់ឈប់ដែរ ខ្ញុំខ្លាចត្រូវអង្គការយកទៅសម្លាប់ ។ កម្មាភិបាលខ្មែរក្រហមមិនដែលធ្វើអីខ្ញុំទេ ប៉ុន្តែខ្ញុំនៅតែខ្លាច ។ តាំងពីថ្ងៃទីមួយដែលខ្ញុំមកដល់ជីខ្វាញ់ មេកងហៅប្រជាជនទៅប្រជុំរាល់ថ្ងៃ ។ អង្គប្រជុំនិយាយតែអំពីខ្មាំងយួន និងជំរុញឲ្យធ្វើការងារឲ្យបានសកម្ម ហាមប្រាមមិនឲ្យមើលខិត្តប័ណ្ណដែលបាចពីលើយន្តហោះមក ។ កម្មាភិបាលថែមទាំងហាមប្រាមប្រជាជនកុំឲ្យជឿការឃោសនារបស់ខ្មាំង ប្រយ័ត្នខ្មាំងវះពោះច្រកស្មៅ ។ ប្រជុំជីវភាពធ្វើរៀងរាល់ល្ងាច ហើយប្រជុំសហករណ៍រៀងរាល់បីថ្ងៃម្តង ។ នៅក្នុងអង្គប្រជុំប្រធានសហករណ៍ប្រាប់អ្នកផ្សេងឲ្យយកតម្រាប់តាមខ្ញុំដែលខំធ្វើការងារមិនដែលសម្រាកតាំងពីមកដល់ទីនេះ ។

ខ្ញុំរស់នៅជីខ្វាញ់ប្រហែលបីខែមុនរបបខ្មែរក្រហមដួលរលំ ។ មិនយូរប៉ុន្មានមុនពេលរបបនេះដួលរលំ យើងឃើញយន្តហោះហោះពីលើក្បាលហើយទម្លាក់ខិត្តប័ណ្ណចុះមក ។ ខ្ញុំអត់ចេះអក្សរទេ ដូច្នេះខ្ញុំពឹងអ្នកផ្សេងអានឲ្យស្តាប់ស្ងាត់ៗ ។ បើខ្មែរក្រហមឃើញយើងអាន យើងពិតជាមានបញ្ហាធំ ។ ប្រជាជនមួយចំនួនដែលខ្មែរក្រហមឃើញកំពុងតែអានខិត្តប័ណ្ណ ត្រូវខ្មែរក្រហមវាយធ្វើបាប ។ ខិត្តប័ណ្ណនោះសរសេរថា «សូមបងប្អូនកុំព្រួយមិនយូរទេ អ្នកទាំងអស់គ្នានឹងត្រូវបានរំដោះនិងបានត្រឡប់ទៅស្រុកកំណើតវិញ» ។ នៅពេលយប់យើងមិន ហ៊ាននិយាយគ្នាអំពីរឿងនេះទេ ។ សូម្បីតែកូនខ្ញុំយំក៏មិនបានដែរ ។

មុនពេលចូលឆ្នាំថ្មី អង្គការប្រាប់ឲ្យខ្ញុំត្រឡប់ទៅវិញ ។ អ្នកណាដែលមានមាសសេសសល់ខ្លះអាចជិះឡាន ចំណែកខ្ញុំត្រូវដើររហូតដោយទូលឆ្នាំងបាយនិងស្បោងខោអាវនៅលើក្បាលនិងស្ពាយកូននៅលើខ្នង ។ នៅតាមផ្លូវ ខ្ញុំដាំបាយមួយឆ្នាំងឲ្យកូនប្រុសខ្ញុំទូល ហើយប្រាប់វាឲ្យហូបពេលឈប់សម្រាក ។ យប់ណាដែលមានខែភ្លឺ យើងត្រូវតែក្រោកពីយប់ងងឹតដើម្បីដើរបន្តទៅទៀត ។

ខ្ញុំតែងតែគិតអំពីប្តីរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងជាត្រូវធ្វើយ៉ាងម៉េច ។ ពេលវេលាកន្លងយូរៗទៅ ការនឹកគាត់ក៏រសាយបន្តិចម្តងៗ ។ នៅពេលមានពិធីបុណ្យម្តងៗ ខ្ញុំតែងតែឧទ្ទិសកុសលជូនគាត់ ប៉ុន្តែខ្ញុំគ្មានលទ្ធភាពធ្វើបុណ្យឲ្យបានធំដុំទេ ព្រោះខ្ញុំក្រ ។ ខ្ញុំគ្មានសូម្បីតែផ្ទះសម្រាប់រស់នៅ ។ ពីមុនខ្ញុំរស់នៅលើដីនេះ

ជាមួយបងជីដូនមួយសាច់ថ្លៃឈ្មោះ ចេក សាក់ ។ ពេលដែលខ្ញុំត្រឡប់មកពីជីខ្លាញ់វិញ ដីរបស់ខ្ញុំត្រូវអ្នកផ្សេងកាន់កាប់ ហើយខ្ញុំក៏មិនរវីរវល់ដែរ ។ ឥឡូវនេះខ្ញុំអត់មានផ្ទះនៅទេ ខ្ញុំរស់នៅជាមួយអ្នកដទៃ ។ ព្រឹកឡើងខ្ញុំចេញពីផ្ទះទៅធ្វើម្ហូបទៅ ។

ឥឡូវនេះកូនប្រុសរបស់ខ្ញុំអាយុ៣០ឆ្នាំ ។ វាកើតឆ្នាំច ។ កូនប្រុសម្នាក់នេះដូចឪពុកវាណាស់ ដូចតាំងពីដំណើរ ។ វាស្គមស ទាប សក់ស្កួត ទម្រង់មុខវៀតណាមដូចឪពុករបស់វាអ៊ីចឹង ។ កូនៗរបស់វាទាំងអស់ស្អាតៗគួរឲ្យស្រលាញ់ណាស់ សក់ក្រហមៗ ។ ពួកវាសម្បុរសដូចជីតាវាអ៊ីចឹង ។ គ្រួសារខាងប្តីខ្ញុំស្លាប់អស់ហើយ ។

បើប្តីខ្ញុំនៅរស់ម៉្លេះសមខ្ញុំសប្បាយចិត្តយ៉ាងណាទេ ។ បើគាត់នៅរស់ខ្ញុំមិនពិបាកអត់ផ្ទះនៅដូចសព្វថ្ងៃនេះទេ ។ គាត់ស្រលាញ់ខ្ញុំណាស់ មិនដែលឲ្យខ្ញុំធ្វើអីទេ ។ កាលលក់ត្រី គាត់លក់តែម្នាក់ឯង អត់ឲ្យខ្ញុំទៅលក់ទេ ។ គាត់និយាយថាគាត់ត្រូវតែថែរក្សាកូនៗឲ្យបានល្អ ។ គាត់ស្រលាញ់ប្រពន្ធកូនណាស់ ឲ្យតែឮកូនយំ គាត់មិនសប្បាយចិត្តទេ ។ គាត់ធ្វើការទាំងអស់តែម្នាក់ឯងតាំងពីដាំស្ល ។ ពេលមានភ្ញៀវមកលេងផ្ទះ គាត់មិនឲ្យខ្ញុំដាំស្លទេ ។ ពេលខ្ញុំកូនខ្ចីគាត់ថែរក្សាខ្ញុំបានល្អណាស់ ។ គាត់ពូកែធ្វើម្ហូបបំផុត ។ ជនជាតិវៀតណាមពូកែធ្វើម្ហូបនិងរៀបចំផ្ទះណាស់ ។ នឹកដល់រឿងនេះ ខ្ញុំនឹកឃើញរឿងកាលពីមុនទាំងអស់ ប៉ុន្តែឥឡូវនេះខ្ញុំមិនដឹងជាត្រូវធ្វើយ៉ាងម៉េចទេ មានតែខំប្រឹងបំភ្លេចទៅ ។

### *ហេង ហ៊ុយ អាយុ៤៩ឆ្នាំ (អ្នកដែលទៅកាប់រពាក់ជាមួយ ង៉ាង)*




ខ្ញុំត្រូវអង្គការបញ្ជូនទៅកាប់រពាក់ជាមួយ ហ៊ាង៉ាង និងបងអែល ។ កាប់បាន១ខែ មេភូមិឈ្មោះ សេង មកហៅឲ្យត្រឡប់ទៅផ្ទះវិញ ។ សេង រស់នៅភូមិពោធិជ្រៃ ។ ពេលដែលមេភូមិមកដល់ប្រហែលម៉ោង២រសៀល ហើយទាំងអស់គ្នាក៏ត្រឡប់មកវិញជាមួយគ្នា ។ ប្រហែលម៉ោង៣នៅត្រង់ផ្លូវបត់ទៅវត្តអូរកណ្តោល ខ្ញុំឃើញ ង៉ាង ដើរយឺតៗព្រោះគាត់មុតជើងជ្រៅណាស់ ដូច្នេះខ្ញុំក៏ឲ្យស្បែកជើងខ្ញុំទៅគាត់ពាក់ ។

ពេលដើរទៅដល់ផ្លូវបំបែក កង់របស់មេភូមិធ្លាក់ច្រវាក់ ។ ខ្ញុំក៏និយាយថា “មិត្តបង ចាំខ្ញុំជួយដាក់ឲ្យវិញ” ។ ពេលដាក់ច្រវាក់កង់រួចហើយ សេង និយាយថា “ឯងទៅមុនចុះ” ។ ពេលងើបដើរទៅ ខ្ញុំដើរលឿនជាង បងង៉ាង ហើយហួសគាត់មួយផ្លូវបត់ ។ កន្លែងនោះសុទ្ធតែព្រៃ ។ ខ្ញុំនិង បងអែល ដើរលឿនជាង ហើយទៅចាំគាត់នៅខាងមុខ ។ ចាំយូរពេក បងអែល និយាយថា “តោះទៅមុនទៀត” ។ មកដល់ភូមិវិញខ្ញុំចាំគាត់កាន់តែយូរទៅៗ ។ ខ្ញុំនិយាយជាមួយ បងអែល ថា “តោះទៅផ្ទះសិនទៅ” ។ ខ្ញុំបន្តទៅភូមិអូរកណ្តោល ។ ពេលមកដល់ភូមិនេះខ្ញុំឮប្រជាជននិយាយថាអង្គការសម្លាប់ជនជាតិវៀតណាម ។ កាលនោះខ្ញុំមិនមាត់ទេ ព្រោះបើហ៊ានតែនិយាយច្បាស់ជាមានបញ្ហាហើយ ។ ខ្ញុំនៅស្ងៀមតាំងពីពេលនោះមក ។ មានតែប៉ុណ្ណឹង ។

អង្គការមិនបញ្ជូនយើងទៅកាប់រពាក់ទៀតទេ ហើយក៏មិនឃើញរពាក់ដែលកាប់រួចហើយនោះដឹកមកដល់ភូមិដែរ ។ តាមធម្មតារពាក់គួរតែដឹកមកភូមិអូរកណ្តោលដើម្បីធ្វើបង្គី ប៉ុន្តែវាបែរជាត្រូវទុកចោលនៅក្នុងព្រៃ ។ ខ្ញុំមិនហ៊ានសួរមេភូមិអំពី ង៉ាង ទេ ។ បន្ទាប់ពីទៅកាប់រពាក់ហើយគ្មានការប្រជុំនៅក្នុងភូមិទេ ហើយក៏គ្មានផែនការថ្មីដែរ ។ ខ្ញុំត្រូវចាត់តាំងឲ្យបររទេះដឹកជីយកទៅដាក់ស្រែ ។

ពេលខ្ញុំមកដល់ភូមិ ប្រពន្ធរបស់ ហ៊ាង៉ាង សួរខ្ញុំថា “បងមានឃើញឪអាង៉ុយទេ?” ខ្ញុំប្រាប់គាត់ថា “បងង៉ាង កំពុងតែដើរមកហើយ គាត់ឈឺជើងបានជាដើរមិនទាន់ខ្ញុំ” ។ គាត់ក៏នៅស្ងៀមទៅ ។ បាត់មួយយប់គាត់ដឹងថា បងង៉ាង ត្រូវអង្គការសម្លាប់ចោលហើយ ។ គាត់លែងហ៊ានសួរខ្ញុំតទៅទៀត ហើយក៏មិនហ៊ានមកលេងផ្ទះខ្ញុំទៀតដែរ ។ គាត់ប្រហែលជាដឹងថា យួននៅក្នុងភូមិត្រូវអង្គការប្រមូលយកទៅសម្លាប់ទាំងអស់ ។

ខ្ញុំមិនដឹងពីមូលហេតុនៃការសម្លាប់នេះទេ ។ ខ្ញុំគ្រាន់តែឮថា កូនដែលមានម្តាយជាជនជាតិវៀតណាមនឹងត្រូវយកទៅសម្លាប់ជាមួយម្តាយ ប៉ុន្តែបើមានឪពុកជាជនជាតិវៀតណាមវិញមានតែឪពុកប៉ុណ្ណោះដែលត្រូវសម្លាប់ ។ ខ្ញុំឮប្រជាជននិយាយអ៊ីចឹង ។ មេភូមិមិនដែលនិយាយអំពីការយកប្រជាជនវៀតណាមទៅសម្លាប់ទេ ។ ខ្ញុំដឹងតែការសម្លាប់វៀតណាមបីនាក់តែប៉ុណ្ណោះ នៅក្នុងភូមិខ្ញុំគ្មានជនជាតិវៀតណាមទៀតទេ ។ **សឹម សុរិយ៉ា**

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ FM102MHz ទីក្រុងភ្នំពេញ វិទ្យុ FM93.25MHz ខេត្តកំពត វិទ្យុ FM99MHz ខេត្តព្រះវិហារ និងវិទ្យុFM ១០៣.២៥MHz ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកប្រសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះ ចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។


បាន សារឿន និងក្មួយៗ

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthwynne@dccam.org ឬ truthpivoine@dccam.org ។

សូមអរគុណ ។

# រួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ

ផ្ទះថ្មតូចមួយខ្នងសង់ប្រឈមមាត់ស្ទឹងសង្កែជិតព្រះវិហារ “នូរុលឥស្លាម” គឺជាផ្ទះរបស់ស្ត្រីមេម៉ាយមូស្លីមវ័យចំណាស់ម្នាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ គាត់ឈ្មោះ ម៉ាឡាស់ ហៅ អួម សីលា អាយុ៩២ឆ្នាំ រស់នៅភូមិសូភី២ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

## កុមារភាព




ម៉ាឡាស់ គឺជាកូនស្រីច្បងក្នុងចំណោមបងប្អូន៧នាក់ (ស្រី៤ ប្រុស៣) ។ ឪពុកម្តាយរបស់គាត់គឺជាកសិករ ។ ម៉ាឡាស់ រៀននៅសាលាបឋមសិក្សាខត្តរៈ ។ ក្រៅពីទៅរៀន គាត់នៅផ្ទះថែរក្សាប្អូនៗ ។ ឪពុករបស់ ម៉ាឡាស់ បានស្លាប់ដោយសារជំងឺនៅពេលដែល ម៉ាឡាស់ មានអាយុ១០ឆ្នាំ ។ ដោយអត់ពីប្តីទៅ ម្តាយរបស់ ម៉ាឡាស់ មិនអាចរ៉ាប់រងការងារស្រែចម្ការតែម្នាក់ឯងបាន គាត់ក៏ជួលដីស្រែឲ្យអ្នកផ្សេងធ្វើ ហើយខ្លួនគាត់ប្រកបរបរដុលសំណាញ់នៅឯផ្ទះ ។ ម៉ាឡាស់ តែងតែជួយម្តាយបញ្ចូលឈ្នុលសំណាញ់នៅពេលទំនេរ ។ ម្តាយរបស់គាត់ផ្លាស់ប្តូរមុខរបរជាញឹកញាប់ដើម្បីរកកម្រៃឲ្យបានគ្រប់ដើម្បីចិញ្ចឹមកូនទាំង៧នាក់ ។ ជួនកាលម្តាយរបស់គាត់មកសុីឈ្នួលលាងចានឲ្យហាងបាយរបស់ជនជាតិចាមម្នាក់នៅផ្សារណាត់ ។ ដោយសារកម្រៃដែលរកបានបន្តិចបន្តួចមិនសមល្មមនឹងការចំណាយប្រចាំថ្ងៃ ម្តាយគាត់ក៏លក់ស្រែយកលុយមកបើកហាងលក់បាយមួយនៅផ្សារ ។ ម៉ាឡាស់ ទៅរៀនផង ជួយលក់បាយផង ។ នៅពេលមានអាយុ១៤ឆ្នាំ ម៉ាឡាស់ ឈប់រៀនត្រឹមថ្នាក់ទី៥ ហើយនាំក្រុមគ្រួសារមកជួលផ្ទះរស់នៅជិតផ្សារ ដោយបិទទ្វារផ្ទះនៅភូមិ ។

## អាពាហ៍ពិពាហ៍ជាមួយបុរសក្រៅសាសន៍

នៅឆ្នាំ១៩៧០ បុរសម្នាក់ជាកូនខ្មែរកាត់ចិនឈ្មោះ យុង ហេងគឹមលី មានកំណើតនៅស្រុកបវេល ដែលមកជួយលក់គុទូជាមួយបងរបស់គាត់នៅផ្សារ បានចាប់ចិត្តស្រលាញ់ ម៉ាឡាស់ ហើយឲ្យឪពុកម្តាយចូលស្តីដណ្តឹង ។ ម្តាយរបស់ ម៉ាឡាស់ មិនយល់ទាស់នឹងអាពាហ៍ពិពាហ៍នេះទេ ប្រសិនបើ គឹមលី ព្រមចូលសាសនាឥស្លាមនិងព្រមគោរពប្រតិបត្តិប្រពៃណីសាសនាឥស្លាម ។ គឹមលី ក៏យល់ព្រម អ្នកទាំងពីរបានរៀបការតាមប្រពៃណីឥស្លាមក្នុងឆ្នាំដដែល ហើយ ម៉ាឡាស់ នៅតែប្រកបរបរលក់បាយដូចធម្មតា ។ គឹមលី បានធ្វើជាអ្នកយកពត៌មានឲ្យកាសែតកោះសន្តិភាពតាមការបបួលរបស់មិត្តភក្តិម្នាក់ឈ្មោះ យុន ។ បន្ទាប់ពីមានកូនស្រីម្នាក់ ម៉ាឡាស់ ឈប់លក់បាយដោយសារមិនមានប្រាក់ចំណេញសោះ ព្រោះពេលនោះទាហានលន់នល់ដែលមកហូបបាយចេះតែជំពាក់ ម្យ៉ាងទៀតគាត់ត្រូវបង់ថ្លៃភាស៊ីនិងចំណាយឈ្នួលពលកម្មសម្រាប់កម្មករច្រើនផង ។ ក្រុមគ្រួសាររបស់ ម៉ាឡាស់ លក់ហាងបាយហើយត្រឡប់ទៅរស់នៅភូមិសូភី២វិញ ។

## ជម្លៀសចេញពីភូមិ

រស់នៅក្នុងភូមិបានកន្លះឆ្នាំ ម៉ាឡាស់ ប្រសូត្របានកូនប្រុសម្នាក់នៅឆ្នាំ១៩៧៥ ។ ថ្ងៃមួយក្នុងឆ្នាំដដែល ពេលកំពុងតែដាំបាយពេលថ្ងៃ ម៉ាឡាស់ ឮអ្នកភូមិស្រែកប្រាប់គ្នាថាខ្មែរក្រហមចូលមកហើយ ។ ពេលនោះទាហានលន់នល់កំពុងតែបាក់ទ័ពរត់ចូលមកក្នុងភូមិ អ្នកខ្លះគ្មានអាវ អ្នកខ្លះមានតែខោខ្លី រត់បណ្តើរស្រែកប្រាប់អ្នកភូមិបណ្តើរឲ្យប្រយ័ត្នខ្លួន ។ ម៉ាឡាស់ ប្រាប់ថាទាហានទាំងនោះមួយចំនួនត្រូវខ្មែរក្រហមសម្លាប់ និងមួយចំនួនទៀតត្រូវខ្មែរក្រហមចាប់បាន ប៉ុន្តែមិនដឹងនាំយកទៅទីណា ។ ពេលនោះ ប្រជាជនជ្រួលច្របល់រត់ចោលផ្ទះសម្បែងរបស់របរ ។ ម៉ាឡាស់ នាំកូនរត់ចោលឆ្នាំងបាយដែលកំពុងតែដាំនៅលើចង្ក្រាន ។ រហូតដល់ខ្មែរក្រហមដកថយទៅវិញអស់ទើបប្រជាជនហ៊ានវិលចូលផ្ទះសម្បែងវិញ ។

ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជននៅទីប្រជុំជនផ្សារណាត់ទៅកាន់តំបន់ជនបទ ។ ប៉ុន្មានថ្ងៃក្រោយមក ការជម្លៀសបានមកដល់ភូមិសូភី២ ។ មុនដំបូង ម៉ាឡាស់ ឆ្ងល់នឹងការជម្លៀស

អ្នកផ្សារ លុះដល់វេនរបស់គាត់ត្រូវជម្លៀសដែរ គាត់និយាយមិនចេញ ។ គាត់រៀបរាប់ថា “ដំបូងគេឲ្យអ្នកផ្សារចេញមុន ។ ខ្ញុំសួរគេថា ទៅណាមកណា? គេនិយាយថា ចេញឆ្ងាយពីក្រុងបីគីឡូម៉ែត្រ ។ យើងគិតថាបើគេជម្លៀសចេញពីផ្សារបីគីឡូ ភូមិដែលយើងកំពុងតែនៅនេះផុតហើយ ។ រំលងបានប្រហែល ៥ថ្ងៃដល់ខ្លួនយើងរកទឹកភ្នែកយំក៏គ្មានដែរ ។ ដូចថារន្ធត់ណាស់ មិនដែលជួបប្រទះ ។ ទាំងម្តាយទាំងប្តីអីនឹកស្មានមិនដល់ ។ យើងនៅឆ្ងាយហើយគេឲ្យយើងចេញមិនឲ្យយកអ្វីទៅជាមួយទៀត ឲ្យចេញតែមួយខ្លួនៗណាស់ ។ យកតែខោអាវរុំឲ្យកូន ហើយនិងខោអាវ៤-៥កំប្លេហ្នឹងឯងក៏ទៅរហូតលែងចូលមកភូមិវិញបាន ។ គេប្រកាសថាឲ្យប្រជាជនចេញតែ៣ថ្ងៃទេ ក្រោយពីបោសសម្អាតខ្មាំងហើយនឹងឲ្យត្រឡប់ចូលភូមិវិញ” ។ ចេះតែចាំថ្ងៃនេះថ្ងៃនោះ ចាំបាត់ៗ ។ មានតែអ្នកទៅអត់មានអ្នកត្រឡប់មកភូមិវិញទេ” ។

## លាក់ប្រវត្តិ

ប្តីរបស់ ម៉ាឡាស់ បារម្ភអំពីប្រវត្តិតួនាទីរបស់គាត់ជាអ្នកកាសែតនៅក្នុងរបបមុន ម្យ៉ាងទៀត គាត់បានឮពាក្យចចាមអារ៉ាមអំពីការបោសសម្អាតអ្នករដ្ឋការក្នុងរបបលន់នល់និងអំពីការចាប់ខ្លួន អឿ គឹមថន នាយទាហានស័ក្តិ៥របបលន់នល់ យកទៅសម្លាប់ចោល ។ គាត់ហាមមនុស្សក្នុងគ្រួសារកុំឲ្យនិយាយអ្វីដែលពាក់ព័ន្ធនឹងការងាររបស់គាត់ និងកុំឲ្យទៅកន្លែងណាដែលមានមនុស្សធ្លាប់ស្គាល់ ។

ម៉ាឡាស់ សម្រេចចិត្តធ្វើដំណើរទៅឃុំតាប៉ុន ព្រោះទីនោះមានជនជាតិមូស្លីមរស់នៅច្រើន ។ ម៉ាឡាស់ ដាំបាយនឹងអង្ករដែលយកទៅតាមខ្លួន ។ បានតែបីថ្ងៃអង្ករក៏អស់ ។ គាត់និយាយថា៖ “ដល់អស់អង្ករទៅចាប់ផ្តើមឡេឡា ហើយមានអ្នកលក់អង្ករមួយតៅប៉ុន្មានក៏ទិញដែរ ។ ដល់រួចទៅគេថា ពុកម៉ែនៅឲ្យស្ងៀមមួយដុំ កុំទៅណាមកណា ចាំគេបើរបបឲ្យ” ។ ម៉ាឡាស់ យកមាសទៅដូរអង្ករយកមកហូប ។ មាស១ជីដូរបានតែអង្ករ១តៅ ។ ម៉ាឡាស់ និយាយថា ពេលភ្ញាមៗនោះទំនិញគ្រប់មុខឡើងកប់ពពក ហើយម្នាក់ៗត្រូវតែនាំគ្នាទិញទុកហូប ។ អ្នកដែលមានរបស់លក់ត្រេកអរណាស់ព្រោះបានលុយច្រើន ប៉ុន្តែក្រោយមកលុយទាំងនោះមិនត្រូវបានចរាចរឡើយ ។ ឆ្នាំ១៩៧៦ ម៉ាឡាស់ ត្រូវជម្លៀសទៅភូមិអូរមុនី ។ ម៉ាឡាស់ ត្រូវអង្គការចាត់តាំងឲ្យទៅច្រូតស្រូវនៅជិតវត្តអូរមុនីរយៈពេល១០ថ្ងៃទើបបានត្រឡប់មកភូមិម្តង ។ ម៉ាឡាស់ ស្នាក់នៅក្នុងវត្តអូរមុនីជាមួយកងនារីដែលទៅជាមួយ ។ កូនៗរបស់គាត់ទុកឲ្យយាយចាស់ៗមើលនៅមណ្ឌលកុមារ ។

## ព្រាត់ប្តី

នៅក្នុងឆ្នាំ១៩៧៧ គឹមលី ត្រូវអង្គការចាត់តាំងឲ្យទៅភ្ជួរស្រែនិងរកត្រីនៅព្រៃនាម ។ រយៈពេល១ខែទើប គឹមលី បានមកសួរសុខទុក្ខក្រុមគ្រួសារម្តង ។ មុនពេលដែលប្តីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ ម៉ាឡាស់ មានប្រផ្នូលមិនស្រួលសោះ ប៉ុន្តែគាត់មិនបានចាប់អារម្មណ៍ ។ ក្រោយមកមានបុរសម្នាក់ឈ្មោះ ហឿប បានលួចខ្សឹបប្រាប់ ម៉ាឡាស់ ថា គាត់បានឃើញដោយផ្ទាល់ភ្នែក ខ្មែរក្រហមវាយសម្លាប់បុរសទាំង៨នាក់ ក្នុងនោះមានប្តីរបស់ ម៉ាឡាស់ ដែរ ទម្លាក់ចូលក្នុងរណ្តៅខណៈពេលដែលគាត់ទៅដឹកត្រីនៅព្រៃនាមដែលនៅជិតកន្លែងធ្វើការរបស់បុរសទាំង៨នាក់ ។ ហឿប បន្ថែមថា ប្តីរបស់ ម៉ាឡាស់ ត្រូវខ្មែរក្រហមសម្លាប់ក្រោយគេដោយវាយនឹងសសរបួនជ្រុងប៉ុនកំភួនជើង ហើយកប់ក្នុងរណ្តៅរួមគ្នានៅក្បែរដើមអំពិល ។ គ្រាន់តែទទួលដំណឹងនេះភ្លាម ម៉ាឡាស់ ដួលសន្លប់ទៅនឹងដី ។ ហឿប បានជួយឲ្យគាត់ដឹងខ្លួនឡើងវិញនិងប្រាប់គាត់ឲ្យកាត់ចិត្ត ។

## ស្ត្រីមេម៉ាយកូនពីរនាក់

ក្រោយពីប្តីស្លាប់ទៅ ម៉ាឡាស់ ត្រូវជម្លៀសទៅបឹងត្របែកដែលនៅឆ្ងាយពីអូរមុនីហើយត្រូវធ្វើដំណើរពេញមួយយប់ ។ ម៉ាឡាស់ ធ្វើខ្ទមស្នាក់នៅទីនោះជាមួយកូនពីរនាក់ ។ នៅពេលយប់គាត់ឮសូរសត្វឃ្មុំនិងសម្រឹបពស់វារលើស្មៅ គាត់ភ័យខ្លាចខ្លាំងណាស់ ។ អ៊ំស្រីម្នាក់ដែលជាអ្នកជិតខាងបានប្រាប់ឲ្យគាត់ពន្លត់ភ្លើងនិងយកដុំដីធំៗសង្កត់ជើងមុងឲ្យជាប់កុំឲ្យពស់ចូលបាន ។

រយៈពេល៥ថ្ងៃក្រោយមក កូនប្រុសពៅរបស់ ម៉ាឡាស់ ចាប់ផ្តើមហើមខ្លួនមួយកំណាត់ត្រឹមចង្កេះចុះក្រោម ដោយសារគ្មានអាហារបរិភោគគ្រប់គ្រាន់ ហើយ ម៉ាឡាស់ ក៏មិនស្រួលសម្បូរទឹកដោះឲ្យកូនបៅទៀត ។

ម៉ាឡាស់ រំឭកឡើងវិញថា៖ «កូនខ្ញុំឈឺ ព្រោះវាហាលទឹកសន្សើម ហាលខ្យល់ ហាលថ្ងៃ ហើមជើងឡើងពោរ ។ ស្អែកឡើងខ្ញុំទៅប្រូតស្រូវ ។ នៅតាមផ្លូវ ពួកម៉ាកខ្ញុំឈ្មោះ សាមួន បានយកត្រីមកឲ្យកូនខ្ញុំមួយ ។ សាមួន ស្រែកប្រាប់ខ្ញុំថា "ខ្ញុំយកត្រីទៅដាក់នៅក្បាលចង្ក្រានឲ្យហើយ អាំងឲ្យអាអូនហូបទៅ" ។ ខ្ញុំថាអរគុណហើយ ។ មកដល់ផ្ទះខ្ញុំរកត្រីអត់ឃើញ ក៏ស្រែកសួរកូនប្រុសខ្ញុំថា អាអូនត្រីទៅណាហើយ? កូនខ្ញុំឆ្លើយថាវាហូបអស់ហើយ ។ ខ្ញុំសួរថា ម៉េចបានហូបត្រីឆៅ? វាថាឃ្លានណាស់ម៉ាក់ ។ ខ្ញុំស្រក់ទឹកភ្នែកអាណិតកូន» ។

ដោយឃើញជំងឺរបស់កូនប្រុសគាត់កាន់តែធ្ងន់ធ្ងរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ម៉ាឡាស់ បានសុំខ្ទឹកង់និងសុំអនុញ្ញាតពីមេកងទៅរកថ្នាំឲ្យកូននៅវេលាយប់ ។ មេកងបានអនុញ្ញាត ប៉ុន្តែដាក់លក្ខខណ្ឌឲ្យ ម៉ាឡាស់ វិលមកធ្វើការឲ្យទាន់ពេលព្រឹកស្អែកវិញ ។ ពេលព្រលប់ៗ ម៉ាឡាស់ ជិះកង់ដែលមានតែខ្នងដែកអត់មានកៅស៊ូ ឆ្ពោះទៅភូមិដែលគាត់រស់នៅពីមុន ។ នៅតាមផ្លូវដែលពោរពេញទៅដោយគ្រលុករដិបរដុប ម៉ាឡាស់ បន់ស្រន់ក្នុងចិត្តនិងនឹកដល់ព្រះអាឡាសូមកុំឲ្យគាត់ជួបនឹងឈ្លបខ្មែរក្រហមឲ្យសោះ ។ គាត់បានទៅដល់ភូមិអូរមុនី ហើយលួចចូលទៅគាស់ដំឡូងឈាមមាន់ដែលប្តីរបស់គាត់បានដាំកាលពីពេលដែលគាត់នៅមានជីវិតនៅឡើយ ។ គាត់បានយកដំឡូងទាំងនោះទៅដូរបានស្ករត្នោតបីគីឡូក្រាមយកមកឲ្យកូនរបស់គាត់ហូប ។ ជំងឺហើមរបស់កូនគាត់ក៏ថមថយវិញ ។ ប្រហែល១០ថ្ងៃក្រោយមកខ្មែរក្រហមបានឲ្យប្រជាជនត្រឡប់ទៅភូមិអូរមុនីវិញ ។ ពេលនោះគឺឆ្នាំ១៩៧៨ ។

សម្រាកនៅភូមិអូរមុនីបាន១០ថ្ងៃ ម៉ាឡាស់ ត្រូវអង្គការចាត់ឲ្យទៅដាំត្រសក់និងស្ពៃ ហើយនៅរដូវវស្សាចាប់ផ្តើមដកស្ទូង ។ ចុងឆ្នាំ១៩៧៨ ម៉ាឡាស់ ត្រូវខ្មែរក្រហមដឹកតាមរថយន្តទ្រុងទៅកាន់ភ្នំធិបដេដើម្បីធ្វើស្រែនៅទីនោះ ។

ថ្ងៃមួយជាថ្ងៃសម្រាក មិត្តភក្តិរបស់ ម៉ាឡាស់ បានមកបបួលគាត់ឡើងភ្នំធិបដេដើម្បីសុំអាហារពីយោធាដែលបោះជំរំនៅលើភ្នំ ។ ម៉ាឡាស់ ទៅជាមួយមិត្តភក្តិដោយផ្តែផ្តាំកូនរបស់គាត់ឲ្យមើលថែគ្នាកុំដើរទៅណាឆ្ងាយពីផ្ទះ ។

ម៉ាឡាស់ រំឭកហេតុការណ៍ពេលនោះថា «ពួកខ្ញុំនាំគ្នាទៅប្រហែល១០នាក់ ។ ឡើងដល់លើភ្នំ ឃើញយោធាអ្នកខ្លះកាន់ចាប៉ី ខ្លះវាយស្គរ គេនាំគ្នាសប្បាយណាស់ ។ គេសួរខ្ញុំថា "ម៉ែឯងមករកអី?" ខ្ញុំមកសុំបាយ ។ "ម៉េចឃ្លានបាយឬ?" បាយគេនោះសុទ្ធតែអង្ករម៉ាស៊ីនទាំងឆ្នាំងៗ គេឲ្យហូបមួយឆ្អែតៗ គេដាក់ត្រីងៀតឲ្យយើងហូប ។ ម្នាក់ៗហូបចង់ហល់ ។ ឃើញបាយនឹកដល់កូន សុំបាយគេ "កូនអើយសុំបាយបន្តិចមកយកទៅឲ្យកូនខ្ញុំនៅក្រោម" ។ ខ្ញុំដោះក្រមាពីក្បាលទៅខ្ចប់បាយបានប្រហែលពីរចាន ។ ដល់រួចហើយសុំអំពៅទៀត "កូនអើយសុំអំពៅ៤-៥ដើមមកយកទៅចែកបងប្អូននៅក្រោម" ។ គេអនុញ្ញាតឲ្យយើងយក ។ ខ្ញុំទើបតែចុះបានបន្តិច តាមផ្លូវទ្រេតៗអីចឹងណាស់ ស្រាប់តែរមៀលមកឯង ភ្ញាក់នឹងគេបាញ់កាំភ្លើង ។ មុនដំបូងស្មានតែគេហាត់រៀនបាញ់កាំភ្លើង មិនដឹងថាគេយកមនុស្សទៅសម្លាប់ចោលឯណា ។ គេដឹកប្រជាជនមកបីឡាន ។ ពេលប្រជាជនចុះពីលើឡានភ្លាម វាឲ្យឈរតម្រៀបជួរបែរមុខទៅខាងភ្នំធិបដេ ហើយវាបាញ់ផាប់ច្រើនណាស់ ។ ពួកមិត្តៗនៅលើភ្នំស្រែកថា "ម៉ែៗឡើងមកវិញគេបាញ់គ្នាហើយ" ។ ឮតែគេបាញ់គ្នា ខ្ញុំមិនដឹងទៅខាងណាទេ ព្រោះយើងទើបតែចុះបានប្រហែលមួយម៉ែត្រ ។ រអិលរូមកជាប់នៅពាក់កណ្តាលភ្នំ បុកនឹងដើមឈើត្រូវចង្កេះភីងចង់សន្លប់ ។ ដល់ពេលឮសូរកាំភ្លើងខ្លាំងភ័យគិតដល់កូន នឹកថាបែបងាប់អស់ហើយ ។ ខ្ញុំមកដល់ផ្ទះរកកូនអត់ឃើញ ស្រែកហៅផងយំផង គ្រវែងបាយគ្រវែងអំពៅចោលអស់ហើយ ។ កូនខ្ញុំប្រហែលឮសូរខ្ញុំស្រែកយំវាចេញមកថា "ម៉ាក់ៗខ្ញុំនៅឯណេះ" ដល់ទៅមើលឃើញកូននៅក្នុងត្បាល់ត្អៀងគ្របស្បូវពីរកណ្តាប ។ តាំងពីពេលនោះមករាងចាលអ្នកណាមកបបួលទៅណាក៏លែងទៅដែរ សុខចិត្តស៊ីអត់ស៊ីឃ្លានជាមួយកូន» ។

បន្ទាប់ពីហេតុការណ៍នោះមក មេកងក៏ប្រកាសឲ្យប្រជាជនរៀបចំអីវ៉ាន់រត់ទៅទិសខាងលិច ព្រោះកងទ័ពវៀតណាមកំពុងតែវាយលុកមកជិតដល់ហើយ ។ ម៉ាឡាស់ ក៏រៀបចំអីវ៉ាន់ហើយនាំកូនៗរត់តាមការឃោសនារបស់មេកង ។ គាត់ធ្វើដំណើរកាត់តាមព្រៃនាម ហើយបន្តបន្ទាប់មកទៀតចេះតែនាំគ្នារត់គេចដោយសារ

មេកងបំភ័យថា "យួនមកដល់ឥឡូវហើយ ប្រយ័ត្នយួនកាត់ក្បាលដាំតែអុង" ។ ប្រជាជនទាំងអស់គ្នារត់យកតែប្រាសអាយុរៀងៗខ្លួន ទីបំផុតអស់ស្បៀងអាហារសូម្បីតែទឹកក៏គ្មានហូប ។ ម៉ាឡាស់ និយាយថា "ដោយស្រេកទឹកខ្លាំងពេក ប្រជាជនដឹកទឹកនោមខ្លួនឯងនិងទឹកក្នុងថ្លុកក្នុងដានជើងក្របី" ។ នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានដេញតាមទាន់ហ្វូងប្រជាជន ហើយបានប្រាប់ឲ្យវិលត្រឡប់ទៅភូមិកំណើតវិញ ។

ដោយសារត្រឡប់ចូលមកភូមិក្រោយគេ ម៉ាឡាស់ គ្មានកន្លែងស្នាក់នៅ (ផ្ទះរបស់គាត់ត្រូវអ្នកដទៃយកជាកម្មសិទ្ធិ) ។ គាត់ក៏សុំសំយាបផ្ទះរបស់អ្នកជិតខាងដើម្បីស្នាក់នៅ និងលក់ដូរអីវ៉ាន់បន្តិចបន្តួចចិញ្ចឹមកូន ។ ក្រោយមកដោយឃើញអ្នកភូមិជាច្រើននាក់ទៅរត់ពន្ធទំនិញនៅព្រំប្រទល់កម្ពុជា-ថៃ ម៉ាឡាស់ ក៏ប្រថុយទៅដែរ ។ ជំនួញលើកទី១របស់គាត់ប្រព្រឹត្តទៅបានល្អ ប៉ុន្តែនៅលើកទី២គាត់ត្រូវចោរប្លន់អស់ហើយស្ទើរតែបាត់បង់ជីវិតទៀត ។ គាត់ឈប់ទៅជួញដូរនៅព្រំដែន ហើយលក់ដូរអីវ៉ាន់បន្តិចបន្តួចនៅក្នុងភូមិ ។

ក្រោយមកប្រហែលឆ្នាំ១៩៨០ ម៉ាឡាស់ ត្រូវបានអាជ្ញាធរភូមិសំណូមពរឲ្យធ្វើជាប្រធាននារីប្រចាំភូមិ ។ ម៉ាឡាស់ បានជាប់ឈ្មោះជានារី៥ល្អដោយសារគាត់បានធ្វើកិច្ចការជាច្រើនដែលជាប្រយោជន៍ដល់ភូមិរបស់គាត់ ។ គាត់បានបញ្ជូនកូនទាំងពីរទៅសាលារៀន ហើយនៅពេលដែលកូនប្រុសរបស់គាត់ធំ ម៉ាឡាស់ បានបញ្ជូនឲ្យចូលបម្រើកងទ័ព ។

នៅពេលរំឭកដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ម៉ាឡាស់ និយាយថា "ខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ ។ ខ្ញុំបាត់បង់ប្តីនិងបងប្អូនអស់ ។ គ្មានរបបណាលំបាកដូចជារបបខ្មែរក្រហមទេ ។ យើងមិនត្រូវឲ្យរបបហ្នឹងកើតឡើងម្តងទៀតទេ" ។

ជារឿយៗ ម៉ាឡាស់ រំឭករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ក្មួយៗនិងចៅៗរបស់គាត់ឲ្យបានដឹង ហើយអប់រំចៅៗកុំឲ្យយកគំរូតាមរបបនោះ ។ គាត់យល់ថា ការនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្រោមរបបខ្មែរក្រហមប្រាប់ដល់កូនចៅពិតជាមានសារសំខាន់ណាស់ ។

**សាន់ កល្យាណ និង សូ ហ្វារីណា**

# កម្មវិធីពិសេសតាមវិទ្យុ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅក្នុងខែសីហាឆ្នាំ២០០៥នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាក់ផ្សាយជាពិសេសនូវការអានសំណួរចម្លើយនៅក្នុងកូនសៀវភៅស្តីអំពី "ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម" ដែលបោះពុម្ពផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីការអានអត្ថបទដកស្រង់ចេញពីទស្សនាវដ្តី "ស្វែងរកការពិត" នៅតាមស្ថានីយ៍វិទ្យុដូចខាងក្រោម ÷

- ◆ វិទ្យុជាតិ AM៩១៨MHz ម៉ោង៦:១៥-៦:៣០ ព្រឹក ។
- ◆ វិទ្យុពត៌មានស្ត្រីកម្ពុជា FM១០២MHz ភ្នំពេញ ម៉ោង៧:៣០-៧:៤៥ល្ងាច ។
- ◆ វិទ្យុ FM១០០.៥MHz ក្រុងព្រះសីហនុ ម៉ោង ១១-១១:១៥ព្រឹក ។
- ◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត ម៉ោង៧:០០-៧:៣០ល្ងាច ។
- ◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ ម៉ោង៦:៣០-៧:០០ល្ងាច ។
- ◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង ម៉ោង ៣:០០-៣:៣០ រសៀល ។
- ◆ វិទ្យុ FM១០០.៥MHz ខេត្តសៀមរាប ម៉ោង ៩:០០-៩:១៥ល្ងាច ។
- ◆ វិទ្យុ FM១០០.៥MHz ខេត្តពោធិសាត់ ម៉ោង ១១:០០-១១:១៥ថ្ងៃ ។
- ◆ វិទ្យុ FM១០៣.៧៥Hz ខេត្តស្វាយរៀង ម៉ោង ៨:៣០-៨:៤៥ព្រឹក ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងអាចរួមចំណែកក្នុងការស្រាយបំភ្លឺចម្ងល់មួយចំនួនជុំវិញសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗខាងមុខនេះ ។

**ផាត រចនា និង លី សុផល**

# សិទ្ធិរបស់ជនជាប់ចោទ

## ១) *សេចក្តីផ្តើម*

*តុលាការមួយមិនអាចមានយុត្តិធម៌ទេប្រសិនបើតុលាការនេះមិនគោរពសិទ្ធិរបស់ជនជាប់ចោទដែលរួមមាន សិទ្ធិក្នុងការសន្មតទុកជាមុនថាគ្មានទោស (ដរាបណាមិនទាន់មានសាលក្រមស្ថាពរ) សិទ្ធិទទួលបានមេធាវី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌និងជាសាធារណៈ ។ ដោយសារតែគ្រប់ៗគ្នាអាចត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយដែលខ្លួនមិនបានប្រព្រឹត្ត ដូច្នេះសិទ្ធិរបស់ជនជាប់ចោទគឺមានសារសំខាន់នៅក្នុងសង្គមយុត្តិធម៌ ។*

*ក៏ប៉ុន្តែ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គំនិតដែលថា «ជនជាប់ចោទមានសិទ្ធិដូចអ្នកដទៃទៀតដរាបណាមិនទាន់មានសាលក្រមស្ថាពររបស់តុលាការ» ប្រហែលជាមិនត្រូវបានគេមើលឃើញថាមានសារសំខាន់នោះទេ ដោយសារអារម្មណ៍ខឹងសម្បារ ។ មនុស្សជាច្រើនមានអារម្មណ៍ថា អ្នកដែលត្រូវបានចោទប្រកាន់ថាជាជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យមិនសមនឹងបានទទួលឱកាសក្នុងការបញ្ចេញសំឡេងឡើយ ។*

*មុនពេលពិនិត្យមើលអំពីសិទ្ធិរបស់ជនជាប់ចោទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ យើងចាំបាច់ត្រូវពិចារណាអំពីមូលហេតុដែលសិទ្ធិទាំងនេះត្រូវបានគោរព ។*

### *ក) ហេតុអ្វីបានជាសិទ្ធិរបស់ជនជាប់ចោទមានសារសំខាន់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ?*

*ទាំងច្បាប់ក្នុងស្រុករបស់កម្ពុជានិងកតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* (ICCPR) *បានធានានូវសិទ្ធិមួយចំនួនសម្រាប់ជនជាប់ចោទ ។ ដូចគ្នានេះដែរ ច្បាប់ទាំងឡាយដែលគ្រប់គ្រងដំណើរការរបស់សាលាជំនុំជម្រះក្តីអន្តរជាតិនិងសាលាជំនុំជម្រះក្តីចម្រុះ មានខជាច្រើនចែងយ៉ាងច្បាស់អំពីសិទ្ធិរបស់ជនជាប់ចោទ ។ ក៏ប៉ុន្តែ ហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមដែលជាប់ចោទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវបានអនុញ្ញាតឲ្យការពារខ្លួននៅចំពោះមុខសាលាក្តីយុត្តិធម៌នៅពេលដែលមេដឹកនាំទាំងនោះបានខកខានក្នុងផ្តល់យុត្តិធម៌ដល់ប្រជាជនដែលរស់នៅក្រោមការត្រួតត្រារបស់ខ្លួន? ហេតុអ្វីបានជាយើងសន្មតទុកជាមុនថាជនជាប់ចោទទាំងនោះជាជនគ្មានទោសបើយើងទាំងអស់គ្នាជឿជាក់ថាអ្នកទាំងនោះជាសមាជិករបស់របបមួយដែលបានប្រព្រឹត្តអំពើឃោរឃៅហួសនឹងថ្លែង? ខាងក្រោមនេះជាមូលហេតុមួយចំនួនដែលបង្ហាញឲ្យឃើញថាហេតុអ្វីបានជាសិទ្ធិរបស់ជនជាប់ចោទមានសារសំខាន់ ជាពិសេសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។*

***ទីមួយ*** *សិទ្ធិរបស់ជនជាប់ចោទមានសារសំខាន់ក្នុងការកំណត់* ***ការពិត*** *។ បើទោះបីជាខ្មែរក្រហមពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះក៏ដោយ វាមិនទាន់ច្បាស់លាស់នៅឡើយទេថាជនជាប់ចោទណាមួយក្នុងចំណោមជនជាប់ចោទទាំងអស់ដែលនឹងត្រូវជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មទាំងនោះ ។ ប្រសិនបើយើងមិនផ្តល់ឱកាសដល់ជនជាប់ចោទដើម្បីការពារខ្លួននិងដើម្បីនិយាយតាមការយល់ឃើញរបស់ខ្លួនទេ នោះយើងនឹងមិនអាចរកឃើញថាតើឧក្រិដ្ឋកម្មអ្វីខ្លះបានកើតឡើង តើឧក្រិដ្ឋកម្មទាំងនោះកើតឡើងយ៉ាងដូចម្តេច និងថាតើអ្នកណាដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ។*

***ទីពីរ*** *សិទ្ធិរបស់ជនជាប់ចោទមានសារសំខាន់ណាស់ក្នុងការធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈ* ***ស្របច្បាប់*** *ទាំងនៅក្នុងនិងនៅក្រៅប្រទេសកម្ពុជា ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញលម្អៀងឬមិនយុត្តិធម៌ អង្គជំនុំជម្រះវិសាមញ្ញនេះនឹងត្រូវពិភពលោកទាំងមូលបដិសេធ ។ នៅក្នុងប្រទេសកម្ពុជា អង្គជំនុំជម្រះដែលមិនយុត្តិធម៌នឹងបណ្តាលឲ្យមានការសង្ស័យ ហើយការសង្ស័យនេះនឹងផ្តល់ឱកាសដល់ជនជាប់ចោទក្នុងការអះអាងថាខ្លួនជាមនុស្សបរិសុទ្ធមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះទេ ។ ក៏ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះមានយុត្តិធម៌ ជនជាប់ចោទនឹងទំនងជាទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្ត ។ ការទទួលស្គាល់នេះ*

អាចជួយព្យាបាលរបួសរបស់សង្គមដែរ ។ តាមរបៀបដូចគ្នានេះដែរ អង្គជំនុំជម្រះវិសាមញ្ញមួយដែលមានលក្ខណៈស្របច្បាប់ និងយុត្តិធម៌អាចផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ ដោយសារជនរងគ្រោះទាំងឡាយអាចមានអារម្មណ៍ជឿជាក់ថា បន្ទាប់ពីការត្រួតពិនិត្យភស្តុតាងយ៉ាងហ្មត់ចត់ អ្នកដែលត្រូវបានវិនិច្ឆ័យទោសពិតជាមនុស្សដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះមែន ។

***ជាចុងក្រោយ*** ការផ្តល់សិទ្ធិដល់ជនជាប់ចោទបានបង្ហាញអំពីការប្តេជ្ញាចិត្តរបស់សង្គមក្នុងការស្វែងរក***យុត្តិធម៌***ជាជាងការសងសឹក ។ តាមរយៈការផ្តល់សិទ្ធិទៅឲ្យមនុស្សគ្រប់ៗគ្នា ពលរដ្ឋទាំងឡាយអាចអះអាងថាពួកគេខុសពីឧក្រិដ្ឋជន ។ ការប្រព្រឹត្តអំពើល្មើសច្បាប់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនគឺជារឿងមិនត្រឹមត្រូវទេ ប៉ុន្តែការអនុវត្តច្បាប់ឲ្យបានស្មើភាពគ្នានិងដោយគ្មានការរើសអើងគឺជារឿងត្រឹមត្រូវ ។ ការបំពារបំពានច្បាប់ដើម្បីធ្វើបាបជនរងគ្រោះគឺជារឿងមិនត្រឹមត្រូវ ហើយការដាក់ទណ្ឌកម្មអ្នកដែលរកឃើញថាពិតជាមានកំហុសគឺជារឿងត្រឹមត្រូវ ។ បើទោះបីជាសាធារណជនបានស្រែកទាមទារការសងសឹកភ្លាមៗ ក៏នេះជាការទទួលខុសត្រូវរបស់តុលាការក្នុងការអនុវត្តច្បាប់ដោយប្រុងប្រយ័ត្ននិងក្នុងការប្រព្រឹត្តចំពោះជនជាប់ចោទទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញដូចជាពលរដ្ឋដែលគ្មានកំហុសដែរ ។

## ១) ប្រភពនៃសិទ្ធិរបស់ជនជាប់ចោទ

*សិទ្ធិរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញមានប្រភពមកពីច្បាប់សំខាន់ៗចំនួនបី ។ ប្រភពពីរដំបូងគឺជាច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសមាត្រា៣៣ដល់មាត្រា៣៥ នៃច្បាប់«ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» និងមាត្រា១២និងមាត្រា១៣នៃ«កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ។ ប្រភពទីបីគឺមាត្រា១៤និងមាត្រា១៥របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលចងកម្ពុជាឲ្យត្រូវតែអនុវត្តដោយសារកម្ពុជាបានចុះហត្ថលេខានិងផ្តល់សច្ចាប័នដល់កតិកាសញ្ញានេះ ។ ជាងនេះទៅទៀត ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញត្រូវតែគោរពតាមកតិកាសញ្ញានេះ ។*

*កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយគឺជាប្រភពច្បាប់សំខាន់បំផុតដែលគ្រប់គ្រងសិទ្ធិរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដោយសារថាកតិកាសញ្ញានេះបានចែងយ៉ាងពិស្តារអំពីសិទ្ធិរបស់ជនជាប់ចោទ ។ លើសពីនេះទៅទៀត សិទ្ធិដែលធានាដោយកតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបកស្រាយនិងបញ្ជាក់យ៉ាងច្បាស់នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ។*

*ក្រៅពីប្រភពទាំងនេះ សិទ្ធិទាំងនេះក៏ត្រូវបានចែងនៅក្នុងច្បាប់របស់កម្ពុជាស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ក៏ដូចជានៅក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។*

## ២) ការសន្មតទុកជាមុនថាគ្មានទោស

*មាត្រា១៤(២)របស់កតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានចែងថា «ជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវទទួលបាននូវសិទ្ធិក្នុងការសន្មតថាគ្មានទោសរហូតដល់ច្បាប់រកឃើញថាមានកំហុស ។»*

*ឃ្លាស្រដៀងគ្នានេះដែរមានចែងនៅក្នុងមាត្រា១៣(ក) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនិងមាត្រា៣៥នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។*

*ច្បាប់ព្រហ្មទណ្ឌអន្តរកាលមាត្រា២៥ស្តីអំពីការសន្មតជាមុនថាគ្មានទោស ក៏បានចែងថា «ជនសង្ស័យនិងជនជាប់ចោទទាំងអស់ត្រូវទទួលបាននូវផលប្រយោជន៍អំពីការសន្មតទុកជាមុនថាគ្មានទោសទាំងស្រុង ។»*

*សិទ្ធិក្នុងការសន្មតទុកជាមុនថាគ្មានទោសត្រូវបានបកស្រាយដូចខាងក្រោមនេះ ÷*

ក) ចៅក្រម ឬតុលាការដែលទទួលខុសត្រូវសំណុំរឿងព្រហ្មទណ្ឌត្រូវតែកាត់សេចក្តីឲ្យស្របទៅតាមគោលការណ៍សន្មតទុកជាមុនថាគ្មានទោស ។

ចៅក្រមទាំងអស់ត្រូវសន្មតនៅគ្រប់ដំណាក់កាលទាំងអស់នៃសវនាការព្រហ្មទណ្ឌថា ជនសង្ស័យនិងជនជាប់ចោទទាំងអស់ជាជនគ្មានទោសរហូតដល់រកឃើញថាមានកំហុស ។

ការសន្មតជាមុនថាគ្មានទោសអាចត្រូវបានរំលោភដោយចៅក្រមឬតុលាការ ប្រសិនបើបន្ទុកនៃការបង្ហាញភស្តុតាងធ្លាក់ទៅលើជនសង្ស័យឬជនជាប់ចោទនៅអំឡុងពេលសវនាការឬប្រសិនបើចៅក្រមឬតុលាការកំណត់ថាជនសង្ស័យឬជនជាប់ចោទមានទោសអំពីបទល្មើសណាមួយមុនពេលដែលរកឃើញថាជននោះមានទោស ។

ការបង្ហាញភស្តុតាងគឺជាបន្ទុករបស់ព្រះរាជអាជ្ញា ។ នៅក្នុងប្រទេសកម្ពុជា ព្រះរាជអាជ្ញាជាអ្នកបញ្ជូនទៅតុលាការនូវភស្តុតាងនៃបទល្មើសណាមួយដើម្បីបង្ហាញចៅក្រមអំពីកំហុសរបស់ជនជាប់ចោទណាម្នាក់ ។ នៅក្នុងករណីដែលនៅមានមន្ទិលសង្ស័យចំពោះភស្តុតាងណាមួយ ជនជាប់ចោទនោះត្រូវតែបានកំណត់ឲ្យរួចពីការចោទប្រកាន់តាមរយៈគោលការណ៍ «ជនជាប់ចោទជាអ្នកទទួលផលប្រយោជន៍នៃភាពមន្ទិលសង្ស័យ» ។ គួរឲ្យកត់សម្គាល់ថា យោបល់លេខ១៣របស់គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា «ភាពមានទោសមិនអាចត្រូវបានសន្មតជាមុនទេ រហូតដល់បទចោទប្រកាន់ជនជាប់ចោទណាម្នាក់ត្រូវបានបង្ហាញដោយឥតមានមន្ទិលសង្ស័យ ។»

ការសន្មតជាមុនថាគ្មានកំហុសនឹងត្រូវបានរំលោភនៅពេលណាដែលសេចក្តីសម្រេចរបស់តុលាការទាក់ទងនឹងបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយបានឆ្លុះបញ្ចាំងឲ្យឃើញគំនិតមួយថាបុគ្គលនោះមានកំហុសរួចទៅហើយមុនពេលដែលគាត់ត្រូវបានបង្ហាញតាមផ្លូវច្បាប់ថាពិតជាមានកំហុស ។

### ១) មន្ត្រីសាធារណៈមិនត្រូវសន្មតទុកជាមុនអំពីលទ្ធផលរបស់សវនាការ

មន្ត្រីសាធារណៈរួមមាន រដ្ឋមន្ត្រី មន្ត្រីទាហាននិងប៉ូលិសនិងបុគ្គលសាធារណៈសំខាន់ៗផ្សេងទៀត ។

យោបល់លេខ១៣របស់គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ទៀតថា «ការណ៍ដែលមិនត្រូវសន្មតទុកជាមុនអំពីលទ្ធផលរបស់សវនាការគឺជាកាតព្វកិច្ចរបស់អាជ្ញាធរសាធារណៈ ។ ឧទាហរណ៍អ្នកតំណាងរដ្ឋសភាជាតិណាម្នាក់ដែលថ្លែងជាសាធារណៈថាជនជាប់ចោទណាម្នាក់ស័ក្តិសមនឹងទទួលទណ្ឌកម្មគឺជាការរំលោភលើសិទ្ធិនេះ» ។

អាជ្ញាធរសាធារណៈអាចជូនដំណឹងដល់សាធារណជនអំពីដំណើរការស៊ើបអង្កេតព្រហ្មទណ្ឌណាមួយ ប៉ុន្តែគួរតែធ្វើដោយប្រុងប្រយ័ត្នជាទីបំផុតដោយគោរពគោលការណ៍សន្មតជាមុនថាគ្មានទោស ។

### សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមឆ្នាំ១៩៧៩

ការរំលោភលើទ្រឹស្តីនៃការសន្មតជាមុនថាគ្មានទោសគឺជាកម្មវត្ថុនៃការរិះគន់យ៉ាងធ្ងន់ធ្ងរបំផុតចំពោះសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមកាលពីឆ្នាំ១៩៧៩ ។ សាលាជំនុំជម្រះក្តីនេះបានទទួលការរិះគន់ធ្ងន់ធ្ងរជាច្រើន ក៏ប៉ុន្តែសាលាជំនុំជម្រះក្តីនេះពិតជាខកខានមិនបានបំពេញតាមបទដ្ឋានអន្តរជាតិស្តីអំពីការសន្មតជាមុនថាគ្មានទោស ។ ជនជាប់ចោទត្រូវបានប្រកាសថាមានទោសសូម្បីតែនៅនឹងឈ្មោះរបស់សាលាជំនុំជម្រះក្តីនេះ÷ «តុលាការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញដើម្បីជំនុំជម្រះក្តីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់បន ប៉ុល ពត-អៀង សារី» ។ កែវ ចិន្តា ដែលជាប្រធានចៅក្រមនៅក្នុងការជំនុំជម្រះក្តីនោះបានបង្ហាញអំពីការជឿជាក់របស់គាត់ថាជនជាប់ចោទពិតជាមានទោស ដោយបានប្រកាសមួយថ្ងៃមុនពេលបើកសវនាការថាៈ

*«ជំនុំជម្រះបនប៉ុល ពត-អៀង សារី អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នឹងអាចបង្ហាញឲ្យឃើញពីសកម្មភាពឧក្រិដ្ឋទាំងអស់ដែលអ្នកទាំងនោះបានប្រព្រឹត្តព្រមទាំងប្រមូលផ្តុំប្រជាជនកម្ពុជាដើម្បីកសាងនិងការពារអំណាចរបស់ប្រជាជន ។ ម្យ៉ាងវិញទៀតការជំនុំជម្រះក្តីនេះនឹងបង្ហាញដល់ប្រជាជនទូទាំងពិភពលោកនូវមុខមាត់ពិតប្រាកដរបស់ឧក្រិដ្ឋជនដែលត្រូវបានតែងតាំងជាតំណាងរបស់ប្រជាជនកម្ពុជា ។»*

ដូច្នេះ បើទោះបីជាមានភស្តុតាងប្រឆាំងនឹង ប៉ុល ពត និង អៀង សារី ក៏ដោយ ក៏សាលាជំនុំជម្រះក្តីកាលពីឆ្នាំ១៩៧៩

ត្រូវបានយល់ជាទូទៅថាជាសាលាជំនុំជម្រះក្តីមិនស្របច្បាប់ (សាលាជំនុំជម្រះក្តីដែលធ្វើឲ្យតែបាន) ហើយសាលក្រមបញ្ជាក់អំពីកំហុសរបស់ជនជាប់ចោទមិនដែលត្រូវបានអនុវត្តឡើយ ។ ប្រសិនបើមន្ត្រីសាធារណៈមិនគោរពឲ្យបានម៉ឺងម៉ាត់ចំពោះគោលការណ៍សន្មតជាមុនថាគ្មានទោសនេះទេ អង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗនេះប្រហែលជានឹងធ្លាក់ទៅក្នុងប្រភេទសាលាជំនុំជម្រះក្តីមិនត្រឹមត្រូវតាមច្បាប់ដូចតុលាការប្រជាជនបដិវត្តន៍កាលពីឆ្នាំ១៩៧៩ជាមិនខាន ។

### ៣) សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

មាត្រា១៤(១) របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន «ការជំនុំជម្រះក្តីដោយយុត្តិធម៌និងជាសាធារណៈដោយសាលាជំនុំជម្រះក្តីដែលបង្កើតឡើងដោយច្បាប់និងដែលមានសមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀង» ។ សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា៣៣ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងមាត្រា១២(២) និងមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ច្បាប់កម្ពុជាក៏បានរំឭកដល់មាត្រា៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៣ដែរ ។

#### ធាតុផ្សំរបស់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

- សមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀង
- សមភាពនៃការការពារនិងការចោទប្រកាន់ (សមភាពរវាងមេធាវីរបស់ជនជាប់ចោទ និងព្រះរាជអាជ្ញា)
- ការចូលរួមរបស់សាធារណៈ

#### ក) សមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀង

ការធានានូវបញ្ហាសមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀងរបស់ចៅក្រមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញគឺជាបញ្ហាដ៏ចម្រូងចម្រាស់នៅក្នុងដំណើរការនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ **សមត្ថភាព** មានន័យថា ចៅក្រមត្រូវតែឆ្លាតអាចទុកចិត្តបាននិងមានការយល់ដឹងក្នុងការអនុវត្តច្បាប់ ។ **ឯករាជ្យភាព** មានន័យថា ចៅក្រមត្រូវតែធ្វើការដោយមិនរវល់នឹងទស្សនៈរបស់សាធារណជននិងថ្នាក់ដឹកនាំនយោបាយ ។ **ភាពមិនលម្អៀង** មានន័យថា ចៅក្រមត្រូវតែសម្រេចចិត្តដោយមានហេតុផលត្រឹមត្រូវដោយមិនពាក់ព័ន្ធនឹងអារម្មណ៍ផ្ទាល់ខ្លួន ។

មាត្រា១០ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងអំពីលក្ខខណ្ឌមួយចំនួនដែលចៅក្រមកម្ពុជាត្រូវតែមានរួមទាំងឧត្តមគតិខ្ពស់ ភាពមិនលម្អៀង និងបទពិសោធន៍នៅក្នុងច្បាប់អន្តរជាតិ ។ ក៏ប៉ុន្តែអ្នករិះគន់ជាច្រើនបានបង្ហាញមន្ទិលសង្ស័យចំពោះលទ្ធភាពក្នុងការស្វែងរកចៅក្រមកម្ពុជាដែលមានសមត្ថភាព ឯករាជ្យភាព និងមិនលម្អៀង សម្រាប់សាលាជំនុំជម្រះក្តីចម្រុះដោយសារតែតុលាការកម្ពុជាត្រូវបានរិះគន់ជាទូទៅថាពុករលួយនិងមិនមានប្រសិទ្ធិភាព ។ ជាក់ស្តែងនៅក្នុងការដកស្រង់សម្តីរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដែលថាៈ *«ខ្ញុំនឹកឃើញដល់របាយការណ៍របស់អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅប្រទេសកម្ពុជាដែលបានរកឃើញថា តុលាការកម្ពុជាមានការគោរពតិចតួចប៉ុណ្ណោះចំពោះខ្លឹមសារសំខាន់ៗនៃសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ខ្ញុំព្រួយបារម្ភថា ខចែងសំខាន់ៗរបស់....[កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ] ប្រហែលជានឹងមិនត្រូវបានគោរពឲ្យបានពេញលេញនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនោះទេ និងបារម្ភថាគ្មានការធានាបទដ្ឋានយុត្តិធម៌អន្តរជាតិនិងដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់»* ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការឃ្លាំមើលសិទ្ធិមនុស្សនិងអង្គការលើកលែងទោសអន្តរជាតិជាដើម បានបដិសេធមិនគាំទ្រសាលាជំនុំជម្រះក្តីនេះដោយសារតែការព្រួយបារម្ភទាំងនោះ ។

ជាទូទៅ ចៅក្រមត្រូវបានសន្មតថាជាមនុស្សមានសមត្ថភាពមិនលម្អៀង និងឯករាជ្យ រហូតដល់រកឃើញផ្សេងពីនេះ ។ នៅក្នុងករណីរវាងព្រះរាជអាជ្ញានិង អាកាយេស៊ុ *(Prosecutor v. Akayesu case)* អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិរ៉ាវ៉ាន់ដាបានកំណត់ថា ដើម្បីអាចកំណត់ថាចៅក្រមណាម្នាក់លម្អៀងលុះត្រាណាតែមានភ័ស្តុតាងគ្រប់គ្រាន់ ។ តុលាការនេះបានសម្រេចថា «ប្រសិនបើគ្មានភ័ស្តុតាងទេនោះ យើងត្រូវ

តែសន្មតថាចៅក្រមរបស់សាលាជំនុំជម្រះក្តីអន្តរជាតិមិនបានកាត់សេចក្តីដោយផ្អែកទៅលើការជឿជាក់ផ្ទាល់ខ្លួនឬដោយលម្អៀងឡើយ» ។

### ១) សមភាពនៃការការពារនិងការចោទប្រកាន់

ដើម្បីធានាឲ្យមាន (សមភាពនៃការការពារនិងការចោទប្រកាន់សមភាពរវាងមេធាវីចុងចោទនិងព្រះរាជអាជ្ញា) តុលាការត្រូវដាក់ឲ្យមេធាវីជនជាប់ចោទនិងព្រះរាជអាជ្ញាស្ថិតនៅក្នុងតំណែងមួយដែលមានសមភាពគ្នាតាមនីតិវិធីទាំងមុនពេលដំណើរការនិងនៅទូទាំងដំណើការកាត់ក្តីទាំងមូល ។ នេះមានន័យថា ទាំងសងខាងមានឱកាសស្មើគ្នាក្នុងការការពារក្តីក្នុងការត្រួតពិនិត្យភស្តុតាងនិងសក្ខីភាពសាក្សី ព្រមទាំងសិទ្ធិនិងអភ័យឯកសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ ។ សាលាឧទ្ធរណ៍របស់សាលាជំនុំជម្រះក្តី ព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសអតីតយូហ្គោស្លាវីបានសម្រេចនៅក្នុងករណីរបស់ព្រះរាជអាជ្ញានិងថេឌីក *(Prosecutor v. Tadic)* ថា «សមភាពនៃការការពារនិងការចោទប្រកាន់ តម្រូវឲ្យតុលាការធានាថាមិនមានភាគីណាមួយ (ព្រះរាជអាជ្ញាឬមេធាវីជនជាប់ចោទ) ខាតប្រយោជន៍នៅពេលការពារសំណុំរឿងរបស់ខ្លួននោះទេ» ។

ទាំងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវីបានសន្និដ្ឋានថា សមភាពនៃការការពារនិងការចោទប្រកាន់មិនមានន័យថាសមភាពនៃធនធាននោះទេ ប៉ុន្តែមានន័យថា តុលាការត្រូវតែប្រព្រឹត្តចំពោះភាគីទាំងសងខាងតាមរបៀបមួយដែលមានសមភាពរវាងគ្នាតាមនីតិវិធីនិងផ្តល់ឲ្យភាគីទាំងសងខាងនូវពេលវេលានិងឱកាសស្មើភាពគ្នាក្នុងការរៀបចំការការពារសំណុំរឿងរបស់ខ្លួន ។

### ក) ការចូលរួមរបស់សាធារណជន

មាត្រា១៤(១)របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានចែងអំពីសិទ្ធិក្នុងការជំនុំជម្រះជាសាធារណៈនិងប្រកាសសាលក្រមជាសាធារណៈ ។ មាត្រា១២(២)និងមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនិងមាត្រា៣៤នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានធានាថា ការជំនុំជម្រះនិងការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវធ្វើឡើងជាសាធារណៈ ។

ច្បាប់ទាំងនេះមានចែងទាំងករណីពិសេសរបស់សិទ្ធិនេះនៅក្នុងកាលៈទេសៈពិសេសទៀតផង ប៉ុន្តែសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីជាសាធារណៈនេះត្រូវគេយល់ថាមានសារសំខាន់ក្នុងការធានាឲ្យមានយុត្តិធម៌ ដោយសារវាបានជួយធ្វើឲ្យមានតម្លាភាព ។ ប្រសិនបើសវនាការត្រូវធ្វើឡើងជាសាធារណៈនោះចៅក្រមនឹងលំបាកក្នុងការរំលោភច្បាប់និងក្នុងការបដិសេធសិទ្ធិរបស់ជនជាប់ចោទ ។ ជាងនេះទៅទៀត ការជំនុំជម្រះជាសាធារណៈមានភាពស្របច្បាប់ ដោយសារសាធារណជនអាចផ្ទៀងផ្ទាត់អំពីភាពយុត្តិធម៌របស់សវនាការនេះ ។

ការចូលរួមរបស់សាធារណជននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនឹងមានសារខំខាន់ជាពិសេសក្នុងការជួយធានាដំណើរការស្វែងរកការពិតនិងការផ្សះផ្សាជាតិ ។ ការចូលរួមរបស់សាធារណជននឹងជួយផ្សព្វផ្សាយការពិតដែលបង្ហាញនៅក្នុងសវនាការនិងជួយជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យសះស្បើយពីឧក្រិដ្ឋកម្មដែលគាត់ទទួលរងនៅក្រោមរបបនោះតាមរយៈការមើលឃើញដំណើរការស្វែងរកយុត្តិធម៌ ។ ជាងនេះទៅទៀត ប្រសិនបើសិទ្ធិរបស់ជនជាប់ចោទត្រូវបានគោរព អង្គជំនុំជម្រះវិសាមញ្ញនឹងផ្តល់ឱកាសដល់ប្រជាជនកម្ពុជាឲ្យទទួលបាននូវការជូនដំណឹងអំពីសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការកម្ពុជា ។

អង្គជំនុំជម្រះវិសាមញ្ញមានទីតាំងនៅក្នុងទីក្រុងភ្នំពេញហើយមនុស្សគ្រប់រូបនឹងត្រូវបានអនុញ្ញាតឲ្យចូលរួមស្តាប់សវនាការដោយមិនគិតថ្លៃ ទាំងប្រជាជនកម្ពុជាទាំងជនបរទេស ។ ផ្នែកពិសេសមួយនឹងត្រូវបានទុកជូនសាធារណជនទូទៅរួមទាំងអ្នកដែលមានផលប្រយោជន៍ផ្ទាល់នៅក្នុងសំណុំរឿងខ្លះទៀតផង ។ សវនាការនឹងត្រូវបានថតជាឯកសារនិងជាអត្ថបទសំណេរផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ ហើយប្រហែលជាអាចផ្សាយនៅខាងក្រៅអង្គជំនុំជម្រះទៀតផងប្រសិនបើមិនមានកន្លែងគ្រប់គ្រាន់សម្រាប់សាធារណជន ។

មានករណីមួយចំនួនដែលតុលាការអាចជំនុំជម្រះជា

*សម្ងាត់មិនឲ្យសាធារណជនចូលរួម ។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានអនុញ្ញាតឲ្យបិទមិនឲ្យសាធារណជនចូលរួម «ប្រសិនបើការចូលរួមរបស់សាធារណជនអាចធ្វើឲ្យលម្អៀងដល់ផលប្រយោជន៍យុត្តិធម៌» ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យតុលាការជំនុំជម្រះជាសម្ងាត់ «ដើម្បីបុព្វហេតុត្រឹមត្រូវ ហើយស្របជាមួយនឹងនីតិវិធីដែលមានជាធរមាន» ។ ក្រៅពីការព្រួយបារម្ភអំពីភាពលម្អៀង មាត្រា១៤(១) របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានចែងអំពីមូលហេតុមួយចំនួនដែលតុលាការអាចសម្រេចមិនឲ្យសាធារណជនចូលរួមនៅក្នុងសវនាការ «ប្រសិនបើការកាត់ក្តីនោះប៉ះពាល់ដល់គុណធម៌ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលដែលផលប្រយោជន៍នៃជីវភាពឯកជនរបស់ភាគីមានភាពចាំបាច់» ។*

មូលហេតុដែលទំនងបំផុតដែលអង្គជំនុំជម្រះវិសាមញ្ញប្រហែលជាសម្រេចមិនឲ្យសាធារណជនចូលរួមគឺដើម្បីការពារសាក្សីមួយចំនួន ។ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសាក្សីផ្តល់សក្ខីភាពជាឯកជន ប្រសិនបើសក្ខីភាពនោះអាចបណ្តាលឲ្យមានការប៉ះពាល់ជាសាធារណៈ ឬនាំដល់ភាពអាម៉ាស់ ។ ជាក់ស្តែង អង្គជំនុំជម្រះតែងតែអនុញ្ញាតឲ្យជនរងគ្រោះនៃអំពើរំលោភផ្តល់សក្ខីភាពជាឯកជន ។ ជួនកាល អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសាក្សីផ្តល់សក្ខីភាពដោយមិនបញ្ចេញអត្តសញ្ញាណដោយប្រើប្រាស់វិធីពិសេសដូចជា ប្រើរបាំងភ្ជាប់វីដេអូ ឬឧបករណ៍កែប្រែសំឡេង ដោយខ្លាចថា ការផ្តល់សក្ខីភាពនេះនឹងបង្កគ្រោះថ្នាក់ដល់សាមីខ្លួនសាក្សីនិងសមាជិកក្រុមគ្រួសារ ។

គួរកត់សម្គាល់ថា អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរិះគន់ខ្លាំងក្លាចំពោះច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលខកខានមិនបានធានាការការពារគ្រប់គ្រាន់ដល់សាក្សី ។ ឧទាហរណ៍ អង្គការលើកលែងទោសអន្តរជាតិបានសរសេរថា *«មានខចែងមិនគ្រប់គ្រាន់សម្រាប់ការការពារសាក្សី [នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ]...ជនរងគ្រោះនិងសាក្សីនឹងមិនផ្តល់សក្ខីភាពទេ ប្រសិនបើគ្មានការធានាសុវត្ថិភាពជាចាំបាច់ពីអាជ្ញាធរអន្តរជាតិជាជាងពីអាជ្ញាធរក្នុងស្រុក»* ។

## ៤) សិទ្ធិទទួលបានមេធាវី

សិទ្ធិទទួលបានមេធាវីរួមមាន សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវីដោយខ្លួនឯង និងសិទ្ធិក្នុងការទទួលបានមេធាវីប្រសិនបើជនជាប់ចោទមិនមានលទ្ធភាពចំណាយ ។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា៣៥(ឃ) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងមាត្រា១៣នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ សិទ្ធិនេះមានចែងយ៉ាងពេញលេញនៅក្នុងមាត្រា១៤(៣) (ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលមានចែងនៅខាងក្រោមនេះ÷

**មាត្រា១៤(៣) (ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ**

*«[ជនជាប់ចោទមានសិទ្ធិ]...ការជំនុំជម្រះទោសត្រូវធ្វើនៅចំពោះមុខសាមីជន ។ សាមីជនអាចឆ្លើយដោះសារដើម្បីការពារខ្លួនឯងឬអាចរកស្មាក្តីឲ្យជួយការពារ ។ សាមីជនមានសិទ្ធិរើសមេធាវីដោយខ្លួនឯងប្រសិនបើខ្លួនមានប្រាក់គ្រប់គ្រាន់សម្រាប់បង់ថ្លៃឈ្នួល ។ ក្នុងករណីដែលចាំបាច់តុលាការត្រូវតែផ្តល់មេធាវីឲ្យជនជាប់ចោទដោយឥតគិតកម្រៃឈ្នួលប្រសិនបើជនជាប់ចោទគ្មានមធ្យោបាយឬប្រាក់កាសគ្រប់គ្រាន់ ។*

មេធាវីនេះត្រូវតែបានផ្តល់ឲ្យពេញទាំងដំណើរការច្បាប់ទាំងមូល រួមទាំងនៅក្នុងដំណាក់ស៊ើបអង្កេតបឋមផង ។

មិនមានច្បាប់ណាមួយរបស់អង្គជំនុំជម្រះវិសាមញ្ញបញ្ជាក់អំពីរបៀបដែលមេធាវីអាចត្រូវបានផ្តល់ដោយមិនគិតថ្លៃដល់ជនជាប់ចោទដែលក្រីក្រមិនមានលទ្ធភាពជួលមេធាវី (ជាពិសេសជនជាប់ចោទដែលក្រីក្របំផុតមិនអាចជួលមេធាវីដោយខ្លួនឯងបាន) ។ ដូច្នេះ ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែស្វែងរកនីតិវិធីដែលមាននៅក្នុងតុលាការកម្ពុជា ។ នៅក្នុងប្រទេសកម្ពុជា ប្រធានក្រឡាបញ្ជីរបស់តុលាការជាអ្នកកំណត់និងបញ្ជាក់ថាជនជាប់ចោទណាម្នាក់ជាអ្នកក្រីក្រដែលមិនមានលទ្ធភាពជួលមេធាវី ហើយគ្មានបទដ្ឋានជាក់លាក់នៅក្នុងការកំណត់នេះទេ ។ ប្រសិនបើជនជាប់ចោទណាម្នាក់ត្រូវបានរកឃើញថាក្រីក្រមិន

អាចជួលមេធាវីបាន ប្រធានតុលាការនឹងស្នើសុំទៅគណៈមេធាវីឲ្យផ្តល់មេធាវីម្នាក់មកការពារក្តីឲ្យជនជាប់ចោទ ។ គណៈមេធាវីមានមេធាវីមួយក្រុមតូចដែលការពារក្តីឲ្យជនជាប់ចោទក្រីក្រដែលមិនមានលទ្ធភាពជួលមេធាវី ។ ក្រៅពីមេធាវីទាំងនេះ គណៈមេធាវីអាចតែងតាំងមេធាវីដែលអនុវត្តវិជ្ជាជីវៈជាឯកជន ឬមេធាវីរបស់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូចដែលផ្តល់សេវាផ្នែកច្បាប់ដល់អ្នកក្រីក្រ ដូចជាអង្គការក្រុមមេធាវីការពារសិទ្ធិកម្ពុជានិងអង្គការជំនួយផ្នែកច្បាប់កម្ពុជា ។ នៅក្នុងការអនុវត្តជាញឹកញាប់ ចៅក្រមទាក់ទងមេធាវីទាំងនេះដោយផ្ទាល់និងដោយមិនបានប្រាប់គណៈមេធាវី ។

គួរកត់សម្គាល់ថា យោងតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមាត្រា១៧(គ) អង្គការសហប្រជាជាតិនឹងចំណាយលើការជួលមេធាវីឲ្យជនក្រីក្រដែលមិនមានលទ្ធភាពជួលមេធាវី ដូចដែលអង្គការសហប្រជាជាតិធ្លាប់ធ្វើនៅក្នុងសាលាជំនុំជម្រះក្តីអន្តរជាតិ ឬសាលាជំនុំជម្រះក្តីចម្រុះសម្រាប់ប្រទេសរ្វ៉ាន់ដា អតីតយូហ្គោស្លាវី និងសៀរ៉ាឡេអូន ។

បញ្ហាមួយដែលអង្គជំនុំជម្រះវិសាមញ្ញប្រហែលជាត្រូវប្រឈមមុខគឺការធានានូវការការពារក្តីដ៏មានប្រសិទ្ធិភាពដល់ជនជាប់ចោទដោយមេធាវីដែលមានសមត្ថភាព ។ គណៈកម្មាធិការសិទ្ធិមនុស្សបានបកស្រាយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយថា មេធាវីដែលផ្តល់ដល់ជនជាប់ចោទត្រូវតែមានសមត្ថភាពសមរម្យ ។ នៅក្នុងរឿងក្តី ហ៊ីលីព ជាមួយនឹងប្រទេសទ្រីនីដាដនិងតូបេហ្គោ បុរសម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតដែលត្រូវមានទោសប្រហារជីវិត បានប្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សថា តុលាការបានផ្តល់មេធាវីឲ្យគាត់ក្នុងរយៈពេលតែបីថ្ងៃមុនពេលសវនាការ ហើយមេធាវីនោះមិនមានបទពិសោធន៍ថែមទៀត ។ គណៈកម្មាធិការសិទ្ធិមនុស្សបានចេញសេចក្តីសម្រេចថា «បើទោះបីជាមាត្រា១៤(៣)(ឃ) មិនបានផ្តល់សិទ្ធិឲ្យជនជាប់ចោទជ្រើសរើសមេធាវីដែលផ្តល់ឲ្យដោយមិនយកកម្រៃក៏ដោយ ក៏តុលាការត្រូវតែធានាថា ការការពារក្តីរបស់មេធាវីមិនត្រូវប្រឆាំងនឹងផលប្រយោជន៍នៃយុត្តិធម៌នោះទេ ។»

ប្រទេសកម្ពុជាមានមេធាវីចុងចោទតិចតួចប៉ុណ្ណោះដែលមានបទពិសោធន៍ក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ជាងនេះទៅទៀត ភាគច្រើននៃមេធាវីទាំងនេះអាចមិនមានឆន្ទៈការពារជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញឡើយ ។ ដូច្នេះប្រហែលជាអង្គជំនុំជម្រះវិសាមញ្ញត្រូវតែជួលមេធាវីអន្តរជាតិមកជួយមេធាវីកម្ពុជាដែលតុលាការបានផ្តល់ឲ្យជនជាប់ចោទក្រីក្រដូចដែលត្រូវបានអនុញ្ញាតនៅក្នុងមាត្រា២១(៣) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ជនជាប់ចោទអាចអះអាងថា ខ្លួនមានសិទ្ធិទទួលបានមេធាវីបរទេសដើម្បីធានានូវគោលការណ៍សមភាពរវាងការការពារនិងការចោទប្រកាន់ ដោយសារនៅក្នុងក្រុមរបស់ព្រះរាជអាជ្ញាក៏មានអ្នកច្បាប់បរទេសដែលមានបទពិសោធន៍ផ្នែកច្បាប់អន្តរជាតិដែរ ។

## ៥) សិទ្ធិមានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់

មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានផ្តល់ឲ្យជនជាប់ចោទនូវសិទ្ធិ «មានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួននិងដើម្បីទាក់ទងជាមួយមេធាវីដោយខ្លួនឯង ។» សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ និងមាត្រា៣៥(ខ) នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

សិទ្ធិមានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់មានទំនាក់ទំនងយ៉ាងរឹងមាំជាមួយនឹងគោលការណ៍សមភាពរវាងការការពារនិងការចោទប្រកាន់ ។ ពាក្យថា «សម្ភារៈ» ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដែលរួមមានសិទ្ធិក្នុងការទទួលបានភស្តុតាងដែលពាក់ព័ន្ធលទ្ធភាពក្នុងការពិនិត្យនិងចម្លងឯកសារដែលអាចជួយដល់សំណុំរឿងរបស់ជនជាប់ចោទលទ្ធភាពក្នុងការស្វែងរកយោបល់របស់អ្នកជំនាញឯករាជ្យនិងសិទ្ធិក្នុងការពិនិត្យមើលរាល់លិខិតទាក់ទងរវាងព្រះរាជអាជ្ញានិងតុលាការ ។ សិទ្ធិក្នុងការទទួលបានភស្តុតាងដែល

ពាក់ព័ន្ធចាប់ផ្តើមនៅក្នុងដំណាក់កាលស៊ើបអង្កេតមុនពេលមានការចោទប្រកាន់ ។ សិទ្ធិនេះមានបញ្ចូលនូវសិទ្ធិក្នុងការទាក់ទងជាសម្ងាត់រវាងជនជាប់ចោទនិងមេធាវីដែលចាប់ផ្តើមអនុវត្តភ្លាមៗបន្ទាប់ពីការចាប់ខ្លួន ។

វិសាលភាពនៃសិទ្ធិនេះគឺស្ថិតនៅលើព្រឹត្តិការណ៍និងនីតិវិធីរបស់សំណុំរឿង ។ សំណុំរឿងខ្លះត្រូវការពេលវេលាយូរដើម្បីរៀបចំការការពារ ហើយសំណុំរឿងខ្លះទៀតត្រូវការ«សម្ភារៈ»ច្រើនជាងសំណុំរឿងផ្សេងទៀត ។ គណៈកម្មាធិការសិទ្ធិមនុស្សបានបកស្រាយសិទ្ធិនេះយ៉ាងទូលំទូលាយ នៅក្នុងសវនាការនៃបទល្មើសធ្ងន់ធ្ងរដូចជាបទល្មើសមនុស្សឃាតជាដើម ។ ឧទាហរណ៍ នៅក្នុងរឿងក្តី ហ៊ីលីព ជាមួយនឹងប្រទេសទ្រីនីដាដនិងតូបេហ្គោ គណៈកម្មាធិការសិទ្ធិមនុស្សបានចេញសេចក្តីសម្រេចថា រយៈពេលពីរថ្ងៃនៃចុងសប្តាហ៍ (ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ) មិនគ្រប់គ្រាន់សម្រាប់រៀបចំការការពារបទល្មើសមនុស្សឃាតដែលជាទោសប្រហារជីវិតនោះទេ ។ នៅក្នុងរឿងក្តី យ៉ាសស៊ីន និង ថូម៉ាស ជាមួយប្រទេសហ្គីយ៉ាណា គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញការរំលោភសិទ្ធិក្នុងការទទួលបាននូវសម្ភារៈគ្រប់គ្រាន់ ដោយសារតែជនជាប់ចោទពីបទមនុស្សឃាតមិនបានទទួលសិទ្ធិក្នុងការពិនិត្យមើលឯកសារសួរចម្លើយរបស់ប៉ូលិសដែលប្រើប្រាស់ជាភ័ស្តុតាងប្រឆាំងនឹងខ្លួន ។ ដោយពិចារណាអំពីទម្ងន់នៃឧក្រិដ្ឋកម្មនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនិងភាពលំបាកក្នុងការការពារខ្លួនឯងប្រឆាំងនឹងការចោទប្រកាន់អំពីបទល្មើសផ្សេងៗដែលបានកើតឡើងកាលពី២៥ឆ្នាំមុន សិទ្ធិនេះប្រហែលជានឹងត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ។

## ៦) សិទ្ធិក្នុងការកោះហៅនិងត្រួតពិនិត្យសាក្សី

ទាក់ទងទៅនឹងគោលការណ៍សមភាពនៃការការពារនិងការចោទប្រកាន់និងសិទ្ធិមានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ក្នុងការការពារនៅចំពោះមុខច្បាប់ ចុងចោទមានសិទ្ធិកោះហៅនិងត្រួតពិនិត្យសាក្សី ។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា១៤(៣)(ង) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដូចដែលមានចែងខាងក្រោមនេះ ៖

*«[ជនជាប់ចោទមានសិទ្ធិ]... អាចពិនិត្យនិងសាកសួរដេញដោលសាក្សីខាងគូបដិបក្ខ ។ សិទ្ធិស្នើសុំឲ្យមានសាក្សីដើម្បីជួយឆ្លើយការពារខ្លួន ។ សាក្សីទាំងសងខាង គឺសាក្សីប្រឆាំងនិងសាក្សីការពារត្រូវស្ថិតនៅក្នុងលក្ខខណ្ឌច្បាប់ស្មើគ្នា ។»*

សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញនិងមាត្រា៣៥(ង) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ សិទ្ធិនេះមានន័យថាជនជាប់ចោទមានសិទ្ធិទាមទារឲ្យតុលាការបង្គាប់ឲ្យសាក្សីបង្ហាញខ្លួននៅចំពោះមុខតុលាការនិងមានសិទ្ធិសួរដេញដោលសាក្សីគូបដិបក្ខដែលត្រូវបានកោះហៅដោយព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាត្រូវតែប្រាប់មេធាវីចុងចោទអំពីសាក្សីដែលខ្លួនបម្រុងនឹងកោះហៅមកបង្ហាញខ្លួននៅក្នុងតុលាការ ហើយមេធាវីត្រូវតែទទួលបាននូវពេលវេលាគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យមើលសាក្សីទាំងនោះ ។

### សាក្សីអនាមិក

សាក្សីរបស់ព្រះរាជអាជ្ញាអាចផ្តល់កសិណជាអនាមិកបានដោយមិនបញ្ចេញអត្តសញ្ញាណនៅក្នុងតុលាការ ប្រសិនបើមានភាពចាំបាច់ក្នុងការការពារសាក្សី ។ ប៉ុន្តែជាធម្មតា មេធាវីចុងចោទត្រូវតែបានទទួលដំណឹងអំពីអត្តសញ្ញាណរបស់សាក្សីដើម្បីមានឱកាសស្មើគ្នាក្នុងការត្រួតពិនិត្យសាក្សីនេះ ។ ប្រសិនបើមេធាវីចាំបាច់ត្រូវតែត្រួតពិនិត្យសាក្សីដោយមិនស្គាល់អត្តសញ្ញាណរបស់សាក្សី មេធាវីអាចលើកឡើងអំពីភាពមិនទុកចិត្តចំពោះសាក្សីនោះ ។ ដូច្នេះអត្តសញ្ញាណរបស់សាក្សីត្រូវតែបង្ហាញដល់មេធាវីចុងចោទ ។ ឧទាហរណ៍ នៅក្នុងរឿងក្តីរបស់ វិនឌីស្ស ជាមួយប្រទេសអូទ្រីស តុលាការសិទ្ធិមនុស្សអឺរ៉ុបបានចេញសេចក្តីសម្រេចថា វាមិនយុត្តិធម៌ទេដែលប៉ូលិសប្រើប្រាស់សក្ខីភាពរបស់សាក្សីសម្ងាត់ បើទោះបីជាមេធាវីអាចសួរសំណួរមិនផ្ទាល់ទៅកាន់សាក្សីនោះក៏ដោយ ។ តុលាការនេះបានចេញសេចក្តីសម្រេចថា *«ដោយមិនស្គាល់អត្តសញ្ញាណរបស់សាក្សី មេធាវីត្រូវប្រឈមមុខនឹងឧបសគ្គមួយដែលស្ទើរ តែមិនអាចជម្នះបាន ពោលគឺមេធាវីបានបាត់បង់ព័ត៌មានចាំបាច់ដែលអាច*



សាក្សីនៅក្នុងតុលាការកាត់ទោសប៉ុលពត-អៀងសារីឆ្នាំ១៩៧៩

ឲ្យខ្លួនពិនិត្យមើលភាពទុកចិត្តបានរបស់សាក្សីឬបង្កការសង្ស័យចំពោះភាពជឿជាក់លើសាក្សី» ។

មានកាលៈទេសៈសំខាន់ៗមួយចំនួនដែលសាលាជំនុំជម្រះអន្តរជាតិអនុញ្ញាតឲ្យលាក់បាំងអត្តសញ្ញាណរបស់សាក្សី (ជាពិសេសប្រសិនបើជនរងគ្រោះព្រួយបារម្ភអំពីការសងសឹកពីសំណាក់ជនជាប់ចោទ) ។ គ្រប់ពេលដែលអាចវាមានសារសំខាន់ក្នុងការការពារសុវត្ថិភាពសាក្សី ប៉ុន្តែនៅតែអនុញ្ញាតឲ្យមេធាវីចុងចោទនូវវិធីខ្លះក្នុងការត្រួតពិនិត្យសាក្សី ។ ឧទាហរណ៍ តុលាការអាចបង្កើបឲ្យមេធាវីចុងចោទដឹងអត្តសញ្ញាណរបស់សាក្សី ប៉ុន្តែមិនមែនឲ្យជនជាប់ចោទដឹងទេ ។ ម្យ៉ាងទៀត មេធាវីចុងចោទអាចត្រួតពិនិត្យសាក្សីនៅក្រោមលក្ខខណ្ឌដែលអត្តសញ្ញាណរបស់សាក្សីត្រូវលាក់កំបាំង ។ ជាទូទៅអាជ្ញាធរអនុវត្តច្បាប់អាចមានមធ្យោបាយផ្សេងៗដើម្បីធានាការការពារសាក្សីនៅមុនពេល អំឡុងពេល និងក្រោយពេលសវនាការ ។

តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបក៏បានគិតដែរថា «ការសម្រេចសេចក្តីមិនគួរមានមូលដ្ឋានតែទៅលើកសិណសាក្សីអនាមិកនោះទេ» ។

### ៧) សិទ្ធិផ្សេងៗទៀតរបស់ជនជាប់ចោទ

មានសិទ្ធិផ្សេងទៀតរបស់ជនជាប់ចោទដែលមានចែងនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ មួយចំនួនតូចនៃសិទ្ធិទាំងនេះមិនទំនងជាបង្កភាពចម្រូងចម្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញទេ ប៉ុន្តែអាចជាការកត់សម្គាល់ខ្លីៗ ។

#### ក) សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

ជនណាក៏ដោយដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ មានសិទ្ធិទទួលបាននូវការជំនុំជម្រះសេចក្តីនិងទទួលបានសាលក្រមនៅក្នុងរយៈពេលមួយសមរម្យ ។ មាត្រា១៤(៣)(គ) របស់កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយធានាឲ្យជនជាប់ចោទមានសិទ្ធិទទួលបាននូវការជំនុំជម្រះ«ដោយគ្មានការពន្យារពេល» ។ សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ សិទ្ធិនេះត្រូវបានអនុវត្តទាំងនៅពេលនាំសំណុំរឿងទៅកាន់តុលាការ និងនៅពេលដំណើរការសំណុំរឿងក្តី ។ អត្ថន័យនៃពាក្យ «គ្មានការពន្យារពេល» អាស្រ័យទៅលើភាពស្មុគស្មាញនិងកាលៈទេសៈរបស់ករណីនីមួយៗ ។

គួរកត់សម្គាល់ដែរថា សិទ្ធិទទួលបានការជំនុំជម្រះសេចក្តីដោយគ្មានការពន្យារពេលមានប្រភពទាំងនៅក្នុងសិទ្ធិទទួលបាននូវសេរីភាពនិងសិទ្ធិក្នុងការសន្មតជាមុនថាគ្មានទោស ។ រដ្ឋាភិបាលត្រូវតែធានាថា អ្នកដែលត្រូវឃុំខ្លួនបណ្តោះអាសន្នគឺត្រូវបានដកហូតនូវសេរីភាពរួចទៅហើយ ហើយត្រូវនាំទៅកាន់សវនាការឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយសារជនជាប់ចោទទាំងនោះត្រូវបានសន្មតជាមុនថាគ្មានទោស ។ ជាងនេះទៅទៀត អ្នកដែលត្រូវបានឃុំខ្លួនយូរទំនងជាត្រូវបានសាធារណជនគិតថាជាជនមានកំហុស ។

#### ខ) សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់កំហុសលើខ្លួនឯង

មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទថា «មិន

ត្រូវបានបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬបង្ខំឲ្យសារភាពកំហុស» ។ ឃ្លានេះក៏មានចែងនៅក្នុងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមាត្រា៣៥(ឆ) ។ សិទ្ធិនៅស្ងៀមមិននិយាយបានបែងចែកជនជាប់ចោទឲ្យខុសពីសាក្សីដែលតុលាការអាចបង្ខំឲ្យផ្តល់កសិណ ។

តុលាការសិទ្ធិមនុស្សអឺរ៉ុបបានកំណត់ថា «សិទ្ធិនៅស្ងៀមមិននិយាយនៅពេលប៉ូលិសសួរសំណួរ និងបុព្វសិទ្ធិប្រឆាំងនឹងការឆ្លើយដាក់កំហុសលើខ្លួនឯងជាទូទៅត្រូវបានទទួលស្គាល់ថាជាបទដ្ឋានអន្តរជាតិ ដែលកំណត់ដោយសញ្ញាណនៃនីតិវិធីត្រឹមត្រូវ(...) ។ តាមរយៈការផ្តល់ការការពារដល់ជនជាប់ចោទប្រឆាំងនឹងការបង្ខិតបង្ខំមិនសមរម្យដោយអាជ្ញាធរ អភ័យឯកសិទ្ធិទាំងនេះបានរួមចំណែកដល់ការចៀសវៀងការខុសឆ្គងនៃយុត្តិធម៌ និងដើម្បីការពារគោលបំណងនៃមាត្រា៦» ។

បើទោះបីជាមិនបានចែងឲ្យបានច្បាស់លាស់នៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយក៏ដោយ ក៏គណៈកម្មាធិការសិទ្ធិមនុស្សបានសម្រេចបន្តទៀតថា ភ័ស្តុតាងទាំងឡាយណាដែលទទួលបានតាមរយៈការបង្ខិតបង្ខំមិនអាចយកមកប្រើជាភ័ស្តុតាងនៅក្នុងតុលាការបានទេ ។ ជាងនេះទៅទៀត ប្រសិនបើជនជាប់ចោទណាម្នាក់បដិសេធមិនផ្តល់កសិណ ការបដិសេធនេះមិនអាចបង្កើតជាភ័ស្តុតាងនៃកំហុសទេ ។ ជនជាប់ចោទត្រូវតែបានទទួលដំណឹងអំពីសិទ្ធិក្នុងការនៅស្ងៀមមិននិយាយនៅមុនពេលត្រូវសួរចម្លើយ ។ ដូច្នេះរាល់ចម្លើយទាំងឡាយណាដែលជនជាប់ចោទផ្តល់ឲ្យអាជ្ញាធរសួរចម្លើយមុនពេលបានទទួលសេចក្តីជូនដំណឹងអំពីសិទ្ធិនេះ អាចត្រូវបានប្រឆាំងជំទាស់ប្រសិនបើចម្លើយនោះត្រូវបានព្រះរាជអាជ្ញាប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តី ។

### ក) សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់

មាត្រា៣៥(ក) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការ«ទទួលបានដំណឹងភ្លាមៗជាភាសាដែលជនជាប់ចោទអាចយល់ដឹងបានអំពីលក្ខណៈនិងហេតុផលចោទប្រកាន់ប្រឆាំងនឹងខ្លួន» ។ ឃ្លានេះគឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងមាត្រា១៤(៣)(ក) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបញ្ជាក់ថា ដើម្បីឲ្យត្រឹមត្រូវតាមបទដ្ឋានទាំងនេះ បទចោទប្រកាន់ព្រហ្មទណ្ឌត្រូវតែបង្ហាញដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ «ទាំងអង្គច្បាប់និងអង្គហេតុដែលជាមូលដ្ឋាននៃការចោទប្រកាន់» ។

### ឃ) សិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍

មាត្រា១៤(៥) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានចែងថា «ជនណាម្នាក់ដែលត្រូវតុលាការសម្រេចផ្តន្ទាទោសជាបទឧក្រិដ្ឋ មានសិទ្ធិស្នើសុំទៅតុលាការថ្នាក់លើឲ្យសើរើពិនិត្យការវិនិច្ឆ័យទោសនេះសាជាថ្មី» ។

ប្រសិនបើជនជាប់ចោទចង់ធ្វើបណ្តឹងឧទ្ធរណ៍ប៉ុន្តែមិនអាចចំណាយទៅលើកម្រៃរបស់មេធាវីបាន ជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីដែលមានសមត្ថភាពសម្រាប់ការប្តឹងឧទ្ធរណ៍របស់គាត់ ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបង្កើតអង្គជំនុំជម្រះនៃសាលាកំពូលដែលនឹងត្រូវពិនិត្យមើលឡើងវិញនូវបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយព្រះរាជអាជ្ញាឬដោយមេធាវីចុងចោទ ។

### ច) សិទ្ធិទទួលបានអ្នកបកប្រែដោយឥតគិតថ្លៃ

មាត្រា៣៥ច) នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងមាត្រា១៤(៣)(ច) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានផ្តល់ដល់ជនជាប់ចោទនូវសិទ្ធិ«ទទួលបានការបកប្រែដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទមិនអាចយល់ឬមិនអាចនិយាយភាសាដែលប្រើប្រាស់នៅក្នុងតុលាការ» ។

សិទ្ធិទទួលបានអ្នកបកប្រែចាប់ផ្តើមនៅក្នុងអំឡុងពេលស៊ើបអង្កេត ។ ភាសាផ្លូវការរបស់អង្គជំនុំជម្រះគឺភាសាខ្មែរ បារាំង និងអង់គ្លេស ។

### សន្និដ្ឋាន

ការការពារសិទ្ធិរបស់ជនជាប់ចោទត្រូវតែថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នបំផុតបើចង់ឲ្យសម្រេចគោលដៅរបស់អង្គជំនុំជម្រះវិសាមញ្ញគឺ ការលាតត្រដាងការពិត ការដាក់ទោសឧក្រិដ្ឋជន និងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។ ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញមិនធានាថាជនជាប់ចោទទទួលបាននូវសិទ្ធិ

ដែលធានាដោយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបង្កើតអង្គជំនុំជម្រះវិសាមញ្ញ នោះអង្គជំនុំជម្រះវិសាមញ្ញនឹងមិនមានលក្ខណៈស្របច្បាប់ទេ ហើយនឹងក្លាយជាឥតប្រយោជន៍ ឬជាប្រភពនៃអយុត្តិធម៌ ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញគោរពសិទ្ធិរបស់ជនជាប់ចោទយ៉ាងប្រុងប្រយ័ត្ន នោះអង្គជំនុំជម្រះវិសាមញ្ញនឹងទំនងជាអាចសម្រេចគោលដៅរបស់ខ្លួន ហើយនឹងដើរតួនាទីជាសាលាជំនុំជម្រះក្តីគំរូសម្រាប់ប្រព័ន្ធយុត្តិធម៌កម្ពុជា ។

## កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ

### មាត្រា១២ៈ នីតិវិធី

១) នីតិវិធីត្រូវតែសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទបញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

២) អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ ។ ក្នុងផលប្រយោជន៍ធានាឲ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវនិងទុកចិត្តបានត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់ ។ ការលើកលែងមិនឲ្យចូលរួមស្តាប់ការជំនុំជម្រក្តីនេះ តាមមាត្រា១៤នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណាដែលការផ្សព្វផ្សាយចេញទៅនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

### មាត្រា១៣ៈ សិទ្ធិរបស់ជនជាប់ចោទ

១) សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវនិងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃររហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលានិងលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន សិទ្ធិទទួលបាននូវមេធាវីប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យឬបានពិនិត្យសាក្សីដាក់បន្ទុក ។

២ – អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា ប្រការស្តីពីសិទ្ធិទទួលបានមេធាវី ការពារក្តីនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានន័យថា ជនជាប់ចោទមានសិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯង ដូចដែលបានធានានៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ។

### មាត្រា៣៣ថ្មី

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទនិងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពី

សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន និងក្នុងការចាត់ការឲ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាព អនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលដែលរួមមានកម្លាំងប្រដាប់អាវុធដើម្បីធានាឲ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។

**មាត្រា៣៤ថ្មី**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

**មាត្រា៣៥ថ្មី**

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ៈ

ក) ទទួលពត៌មានភ្លាមៗនិងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ) មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួននិងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនិងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង

ង) ពិនិត្យភ័ស្តុតាងដាក់បន្ទុកនិងទទួលបាននូវការចូលរួមនិងការពិនិត្យភ័ស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នានិងភ័ស្តុតាងដាក់បន្ទុកដែរ

ច) មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ឬមិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ

ឆ) មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស ។

**ឯកសារហ្វីកហ្វីនផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: dccam@online.com.kh

Home page: www.dccam.org

# ទំនៀមទម្លាប់បូជាសពតាមគន្លងព្រះពុទ្ធសាសនា និងតម្រូវការថែរក្សាភ័ស្តុតាងកោសល្យវិច័យនៅប្រទេសកម្ពុជា

នៅពេលដែលកងទ័ពដែលដឹកនាំដោយវៀតណាមវាយលុកចូលមកក្នុងប្រទេសកម្ពុជានៅចុងខែធ្នូឆ្នាំ១៩៧៨ ហើយបានផ្តួលរំលំខ្មែរក្រហម កងទ័ពទាំងនោះបានរកឃើញភ័ស្តុតាងគ្រប់គ្រាន់អំពីការស្លាប់ដ៏ច្រើនលើសលប់ដែលបានបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ។ បើនិយាយអំពីចំនួនមនុស្សស្លាប់នៅក្នុងអំឡុងពេលជិតបួនឆ្នាំដែលខ្មែរក្រហមកាន់អំណាចគឺតិចបើប្រៀបធៀបទៅនឹងការស្លាប់នៅក្នុងចំណោមអំពើប្រល័យពូជសាសន៍សម័យទំនើបជាច្រើនទៀត (តាមការប៉ាន់ប្រមាណមនុស្ស១,៧លាននាក់បានស្លាប់ដោយត្រូវយកទៅសម្លាប់ ឬដោយសារតែអត់អាហារ ជំងឺ ឬការបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ) ប៉ុន្តែបើពិនិត្យមើលទៅលើភាគរយនៃចំនួនប្រជាជន គ្មានអំពើប្រល័យពូជសាសន៍ណាមួយមានចំនួនមនុស្សស្លាប់ច្រើនដូចអំពើប្រល័យពូជសាសន៍នៅកម្ពុជានោះទេ ។ ខ្មែរក្រហមជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់អាយុជីវិតប្រជាជនអស់ប្រហែល១ភាគ៤នៅក្នុងប្រទេសនេះ ។

បន្ទាប់ពីមានអំពើបំផ្លិចបំផ្លាញដែលខ្មែរក្រហមបានធ្វើមកលើប្រទេសកម្ពុជារួចមក មានការទាមទារជាសាធារណៈតិចតួចណាស់ដែលសុំឲ្យមានរៀបចំទុកដាក់ឆ្អឹងដែលរកឃើញនៅក្នុងរណ្តៅសាកសពរួមដែលស្ថិតនៅរាយប៉ាយពាសពេញប្រទេស ហើយដែលភាគច្រើននៃរណ្តៅសាកសពទាំងនោះមិនត្រូវបានប៉ះពាល់និងស្ថិតក្រោមឥទ្ធិពលនៃធម្មជាតិ ។ នៅក្នុងរបបនោះ ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសត្រូវបានបំផ្លាញខ្ទេចខ្ទីស្ទើរតែទាំងស្រុង (សាលារៀន ធនាគារ ប៉ុស្តិ៍ប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវបិទទ្វារចោល ហើយសំណង់សាសនាត្រូវបានប្រែក្លាយទៅជាពន្ធនាគារ) ។ អ្នកចេះដឹងជាច្រើនត្រូវបានសម្លាប់ ចំណែកអ្នកដែលនៅរស់ព្រួយបារម្ភអំពីការតស៊ូដើម្បីរស់ជាជាងផ្តោតអារម្មណ៍ទៅលើអ្នកស្លាប់ ។

ក្រោយពីការចរចាអស់រយៈពេល៧ឆ្នាំ នៅក្នុងខែវិច្ឆិកាឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានផ្តល់សច្ចាប័នដល់ច្បាប់វិសោធនកម្មបង្កើតអង្គជំនុំជម្រះវិសាមញ្ញសម្រាប់សាលាជំនុំជម្រះក្តី ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់របស់របបនោះ ។ ក្រៅពីសារសំខាន់ជាប្រវត្តិសាស្ត្រ ឆ្អឹងនៅក្នុងរណ្តៅសាកសពរួមនៅប្រទេសកម្ពុជានឹងផ្តល់ជាភ័ស្តុតាងជាក់ស្តែងនៅក្នុងការកាត់សេចក្តីមេឃាតករទាំងអស់នេះទៀតផង ។ ក៏ប៉ុន្តែ កាលពីពេលថ្មីៗនេះ ការពិភាក្សាវែកញែកអំពីការរៀបចំនិងថែរក្សាឆ្អឹងបានកើតមានឡើង ។

### កិច្ចខិតខំប្រឹងប្រែងដំបូងដើម្បីថែរក្សាឆ្អឹង

រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានស្វះស្វែងឲ្យមានការថែរក្សាអដ្ឋិធាតុ មនុស្សទាំងអស់ ដំបូងបង្អស់ដើម្បីបង្ហាញថា ប្រទេសចិនជាសត្រូវខាងមនោគមវិជ្ជានិងនយោបាយដែលស្ថិតនៅពីក្រោយខ្នងមេឃាតករនៅក្នុងប្រទេសកម្ពុជា ។



បន្ទាប់មក រដ្ឋាភិបាលនេះចាត់ទុកអដ្ឋិធាតុទាំងនោះជាភ័ស្តុតាងនៃអំពើប្រល័យពូជសាសន៍ ដូច្នេះខ្លួននឹងមានហេតុផលគ្រប់គ្រាន់ដើម្បីគ្រប់គ្រងប្រទេស (នៅពេលនោះអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលលោកខាងលិចមួយចំនួននៅតែទទួលស្គាល់ខ្មែរក្រហមថាជារដ្ឋាភិបាលស្របតាមច្បាប់របស់កម្ពុជា) ។ ទីតាំងពីរកន្លែងដ៏មានសារសំខាន់នៅក្នុងទីក្រុងភ្នំពេញគឺជាចំណុចផ្តោតការយកចិត្តទុកដាក់បំផុត ហើយសព្វថ្ងៃនេះបានក្លាយទៅជានិមិត្តរូបដ៏រន្ធត់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ទីតាំងទីមួយគឺទួលស្លែងជាអតីតវិទ្យាល័យមួយនៅក្នុងទីក្រុងភ្នំពេញដែលត្រូវបានយកមកធ្វើជាគុកសម្ងាត់របស់ប្រទេសក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (គុកនេះត្រូវបានស្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈឈ្មោះសម្ងាត់ ស-២១) ។ បើយោងទៅតាមឯកសារទាំងឡាយដែលបានរកឃើញនៅក្នុងនិងនៅជុំវិញគុក យ៉ាងហោចណាស់ក៏មានខ្មាំងរបស់ប្រទេសចំនួន ១ម៉ឺន៤ពាន់នាក់ត្រូវបានឃុំខ្លួននៅទីនេះ ហើយនៅពេលដែលកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានប្រទះឃើញអ្នករស់រានមានជីវិតតែប្រាំពីរនាក់ប៉ុណ្ណោះ ។


បូជនីយដ្ឋាននៅជើងឯក

នៅទួលស្លែង (ដែលត្រូវបានប្រែក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឆ្នាំ១៩៨០ ដោយប្រើប្រាស់ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ដែលនៅសេសសល់នៅកន្លែងនោះ) របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបផែនទីដែលមានទំហំ១២ម៉ែត្រការ៉េ ដោយប្រើប្រាស់ឆ្អឹងលលាដ៍ក្បាលដែលគាស់បានចំនួន៣០០លលាដ៍មកផ្គុំបញ្ចូលគ្នា ហើយរូបទន្លេត្រូវបានលាបពណ៌ក្រហមដែលជាពណ៌ឈាម ។ ផែនទីដែលផ្គុំដោយលលាដ៍ក្បាលនេះបានដាក់តាំងបង្ហាញរហូតដល់ឆ្នាំ ២០០២ ទើបត្រូវបានរុះរើចេញវិញ ។ សព្វថ្ងៃនេះ ឆ្អឹងលលាដ៍ដែលយកចេញពីផែនទីត្រូវបានដាក់នៅក្នុងប្រអប់ឈើបិទជិតដោយកញ្ចក់ ។

ទីតាំងទី២គឺ“វាលពិឃាត”បឹងជើងឯកដែលត្រូវបានរុករកឃើញមួយឆ្នាំក្រោយពីការចូលមកដល់របស់កងទ័ពវៀតណាម ។ ភាគច្រើននៃអ្នកជាប់គុកទួលស្លែង គឺយ៉ាងហោចណាស់២ម៉ឺននាក់ត្រូវបានយកទៅសម្លាប់នៅទីតាំងពិឃាតជើងឯកដែលមានចម្ងាយប្រមាណ១៥គីឡូម៉ែត្រពីទីតាំងគុក ។ ជាទូទៅ ជនរងគ្រោះត្រូវបានបង្ខំឲ្យលុតជង្គង់នៅមាត់រណ្តៅ បន្ទាប់មកអ្នកពិឃាតយកត្បូងចបបុកចបជីកវាយពីក្រោយចំកញ្ចឹងកឬចំក្បាល ។

ការជីកគាស់រណ្តៅជាទ្រង់ទ្រាយធំបានធ្វើឡើងនៅជើងឯកនៅក្នុងឆ្នាំ១៩៨០ ។ រណ្តៅសាកសពរួមប្រមាណ៨៩ ក្នុងចំណោម១៣០រណ្តៅត្រូវបានជីកគាស់នៅក្នុងបរិវេណនេះ ។ អដ្ឋិធាតុមនុស្សជិត៩ពាន់ត្រូវបានយកចេញពីទីនោះក្រោមជំនួយពីអ្នកជំនាញការកោសល្យវិច័យជាជនជាតិវៀតណាម ។ អដ្ឋិធាតុទាំងអស់ត្រូវបានរៀបចំថែរក្សាទុកដោយប្រើសារជាតិគីមីនិងដាក់នៅលើធ្នើនៅក្នុងបូជនីយដ្ឋានដែលសង់អំពីឈើនិងទុកជញ្ជាំងសងខាងចំហ ។ ដើម្បីឲ្យកាន់តែរន្ធត់ថែមទៀត មន្ត្រីរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបាន “តម្រៀប” អដ្ឋិធាតុទាំងនោះដើម្បីថតរូបភាព ។ នៅក្នុងទសវត្សរ៍បន្ទាប់ពីការដួលរលំរបស់របបខ្មែរក្រហម បូជនីយដ្ឋានថ្នាក់ជាតិនិងថ្នាក់តំបន់ជាច្រើនត្រូវបាន

កសាងឡើងទូទាំងប្រទេស ។ បូជនីយដ្ឋានថ្មីមួយត្រូវបានសាងសង់ឡើងនៅជើងឯកនៅក្នុងខែមិថុនាឆ្នាំ១៩៨៨ ។ ចេតិយថ្មកម្ពស់៦២ម៉ែត្ររបស់បូជនីយដ្ឋាននេះមានកញ្ចក់បិទជិតហើយអាចផ្ទុកឆ្អឹងលលាដ៍ចំនួន៨ពាន់ ។ ឧត្តមសេនីយ៍វៀតណាម ម៉ៃឡាំ ជាបណ្ណារក្សនៅសារមន្ទីរទួលស្លែង និងអ្នករៀបចំផែនទីឆ្អឹងលលាដ៍ក្បាល បានចាត់ទុកការថែរក្សាអដ្ឋិធាតុទាំងអស់នេះថា«មានសារសំខាន់សម្រាប់ប្រជាជនកម្ពុជា ពោល អដ្ឋិធាតុនេះគឺជាភ័ស្តុតាង» ។

## ព្រះពុទ្ធសាសនានិងការថែរក្សាអដ្ឋិធាតុ

ប្រជាជនកម្ពុជាប្រមាណជា៩៥ភាគរយគោរពប្រតិបត្តិសាសនាព្រះពុទ្ធសាសនានិកាយហីនយានដែលមិនផ្តល់ឱវាទឲ្យបូជាសពនោះទេ ។ ក៏ប៉ុន្តែ ការបូជាសពជាប្រពៃណីមួយនៅក្នុងប្រទេសកម្ពុជានិងសង្គមនានានៅអាស៊ីដែលគោរពសាសនាព្រះពុទ្ធនៅជាច្រើនសតវត្សរ៍មកហើយ ។ ប្រជាជនកម្ពុជាជាច្រើននាក់ជឿថា ការបូជាសពនិងការធ្វើពិធីផ្សេងៗសម្រាប់អ្នកស្លាប់នឹងជួយធ្វើឲ្យព្រលឹងអ្នកស្លាប់បានស្ងប់និងបានទៅចាប់កំណើតជាថ្មី ។ បន្ទាប់ពីការបូជាសព សមាជិកគ្រួសាររក្សាអដ្ឋិធាតុរបស់អ្នកស្លាប់នៅក្នុងចេតិយ ។ ធ្វើដូច្នេះព្រលឹងអ្នកស្លាប់ទាំងនោះអាចចាកផុតពីទុក្ខទាំងឡាយទាំងពួងនិងទៅចាប់ភពថ្មី ។

បន្ថែមពីលើប្រពៃណីនេះគឺការប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ដែលច្របាច់បញ្ចូលគ្នានូវសាសនាហិណ្ឌូនិងជំនឿដើម (ការជឿថាធម្មជាតិទាំងអស់សុទ្ធតែមានព្រលឹង) ។ ព្រលឹងអ្នកស្លាប់ស្ថិតនៅក្នុងចំណោមព្រលឹងទាំងឡាយនៅក្នុងពិភពជំនឿទាំងអស់នេះ ។ ព្រលឹងមនុស្សដែលស្លាប់តៃហោងត្រូវបានចាត់ទុកថាជាព្រលឹងកាចសាហាវបំផុត ពីព្រោះថាព្រលឹងអ្នកទាំងនេះមិនអាចស្ងប់បាន ហើយនឹងតាមលងអ្នកនៅរស់ដែលធ្វើបាបខ្លួន ។

នៅក្នុងករណីស្លាប់ដោយសារគ្រោះអាក្រក់ ដូចជាដោយសារអំពើហិង្សាឬគ្រោះថ្នាក់ ប្រជាជនមានជំនឿថាព្រលឹងនោះនៅតែវិលវល់នៅកន្លែងដែលអ្នកនោះបានស្លាប់ និងមិនអាចទៅចាប់ជាតិថ្មីបានទេ ។ បញ្ញាជន រ៉ាឈល ហាគីស បានកត់សម្គាល់ឃើញថា «ប្រជាជនកម្ពុជាភាគច្រើនចាត់ទុកបឹងជើងឯកជាទីកន្លែងប្រកបដោយគ្រោះថ្នាក់បំផុត និងបដិសេធមិនព្រមទៅទស្សនាបូជនីយដ្ឋាននេះទេ ។ ក្រៅពីនេះទៀត ការដាក់តាំងបង្ហាញអដ្ឋិធាតុដោយមិនបូជាត្រូវបានអ្នកខ្លះចាត់ទុកថាជាអំពើល្មើសដ៏ធំមួយមានន័យស្មើនឹងការប្រព្រឹត្តអំពើហិង្សាជាលើកទីពីរទៅជនរងគ្រោះ» ។

ការពិនិត្យពិចារណាមួយចំនួននៅមានសុពលភាពនៅឡើយទាក់ទងទៅនឹងការថែរក្សាទុកអដ្ឋិធាតុទាំងអស់នេះ ។ ទីមួយ ពុទ្ធសាសនិកជនកម្ពុជាមិនបញ្ចុះសពអ្នកស្លាប់ និងមិនទៅមើលផ្នូរទេ (ប៉ុន្តែពុទ្ធសាសនិកជនចិនបញ្ចុះសាកសពហើយទៅគោរពផ្នូរ) ។ ដូច្នេះ ប្រជាជនកម្ពុជាភាគច្រើនចាត់ទុកបឹងជើងឯកថាជាចេតិយ មិនមែនជាបូជនីយដ្ឋានទេ ។ ទីពីរ ការអាក់អន់ចិត្តនោះគឺប្រតិកម្មតាមធម្មជាតិរបស់មនុស្សថា អដ្ឋិធាតុទាំងនោះប្រហែលជាអដ្ឋិធាតុសាច់សាលោហិតរបស់ខ្លួន ដូច្នេះប្រជាជនជាច្រើនស្ទាក់ស្ទើរមិនហ៊ានទៅទស្សនាបូជនីយដ្ឋាននេះ ។ ចុងក្រោយ ប្រជាជនកម្ពុជាមួយចំនួនពិតជាចាត់ទុកជើងឯកជាទីកន្លែងប្រកបដោយគ្រោះថ្នាក់មួយ ដោយសារតែមានវត្តមាននៃខ្មោចទាំងអស់នោះ មិនមែនដោយសារអ្នកទាំងនោះភ័យខ្លាចត្រូវចោរប្លន់នៅទីនោះទេ ។ អ្នកដែលបានទៅទស្សនាទីតាំងនេះមានគោលបំណងចែករំលែកសមានចិត្តសោកស្តាយស្រណោះ ដូច្នេះបឹងជើងឯកអាចត្រូវបានចាត់ទុកថាជាទីកន្លែងផ្សះផ្សារបួសសម្រាប់អ្នករស់រានមានជីវិត ។

## ភាពចម្រូងចម្រាស់ទៅលើអដ្ឋិធាតុ

ប្រជាជនកម្ពុជាភាគច្រើន រួមទាំងប្រជាជនធម្មតា សហគមន៍សាសនា និងរដ្ឋាភិបាល ហាក់ដូចជាគាំទ្រឲ្យថែរក្សាឆ្អឹងលលាដ៍និងបំណែកអដ្ឋិធាតុរបស់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ (ការគាំទ្រនេះកើតឡើងដោយសារតែមានជំនឿជាមូលដ្ឋាននៅក្នុងប្រពៃណីព្រះពុទ្ធសាសនាថា ប្រជាជនអាចបូជាតែអដ្ឋិធាតុណាដែលជាសមាជិកក្រុមគ្រួសាររបស់ខ្លួនប៉ុណ្ណោះ ។ ជាក់ស្តែងដោយសារតែគ្មានអ្នកណាស្គាល់ថា អដ្ឋិធាតុទាំងនេះជារបស់អ្នកណា ដូច្នេះការបូជាអាចបង្កឲ្យមានឧបសគ្គមួយចំនួននៅក្នុងប្រទេសកម្ពុជា) ។

រដ្ឋាភិបាលកម្ពុជាបានគាំទ្រជាយូរយារណាស់មកហើយឲ្យ

មានការថែរក្សាទុកអដ្ឋិធាតុនេះដើម្បីធ្វើជាភស្តុតាង ។ ឧទាហរណ៍ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបទបញ្ជាទាក់ទងទៅនឹងអដ្ឋិធាតុទាំងនេះនៅចុងឆ្នាំ២០០១÷

ដើម្បីថែរក្សាទុកអដ្ឋិធាតុជាភស្តុតាងនៃឧក្រិដ្ឋកម្មប្រវត្តិសាស្ត្រសម្រាប់ជាមូលដ្ឋានប្រជាពលរដ្ឋកម្ពុជាទាំងមូល ជាពិសេសដល់វ័យជំនាន់ក្រោយឲ្យចងចាំជានិច្ចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់ខ្លោចផ្សានិងដូរចត់បំផុតដែលរបបកម្ពុជាប្រជាធិបតេយ្យ...រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ

១-អាជ្ញាធរដែនដីខេត្តក្រុងទាំងអស់សហការជាមួយមន្ទីរជំនាញជុំវិញខេត្តក្រុង ត្រូវត្រួតពិនិត្យ ជួសជុល និងថែរក្សាឡើងវិញឲ្យបានល្អនូវកន្លែងតម្កល់អដ្ឋិធាតុទាំងឡាយដែលបានធ្វើកន្លងមកហើយ ត្រួតពិនិត្យស្រាវជ្រាវនូវរណ្តៅដែលនៅសេសសល់ដើម្បីរៀបចំកន្លែងទាំងអស់នេះឲ្យទៅជាបូជនីយដ្ឋានដែលមានរបងហ៊ុមព័ទ្ធ មានដាំដើមឈើ និងដាក់ផ្លាកសញ្ញាពត៌មានប្រវត្តិសាស្ត្រឲ្យបានល្អដើម្បីបង្ហាញជូនដល់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរណ៍ ។

គ្មានការទាមទារណាមួយពីខាងព្រះសង្ឃទេ ។ តាមពិតទៅព្រះសង្ឃជាច្រើនហាក់ដូចជាគាំទ្រការថែរក្សាអដ្ឋិធាតុនៅកន្លែងដើម ។ ព្រះសង្ឃរាជវត្តក្រូចសើចព្រះនាម ពេញ សាម៉ន ដែលបានផ្តួចផ្តើមគំនិតឲ្យកសាងបូជនីយដ្ឋានមួយសម្រាប់តម្កល់អដ្ឋិធាតុជនរងគ្រោះដែលយកមកពីគុកសង់នៅក្នុងខេត្តកណ្តាលនៅចុងឆ្នាំ១៩៩៩ បានមានសង្ឃដីកាប្រាប់បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា÷

«មូលហេតុដែលអាត្មាដឹកនាំកសាងបូជនីយដ្ឋាននេះគឺដោយសារញោមប្រុសឪពុករបស់អាត្មាត្រូវសម្លាប់នៅក្នុងគុកសង់នេះ ។ ហេតុផលមួយទៀតគឺថា អាត្មាមើលឃើញអដ្ឋិធាតុទាំងនោះស្ថិតនៅហាលថ្ងៃ ហាលខ្យល់ និងហាលភ្លៀង ។ អដ្ឋិធាតុទាំងនេះពុកផុយនិងត្រូវគោស៊ីម្តងបន្តិចៗ ។ ប្រការទាំងនោះហើយដែលញ៉ាំងចិត្តអាត្មាឲ្យគិតថា ប្រសិនបើអដ្ឋិធាតុទាំងនេះបន្តទុកចោលក្នុងស្ថានភាពបែបនេះ មិនយូរទេមុខជានឹងបាត់បង់អស់ហើយ គ្មានភស្តុតាងបន្សល់ទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានឃើញទេ ។ ក្រៅពីនេះទៀត គ្មានកន្លែងសម្រាប់ឲ្យពុទ្ធបរិស័ទមកអុជធូបគោរពបូជាធ្វើបុណ្យឧទ្ទិសកុសលដល់ព្រលឹងអ្នកដែលបានស្លាប់ទៅ ។ ដូច្នេះទើបអាត្មាបានផ្តួចផ្តើមគំនិតកសាងបូជនីយដ្ឋាននេះសម្រាប់ដាក់អដ្ឋិធាតុ ។

ការបាត់បង់អដ្ឋិធាតុទាំងនេះគឺជាអ្វីដែលអាត្មាព្រួយបារម្ភបំផុត ។ ពីព្រោះថា ប្រសិនបើគ្រប់គ្នានិយាយថា "មានមនុស្សជាច្រើនបានស្លាប់នៅទីនេះ" ប៉ុន្តែបែរគ្មានអដ្ឋិធាតុនៅទីនេះសោះ តើយើងអាចជឿរឿងហ្នឹងបានដែរឬទេ? អាស្រ័យហេតុនេះហើយ ការថែរក្សាអដ្ឋិធាតុជាហេតុផលសំខាន់បំផុត ។ អាត្មាមិនមែនជាអ្នកកសាងបូជនីយដ្ឋាននេះដោយខ្លួនអាត្មាតែម្នាក់ឯងនោះទេ ។ មានមនុស្សជាច្រើនបានចូលរួមជាបច្ច័យ ។ អាត្មាមិនចង់ឲ្យភស្តុតាងបាត់បង់នោះទេ ដូច្នេះប្រជាជនមកពីគ្រប់ទីកន្លែងអាចមកគោរពវិញ្ញាណក្ខន្ធអ្នកស្លាប់ ។ អាត្មាកំពុងតែគិតចង់ឲ្យមានព្រះសង្ឃគង់នៅកន្លែងនោះដើម្បីឲ្យប្រជាជនទាំងអស់បានចូលមកគោរពបូជា ។ ព្រលឹងខ្លះបានពន្យល់សប្តិដល់ឪពុកម្តាយឬកូនចៅ និងប្រាប់ថាព្រលឹងរបស់ខ្លួនកំពុងតែហោះហើរវិលវល់និងមិនបានទៅចាប់កំណើតនៅភពថ្មីទេ ។ អាត្មាចង់ធ្វើឲ្យទីនេះក្លាយជាកន្លែងសមាធិ ដូច្នេះព្រលឹងអ្នកស្លាប់នឹងបានស្ងប់ ។ នៅក្នុងព្រះពុទ្ធសាសនានៅពេលដែលមនុស្សម្នាក់ស្លាប់ ដួងចិត្តរបស់អ្នកនោះស្ថិតនៅក្នុងភពនេះនៅឡើយ ហើយបន្ទាប់មកព្រលឹងអ្នកនោះហោះហើរវិលវល់ចុះឡើងៗ ។ អដ្ឋិធាតុទាំងនេះជាកេរដំណែលសម្រាប់មនុស្សជំនាន់ក្រោយ ។ ដូចនេះ អ្នកជំនាន់ក្រោយអាចបានដឹងថាតើរបបខ្មែរក្រហមសាហាវឃោរឃៅយ៉ាងណាខ្លះពីព្រោះក្មេងជំនាន់ក្រោយមិនបានពើបប្រទះរបបនេះ ។ អាត្មាបានឆ្លងកាត់របបនេះ ។ អ្នកខ្លះបានរស់ឆ្លងកាត់របបនេះនៅក្មេងវ័យនៅឡើយ អ្នកទាំងនោះនៅមិនចង់ជឿ ចុះតើអ្នកដែលមិនបានឆ្លងកាត់ផងនោះអាចជឿបានឬទេ? តើក្មេងជំនាន់ក្រោយអាចជឿបានលើអ្វីទៅ?

បើអាជ្ញាធរទាមទារយកអដ្ឋិធាតុទាំងនេះចេញពីកន្លែងនេះ អាត្មាមិនហ៊ានជំទាស់ទេ ។ អាត្មាគ្រាន់តែស្នើសុំអាជ្ញាធរថា កុំឲ្យបូជាអី ឲ្យទុកអីចឹងចុះ ព្រោះអាត្មាបានធ្វើចេតិយដាក់ ហើយកុំមកប៉ះពាល់អីទៀត ។ បើថាមិនឲ្យសាងសង់កន្លែងហ្នឹងទេ សូមប្រគល់ធាតុឲ្យមកអាត្មាវិញ អាត្មានឹងដង្ហែធាតុទាំងអស់ហ្នឹងមកដាក់នៅ

វត្តរបស់អាត្មា ។ ប៉ុន្តែបើអាជ្ញាធរនៅតែទទូចសុំបូជាអដ្ឋិធាតុទាំងនេះ អាត្មាក៏មិនហ៊ានជំទាស់ដែរ ។ តាមគំនិតរបស់អាត្មា បើសិនអាជ្ញាធរមិនចង់ឲ្យយើងរក្សាទុកអដ្ឋិធាតុនៅទីនោះទេ អាត្មាចង់រក្សាទុកអដ្ឋិធាតុនៅក្នុងវត្តរបស់អាត្មា ដូច្នេះប្រជាជនអាចចូលមកធ្វើបុណ្យទានតាមប្រពៃណីជូនដល់សាច់សាលោហិតរបស់ខ្លួន» ។

ផ្ទុយទៅវិញ ប្រតិកម្មបានចេញមកពីអតីតព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ និងសមាជិកគណបក្សរាជានិយម ហ៊្វុនស៊ិនប៉ិច ។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ អតីតព្រះមហាក្សត្របានសរសេរសំបុត្រទៅសម្តេច ហ៊ុន សែន ស្នើសុំឲ្យមានការរុះរើផែនទីឆ្អឹងលលាដ៍ក្បាលនៅទួលស្លែង និង«បូជាតាមគន្លងព្រះពុទ្ធសាសនា» ធ្វើដូច្នេះទើបព្រលឹងអ្នកស្លាប់បានទៅដល់សុគតិភព ។ ក្រោយមកសម្តេច ហ៊ុន សែន បានបង្ហាញសុឆន្ទៈចង់ឲ្យមានការធ្វើប្រជាមតិថ្នាក់ជាតិមួយទាក់ទងទៅនឹងបញ្ហានេះបន្ទាប់ពីការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម ។

អតីតព្រះមហាក្សត្រក៏បានដាក់បង្ហាញសំបុត្រនោះនៅលើគេហទំព័ររបស់ព្រះអង្គនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៤ ដោយលើកឡើងថា អដ្ឋិធាតុជនរងគ្រោះរបស់របបខ្មែរក្រហមត្រូវបានទុកចោលពាសពេញប្រទេស ។ អតីតព្រះមហាក្សត្របានសរសេរថា ព្រលឹងជនរងគ្រោះនឹង«មិនបានទៅកាន់សុគតិភព និងនៅតែវិលវល់» ហើយថាគួរតែបូជាអដ្ឋិធាតុទាំងនេះនៅទូទាំងប្រទេសតាមប្រពៃណីសាសនា ។



១) លលាដ៍សព TSL13, 2A50700 ភេទៈ ប្រុស អាយុៈពី២៥ - ៤៥ឆ្នាំ ស្នាមរបួសៈ គ្រាប់បាញ់ចូលពីផ្នែកខាងមុខជ្រុងខាងឆ្វេងនៃលលាដ៍ក្បាលសំដៅចុះទៅក្រោមតាមមុំ៤៥ដឺក្រេ កាត់តាមខួរក្បាលពីស្តាំទៅឆ្វេងមានសភាពជារន្ធសោរ (គ្រាប់បៀម) ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ អតីតព្រះមហាក្សត្របានប្រារព្ធខួបទី២៩នៃការដួលរលំនៃរបបខ្មែរក្រហមដោយអំពាវនាវជាថ្មីម្តងទៀតឲ្យមានការបូជាអដ្ឋិធាតុជនរងគ្រោះនៃរបបវាលនេះ ។ នៅក្នុងអត្ថបទបោះពុម្ពផ្សាយថ្ងៃទី១៩ ខែមេសា របស់កាសែតឌឹ ខេមបូឌា ដេលី បានដកស្រង់ព្រះរាជបន្ទូលរបស់អតីតព្រះមហាក្សត្រថា «យើងជាពុទ្ធសាសនិកជនដែលប្រពៃណីនិងជំនឿមានតាំងពីបុរាណកាលមកតែងតែបូជាសពហើយនាំយកធាតុទៅដាក់នៅចេតិយតាមវត្តអារាម» ។

## កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយភាពចម្រូងចម្រាស់

មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំប្រឹងប្រែងសម្រុះសម្រួលរវាងព្រះរាជតម្រិះរបស់ព្រះមហាក្សត្រនិងជំនឿព្រះពុទ្ធសាសនា ដោយសារតែតម្រូវការឲ្យមានការអប់រំជាសាធារណៈ និងតម្រូវការភស្តុតាងកោសល្យវិច័យនៃអំពើប្រល័យពូជសាសន៍ ។ ឧទាហរណ៍ នៅក្នុងឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់ជំនួសផែនទីឆ្អឹងលលាដ៍ ដោយផែនទីកម្ពុជាតាមផ្កាយរណបដែលមានដៅទីតាំងគុកនិងរណ្តៅសាកសពរួមបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ។ អតីតព្រះមហាក្សត្របានសរសេរលិខិតទៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាបន្តបន្ទាប់ថា «ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងកោតសរសើរយ៉ាងកក់ក្តៅនូវគំនិតផ្តួចផ្តើមដ៏ពិសេសថ្លៃថ្លានេះក្នុងការពង្រីកឲ្យឃើញទីតាំងប្រល័យពូជសាសន៍នៅលើផែនទីប្រទេសកម្ពុជាដើម្បីជំនួសផែនទីឆ្អឹងលលាដ៍មានពីមុនមកដែលត្រូវបានដាក់តាំងបង្ហាញនៅឯសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង» ។

នៅក្នុងឆ្នាំ២០០៣ មជ្ឈមណ្ឌលបានផ្តល់ឆ្អឹងលលាដ៍មួយចំនួនធំមកពីជើងឯកនិងមកពីទីកន្លែងនានានៃប្រទេសកម្ពុជាទៅឲ្យក្រុមអ្នកឯកទេសកោសល្យវិច័យឆ្អឹងដែលមកពីអាមេរិកខាងជើងដើម្បីធ្វើកោសល្យវិច័យ ។ អ្នកឯកទេសបានជ្រើសរើសយកឆ្អឹងលលាដ៍ចំនួនដប់មកសិក្សាវិភាគ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៤ មជ្ឈមណ្ឌលឯកសារកម្ពុជាបានតាំងពិព័រណ៍ឆ្អឹងលលាដ៍ទាំងដប់នោះនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ដោយដាក់ចំណងជើងថា «ឆ្អឹងទាំងនេះមិនអាចស្ងប់បានទេ លុះត្រាតែការពិតដែលនាំទៅជាមួយអ្នកទាំងអស់នោះត្រូវបានរកឃើញ»



ពិព័រណ៍នេះបានព្យាយាមបង្ហាញពីតម្លៃកោសល្យវិច័យក្នុងការចងក្រងទុកជាឯកសារនូវអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអប់រំសាធារណជនអំពីប្រភេទពត៌មានទាំងឡាយដែលប្រមូលបានពីអដ្ឋិធាតុជនរងគ្រោះតាមលក្ខណៈវិទ្យាសាស្ត្រ ។

ដើមឡើយ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងដាក់តាំងបង្ហាញឆ្អឹងលលាដ៍ជូនដល់សាធារណជន ប៉ុន្តែចៀសវាងនូវការមិនប្រតិបត្តិតាមព្រះរាជតម្រិះរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ និងប្រជាជនកម្ពុជាដទៃទៀតដែលមានអារម្មណ៍មិនស្រួលក្នុងចិត្តចំពោះការដាក់អដ្ឋិធាតុមនុស្សនៅក្នុងប្រអប់នោះ មជ្ឈមណ្ឌលបានរិះរកដំណោះស្រាយមួយទៀត ។ អាស្រ័យហេតុនេះ មជ្ឈមណ្ឌលបានដាក់ឆ្អឹងលលាដ៍ទាំងនេះនៅក្នុងបន្ទប់មួយដាច់ដោយឡែកនៅទួលស្លែង ដែលបើកជូនទស្សនាតែចំពោះមន្ត្រីនានា (ឧទាហរណ៍ ព្រះរាជអាជ្ញានៅក្នុងតុលាការខ្មែរក្រហម) ។ ការរៀបចំទុកដាក់ឆ្អឹងលលាដ៍ចុងក្រោយនឹងត្រូវកំណត់នៅពេលណាដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានបញ្ចប់ ។

ឆ្អឹងលលាដ៍ត្រូវបានដាក់នៅក្នុងជើងទម្រដូចៗគ្នាធ្វើអំពីបន្ទះឈើតូចៗនិងស្តើងៗពីរជាន់ និងមានទុកចន្លោះប៉ុនចង្អុលដៃនៅជ្រុងទាំងបួននៃទម្រដើម្បីឲ្យខ្យល់អាចចេញចូលប៉ះលលាដ៍នោះ និងអាចឲ្យព្រលឹងជនរងគ្រោះទាំងនោះចេញចូលប្រអប់បានតាមប្រាថ្នា ។ ដើម្បីការពារលលាដ៍ទាំងនោះ មជ្ឈមណ្ឌលបានយកប្រអប់កញ្ចក់រាងការ៉េមកគ្របពីលើ រួចបិទភ្ជាប់ទៅនឹងទម្រដោយការបិទកញ្ចក់ ។ ប្រអប់កញ្ចក់នេះអាចយកចេញបានដោយគ្រាន់តែប្រើឡាមចៀរការបិទកញ្ចក់ចេញ ដូច្នេះយើងអាចសម្អាតបុប្ផូរទីតាំងលលាដ៍បាន ។ មជ្ឈមណ្ឌលបានថតរូបឆ្អឹងលលាដ៍ទាំងនេះទុក ដោយមានភ្ជាប់សេចក្តីពន្យល់អំពីប្រភេទនៃការប៉ះទង្គិចចំពោះលលាដ៍ក្បាលនីមួយៗផង ។

អតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានស្នើសុំឲ្យកសាងចេតិយមួយនៅអតីតរាជធានីឧដុង្គដើម្បីដាក់ធាតុដែលបានមកពីការបូជាឆ្អឹង ។ នៅពេលណាដែលតុលាការខ្មែរក្រហមបញ្ចប់ពេលនោះប្រហែលជាមានលទ្ធភាពធ្វើឲ្យជនរងគ្រោះបានស្ងប់ បន្ទាប់ពីរយៈពេលជាង១ភាគ៤នៃទសវត្សរ៍នៃអំពើប្រល័យពូជសាសន៍ ។

**ខេននី ឌូចហ្គៀល**

# រ្វ៉ាន់ដាៈ តើមានសង្ឃឹមសម្រាប់ប្រទេសនេះដែរឬទេ?

**(តពីលេខមុន)**

**ខ) ការដួលរលំសេដ្ឋកិច្ច និងគោលនយោបាយរបស់អង្គការរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោក**

បន្ថែមពីលើបញ្ហាកន្ទុះដីដាំដំណាំគឺការដើរថយក្រោយនៃសេដ្ឋកិច្ចនិងកម្មវិធីកំណែទម្រង់យុទ្ធសាស្ត្ររបស់អង្គការរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកដែលមិនមានការគាំទ្រពីសំណាក់មជ្ឈដ្ឋានខាងក្រៅ ។ បន្ទាប់ពីសេដ្ឋកិច្ចកើនឡើងអស់រយៈពេលមួយទសវត្សរ៍ រ្វ៉ាន់ដាបែរជាមានបញ្ហាសេដ្ឋកិច្ចមួយយ៉ាងធ្ងន់ធ្ងរនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ផលដ៏ស្លួចស្លើងនៃដំណាំដាំដុះនិងចំនួនជនភៀសខ្លួនដ៏សន្ធឹកសន្ធាប់ពីប្រទេសប៊ូរុនឌីនៅឆ្នាំ១៩៨៨ បានបណ្តាលឲ្យផែនការតម្លៃទំនិញរបស់រដ្ឋាភិបាលរ្វ៉ាន់ដាបរាជ័យ ។ នៅឆ្នាំ១៩៨៩ ការធ្លាក់ចុះនៃតម្លៃកាហ្វេអន្តរជាតិ (ដែលបណ្តាលមកពីសម្ពាធនយោបាយពីសំណាក់ទីក្រុងវ៉ាស៊ីនតោនធ្វើក្នុងនាមឈ្មួញកាហ្វេធំៗរបស់សហរដ្ឋអាមេរិក) ធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកចម្ការកាហ្វេតូចតាចនៅរ្វ៉ាន់ដារហូតដល់ទៅជាង៦០ភាគរយ ។ គ្រាន់តែរយៈពេលបីខែមុនពេលការឈ្លានពានរបស់«រណសិរ្សស្នេហាជាតិរ្វ៉ាន់ដា» នៅខែតុលាឆ្នាំ១៩៩០ របបហាប៊ីយ៉ារីម៉ាណាទទួលរងការគាបសង្កត់យ៉ាងធ្ងន់ធ្ងរពីសហគមន៍សេដ្ឋកិច្ចអឺរ៉ុប (European Economic Community) ហើយក៏យល់ព្រមទទួលយកកំណែទម្រង់នយោបាយទាំងនោះ ដែលបណ្តាលឲ្យតម្លៃទំនិញនិងភាពអត់ការងារកើនឡើងភ្លាមៗ ។ បន្ទាប់មក ប្រជាជនរ្វ៉ាន់ដាបានផ្តន្ទាទោសរបបហាប៊ីយ៉ារីម៉ាណាដែលបានលក់ប្រទេសរបស់ខ្លួនទៅឲ្យ «ក្លិបប៉ារីសរបស់អ្នកផ្តល់ប្រាក់កម្ចី» គណៈកម្មការអឺរ៉ុប និងធនាគារពិភពលោក ។

សង្គ្រាមស៊ីវិលជាមួយ«រណសិរ្សស្នេហាជាតិរ្វ៉ាន់ដា» រឹតតែធ្វើឲ្យសេដ្ឋកិច្ចដែលខ្ទេចខ្ទាំរួចស្រេចទៅហើយនោះមានបញ្ហាធ្ងន់ធ្ងរថែមទៀតតាមរយៈការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាលឲ្យមនុស្សរាប់ម៉ឺននាក់ត្រូវផ្លាស់ប្តូរទីកន្លែងរស់នៅ ។ មកដល់ចុងឆ្នាំ១៩៩៣ ក្នុងចំណោមប្រជាជនរ្វ៉ាន់ដា៧នាក់ មានម្នាក់រស់នៅក្នុងជំរំដែលខ្វះខាតស្បៀងអាហារនិងមានជំងឺធ្ងន់ធ្ងរ ។ ភាពក្រីក្រនិងភាពច្របូកច្របល់ផ្នែកសេដ្ឋកិច្ចបានបង្កឲ្យសង្គមរ្វ៉ាន់ដាក្លាយទៅជាសង្គមក្រីក្រនិងសម្បូរដោយអ្នកប្រព្រឹត្តអំពើទុច្ចរិត ។ តាមរយៈនេះ ជនជ្រុលនិយមហ៊ូទូមានភាពងាយស្រួលក្នុងការបញ្ចុះបញ្ចូលអ្នកប្រព្រឹត្តអំពើទុច្ចរិតទាំងនោះឲ្យចូលបម្រើយោធា ។ ឧទាហរណ៍មួយដែលល្បីល្បាញបំផុតគឺ «អ៊ីនថឺអាហាមេ» មានន័យថា «អ្នកចូលរួមប្រយុទ្ធជាមួយគ្នា» ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៩២ ដែលក្រោយមកបានក្លាយជាមូលហេតុចម្បងក្នុងការនាំឲ្យមានអំពើប្រល័យពូជសាសន៍ ។ ក្នុងនោះដែរ អ្នកនយោបាយឆ្លៀតឱកាសជាច្រើនក៏បានប្រើប្រាស់សង្គ្រាមស៊ីវិលនោះជាមធ្យោបាយដើម្បីបង្វែរការស្អប់ខ្ពើមរបស់មហាជនពីកំណែទម្រង់យោបាយសេដ្ឋកិច្ច (ខ្លួនឯង) ទៅលើ «រណសិរ្សស្នេហាជាតិរ្វ៉ាន់ដា»និងទៅលើក្រុមទុតស៊ី ។ នៅក្នុងស្ថានភាពពិតការយល់ឃើញបែបនេះគឺជាការប្រឌិតសុទ្ធសាធ ៖ អ្នកដែលមានបុព្វសិទ្ធិពិតប្រាកដគឺជាក្រុមហ៊ូទូ មិនមែនក្រុមទុតស៊ីទេ ជាពិសេសអ្នកដែលមកពីតំបន់ពាយ័ព្យរបស់ប្រធានាធិបតីហាប៊ីយ៉ារីម៉ាណា ។ ក៏ប៉ុន្តែ គោលនយោបាយជាតិពន្ធុនេះបានទទួលជោគជ័យលើការពិត ។ ដូចដែលបានរកឃើញដោយ ធីម៉ូស៊ី ឡុងមែន ការសម្លាប់រង្គាលនៅអំឡុងពេលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅរ្វ៉ាន់ដាគឺភាគច្រើនកើតឡើងនៅក្នុងតំបន់ដែលមានគម្លាតសេដ្ឋកិច្ចខ្លាំងនិងនៅតំបន់ដែលមានការព្រួយបារម្ភខ្លាចបាត់បង់កម្មសិទ្ធិដីខ្លាំង ។

**គ) ការដួលរលំនៃរបបហាប៊ីយ៉ារីម៉ាណា និងការជ្រកក្រោមផ្លាកប្រជាធិបតេយ្យ**

បើគិតត្រឹមថ្នាក់នយោបាយជាតិ សង្គ្រាមស៊ីវិលជាមួយ «រណសិរ្សស្នេហាជាតិរ៉ាន់ដា» បានបណ្តាលឲ្យនយោបាយនៅរ៉ាន់ដាបែកខ្ញែកជាពីរផ្នែក និងបានបង្កើនឥទ្ធិពលនៃចលនាជ្រុលនិយមរបស់ក្រុមហ៊ូទូ ។ តាមរយៈយុទ្ធវិធីក្នុងការកាត់បន្ថយបញ្ហាវើសអើងជាតិពន្ធនិងការយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច គណបក្សកាន់អំណាចរបស់ហាប៊ីយ៉ារីម៉ាណាដែលហៅថា «គណបក្សចលនាសាធារណរដ្ឋប្រជាធិបតេយ្យ» (MRND) អាចគ្រង់គ្រងរ៉ាន់ដាយ៉ាងសប្បាយជាមួយនឹងប្រជាប្រិយភាព និងការគាំទ្រពីសំណាក់អន្តរជាតិ ។ ប៉ុន្តែវិបត្តិសេដ្ឋកិច្ចនៅចុងទសវត្សន៍ឆ្នាំ១៩៨០ និងចលនាកំណែទម្រង់នយោបាយដែលបានរីកសាយភាយនៅពាសពេញផ្ទៃប្រទេសនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បានគំរាមកំហែងដល់ការគ្រប់គ្រងអំណាចផ្តាច់មុខរបស់របបនេះ ។ ការវាយប្រហាររបស់ «រណសិរ្សស្នេហាជាតិរ៉ាន់ដា» កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩០ បានផ្តល់ឱកាសឲ្យរបបនេះធ្វើឲ្យការគ្រប់គ្រងអំណាចរបស់ខ្លួនមានភាពស្របច្បាប់ឡើងវិញក្នុងនាមជាអ្នកការពារប្រទេសពីការគំរាមកំហែងរបស់ក្រុមទុតស៊ី ។

ដូចដែលខ្ញុំបានបកស្រាយនៅផ្នែកមុនរួចមកហើយ ប្រធានាធិបតី ហាប៊ីយ៉ារីម៉ាណា ចេញមុខនិយាយថា ក្រុមទុតស៊ីដែលជាក្រុមជាតិពន្ធមួយរបស់រ៉ាន់ដា មិនមែនជាជនបរទេសទេ ហើយការផ្លាស់ប្តូរភាសានយោបាយបានផ្តល់ការផ្សះផ្សាជាតិមួយយ៉ាងសម្បើមនៅក្នុងប្រទេសនេះ ។ ជាក់ស្តែង នៅក្រោមការគ្រប់គ្រងរបស់ដាមេហ៊ូទូ ជនជាតិហ៊ូទូភាគច្រើនគាំទ្រក្រុម«អំណាចហ៊ូទូ» (អ្នកនយោបាយហ៊ូទូជ្រុលនិយមមួយក្រុម) ដែលបានប្រកាសថា ក្រុមហ៊ូទូមិនត្រឹមតែប្រជាជនប្រជាធិបតេយ្យភាគច្រើនប៉ុណ្ណោះទេ ប៉ុន្តែជាជាតិរ៉ាន់ដាផ្ទាល់ទៀតផង ។ មកដល់ចុងទសវត្សរ៍ ឆ្នាំ១៩៨០ ពោលគឺបន្ទាប់ពីរយៈពេល១៥ឆ្នាំនៃការគ្រប់គ្រងអំណាចរបស់សាធារណរដ្ឋទីពីររួចមក មានប្រជាជនហ៊ូទូតែប៉ុន្មានភាគប៉ុណ្ណោះដែលបន្តគាំទ្រមនោគមវិជ្ជានេះ ។ បន្ទាប់មក សង្គ្រាមស៊ីវិលបានបណ្តាលឲ្យមានការវិលត្រឡប់មកវិញនូវមនោគមវិជ្ជា«អំណាចហ៊ូទូ» ហើយបានធ្វើឲ្យនយោបាយនៅរ៉ាន់ដាបែកខ្ញែកជាពីរបក្សផ្សេងគ្នា គឺក្រុមអំណាចជ្រុលនិយមហ៊ូទូនិងក្រុមហ៊ូទូនិយមកណ្តាលដែលគាំទ្រការចែករំលែកអំណាចជាមួយ«រណសិរ្សស្នេហាជាតិរ៉ាន់ដា» ។

អ្វីដែលគួរឲ្យអស់សំណើចនោះគឺ ដំណើរការបង្កើតប្រជាធិបតេយ្យនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បែរជាធ្វើឲ្យមនោគមវិជ្ជា «អំណាចហ៊ូទូ»មានឥទ្ធិពលកាន់តែខ្លាំងឡើងនៅរ៉ាន់ដា ។ នៅក្នុងពេលជាមួយគ្នានោះ រដ្ឋាភិបាលរ៉ាន់ដាបានអនុម័តកំណែទម្រង់សេដ្ឋកិច្ចមួយដែលក្នុងនោះសហគមន៍ម្ចាស់ជំនួយអន្តរជាតិបានជំរុញឲ្យរដ្ឋាភិបាលរ៉ាន់ដាមានប្រជាធិបតេយ្យភាពតាមរយៈការគ្រប់គ្រងដោយគណបក្សចម្រុះ ។ ប៉ុន្តែ នៅអំឡុងពេលមានសង្គ្រាមស៊ីវិល ការប្រកួតប្រជែងអំណាចគ្នារវាងពហុបក្សបានធ្វើឲ្យប្រទេសរ៉ាន់ដាធ្លាក់ទៅក្នុងសភាពតានតឹង ព្រមទាំងផ្តល់ឱកាសយ៉ាងស្របច្បាប់ឲ្យក្រុមហ៊ូទូក្នុងការរៀបចំស្ថាប័នផ្សេងៗរបស់ខ្លួន និងក្នុងការបង្កើនលទ្ធភាពសម្រេចឲ្យបាននូវនយោបាយឯករាជ្យ ។ អាចនិយាយបានម្យ៉ាងទៀតថា ប្រជាធិបតេយ្យនៅក្នុងបរិបទនៃសង្គ្រាមស៊ីវិលបានក្លាយទៅជាហេតុផលនយោបាយសម្រាប់ហ៊ូទូនិយមកណ្តាលនៅរ៉ាន់ដាទៅវិញទេ ។

## ៦) ការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ៈ មូលហេតុ និងការវិវត្ត

### ក) បរាជ័យរបស់កិច្ចព្រមព្រៀងក្រុងអារូហ្សា និងវិបត្តិនយោបាយនៅប៊ូរុនឌី

ចំណុចសំខាន់សម្រាប់ក្រុម «អំណាចហ៊ូទូ» នៅក្នុងគោលនយោបាយរ៉ាន់ដាគឺ «កិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សា» ដែលចុះហត្ថលេខាដោយរដ្ឋាភិបាលរ៉ាន់ដា (ដែលកាន់អំណាចដោយក្រុមហ៊ូទូ) និង «រណសិរ្សស្នេហាជាតិរ៉ាន់ដា» (ក្រុមទុតស៊ី) កាលពីខែសីហា ឆ្នាំ១៩៩៣ ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនោះត្រូវបរាជ័យតាំងពីពេលចាប់ផ្តើមដំបូងម្ល៉េះ ដោយសារតែមិនបានបញ្ចូលផលប្រយោជន៍របស់ក្រុមជ្រុលនិយម ។ ជាក់ស្តែង ខចែងអំពីការធ្វើសមាហរណកម្មទាហានទាំងសងខាងបញ្ចូលគ្នាបានអនុញ្ញាតឲ្យរណសិរ្សស្នេហាជាតិរ៉ាន់ដាបញ្ចូលកងទ័ពរបស់ខ្លួនទៅក្នុងចំនួនពាក់កណ្តាលនៃកងកម្លាំង

ទាហានជាតិដែលបង្កើតថ្មីៗ ប៉ុន្តែ បើយើងពិនិត្យមើលការណ៍ដែលថាកងទ័ពរ៉្វាន់ដាត្រូវបានពង្រីកឲ្យធំជាងមុនចំនួន៦ដងចាប់តាំងពីឆ្នាំ១៩៩០មក ខណៈពេលដែលឃើងខាងលើនឹងធ្វើឲ្យទាហានហ៊ូទូជាច្រើននាក់បាត់បង់ការងារ ។ កិច្ចព្រមព្រៀងនេះក៏បានអនុញ្ញាតឲ្យរណសិរ្សស្នេហាជាតិរ៉្វាន់ដាកាន់កាប់ក្រសួងមហាផ្ទៃ ហើយអ្វីដែលមានសារសំខាន់បំផុតនោះគឺកិច្ចព្រមព្រៀងនេះមិនបានផ្តល់ឲ្យគណបក្សជ្រុលនិយមរបស់ក្រុមហ៊ូទូនូវអាសនៈនៅក្នុងសភាទេ ។ ការមិនផ្តល់អំណាចនយោបាយដល់ក្រុមហ៊ូទូជ្រុលនិយមបានធ្វើឲ្យក្រុមនេះប្រឹងប្រែងកាន់តែខ្លាំងក្លាជាងមុនក្នុងការធ្វើឲ្យ «កិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សា» ទទួលបរាជ័យ និងក្នុងការកម្ទេចក្រុមហ៊ូទូនិយមកណ្តាលនិងក្រុមទុតស៊ីដែលស្រលាញ់សន្តិភាព ។ តាមរយៈការចោទប្រកាន់ថាគណបក្សប្រឆាំងទាំងអស់មានទំនោរទៅរកក្រុមរណសិរ្សស្នេហាជាតិរ៉្វាន់ដានិងការដាក់ឈ្មោះគណបក្សប្រឆាំងទាំងនោះថាជាជនក្បត់ជាតិ ក្រុម«អំណាចហ៊ូទូ» បានទទួលជោគជ័យក្នុងការបញ្ចុះបញ្ចូលប្រជាជនមួយចំនួនធំឲ្យមានទស្សនៈអវិជ្ជមានចំពោះក្រុមហ៊ូទូនិយមកណ្តាល ។ ជាការពិត «កិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សា» គឺជាការធ្វើអត្តឃាតខ្លួនឯងរបស់របប ហាប៊ីយ៉ារីម៉ាណា ដោយសារក្រុមហ៊ូទូនិយមជ្រុលបានចោទប្រកាន់ គាត់ថាជាជនក្បត់ជាតិ ដូច្នេះហើយអនាគតនយោបាយនិយមកណ្តាលរបស់គាត់ត្រូវរាំងស្ទះ ។ អ្វីដែលកាន់តែអាក្រក់ជាងនេះទៅទៀតគឺ សហគមន៍អន្តរជាតិបានដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលដែលកំពុងតែមានបញ្ហារួចទៅហើយនោះឲ្យពង្រឹងសន្តិភាពភ្លាមៗដោយមិនបានផ្តល់ជាមធ្យោបាយដាក់ស្តែងដល់កិច្ចការនេះឡើយ ។ សហគមន៍អន្តរជាតិបានគំរាមថា ប្រសិនបើរដ្ឋាភិបាលរ៉្វាន់ដានៅពេលនោះពុំព្រមអនុវត្តតាមទេ សហគមន៍អន្តរជាតិនឹងផ្អាកការផ្តល់ជំនួយដល់រ៉្វាន់ដា ។ ដូចដែល ផនដ័រ បានពន្យល់ថា ការណ៍នេះបានធ្វើឲ្យរ៉្វាន់ដាក្លាយទៅជា «ប្រទេសមួយដែលកំពុងតែត្រូវក្តួងក្បាលដោយកាំភ្លើងរបស់រណសិរ្សស្នេហាជាតិរ៉្វាន់ដា សហរដ្ឋអាមេរិក បែលហ្ស៊ិក ចក្រភពអង់គ្លេស អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងអង្គការរូបិយវត្ថុអន្តរជាតិ» ។

ពេលវេលាចុងក្រោយបំផុតសម្រាប់ជនជ្រុលនិយមបានមកដល់ជាមួយនឹងការសម្លាប់ប្រធានាធិបតីដើមកំណើតហ៊ូទូរបស់ប្រទេសប៊ូរុនឌីដែលមានឈ្មោះថា មែលឆ័រ ដាដាយេ ។ នៅក្រោយឆ្នាំ១៩៥៩ រ៉្វាន់ដាបានមើលឃើញថាខ្លួននឹងមានអនាគតដូចប្រទេសប៊ូរុនឌីប្រសិនបើបន្តរស់នៅក្រោមឥទ្ធិពលរបស់ក្រុមទុតស៊ី ។ ដូចដែលបង្ហាញរួចហើយ ការសម្លាប់រង្គាលសិស្សនិងបញ្ញវន្តហ៊ូទូចំនួន២សែននាក់កាលពីឆ្នាំ១៩៧២បានបន្តទៅជាអំពើហិង្សាជាតិពន្ធប្រឆាំងនឹងក្រុមទុតស៊ីនៅក្នុងប្រទេសរ៉្វាន់ដា ។ ដូច្នេះហើយ នៅពេលដែល ដាដាយេ ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានាធិបតីដើមកំណើតហ៊ូទូទីមួយនៅក្នុងប្រទេសប៊ូរុនឌីកាលពីឆ្នាំ១៩៩៣ ប្រជាជនរ៉្វាន់ដាសង្ឃឹមថាព្រឹត្តិការណ៍នេះជាសញ្ញាវិជ្ជមានមួយសម្រាប់ការរស់នៅយ៉ាងសុខដុមរម្យនារវាងក្រុមហ៊ូទូនិងទុតស៊ី ។ ប៉ុន្តែបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពតែពីរខែប៉ុណ្ណោះ ទាហានទុតស៊ីបានធ្វើឃាត ដាដាយេ ។ នេះជាព្រឹត្តិការណ៍មួយដែលបានបន្តជាអំពើហិង្សានយោបាយបន្ថែមទៀត ។ ជនហ៊ូទូប្រមាណ២សែននាក់បានភៀសខ្លួនទៅកាន់ប្រទេសរ៉្វាន់ដា ។ នៅក្នុងក្រសែភ្នែករបស់អ្នកនយោបាយហ៊ូទូនៅក្នុងប្រទេសរ៉្វាន់ដា ព្រឹត្តការណ៍នេះជាសារយ៉ាងច្បាស់និងយ៉ាងសាមញ្ញថា «ប្រវត្តិសាស្ត្របានបង្ហាញថា ក្រុមហ៊ូទូនិងទុតស៊ីមិនអាចរស់នៅជាមួយគ្នាដោយសន្តិភាពទេ» ។ ជាលទ្ធផល វិបត្តិនៅក្នុងប្រទេសប៊ូរុនឌីបាននាំទៅដល់ការបែងចែកនយោបាយយ៉ាងខ្លាំង ដែលក្នុងនោះអ្នកនយោបាយហ៊ូទូនិយមកណ្តាលយ៉ាងច្រើនបានចូលរួមជាមួយក្រុម«អំណាចហ៊ូទូ» ។

## ៧) ទិសដៅនយោបាយនៃអំពើប្រល័យពូជសាសន៍

ទោះជាយ៉ាងណាក៏ដោយ ការពន្យល់អំពីការកើនឡើងនូវនិន្នាការប្រល័យពូជសាសន៍នៅក្នុងបរិបទរបស់កិច្ចព្រមព្រៀងសន្តិភាពក្រុងអារូហ្សានិងវិបត្តិនៅក្នុងប្រទេសប៊ូរុនឌី មិនមែនដើម្បីអះអាងថាអំពើប្រល័យពូជសាសន៍គឺជាលទ្ធផលនយោបាយដែលមិនអាចចៀសវាងបាននោះទេ។ ក្រុម «អំណាចហ៊ូទូ» បានជ្រើសរើសយកអំពើប្រល័យពូជសាសន៍ជាមធ្យោបាយសម្រេច

គោលដៅនយោបាយរបស់ខ្លួន ។ គោលដៅនយោបាយរបស់ក្រុមនេះគឺលុបបំបាត់ជនទុតស៊ីដែលត្រូវបានសន្មតថាជាអ្នកគាំទ្ររណសិរ្សស្នេហាជាតិរ៉្វាន់ដា និងជនហ៊ូទូនិយមកណ្តាលទាំងអស់ដែលគាំទ្រគំនិតថាកិច្ចព្រមព្រៀងសន្តិភាពក្រុងអារូហ្សាជាដំណោះស្រាយសង្គ្រាមស៊ីវិលនៅរ៉្វាន់ដា ។ ម៉ាំដានី បាននិយាយថា «ជនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍បានជ្រើសរើសយកការស្លាប់ជាជាងរស់នៅដោយគ្មានអំណាច ។ នៅពេលដែលបានសម្រេចចិត្តជ្រើសរើសយ៉ាងនេះ អ្នកទាំងនោះបានចាប់ផ្តើមរៀបចំផែនការសម្លាប់មនុស្សជាខ្សែសង្វាក់ ។ ជនប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទាំងនេះបានបង្កើតនិងពង្រីកកងឈ្លប ទិញកាំភ្លើង កាំបិត និងបង្ហឹកយុវជនវ័យក្មេងឲ្យចេះសម្លាប់សត្រូវ ។ បើយោងទៅតាម រេនេ ឡឺម៉ាហ្សង់ ទម្រង់នៃអំពើប្រល័យពូជសាសន៍មានរួចជាស្រេចទៅហើយតាំងពីឆ្នាំ១៩៩២មកម្ល៉េះ ។ អ្នកនយោបាយជ្រុលនិយមបានបង្កើតជា«អង្គភាពការពារខ្លួន» នៅគ្រប់ភូមិឃុំទាំងអស់ ដែលនៅទីនោះពួកគេបង្ហឹកមនុស្សទាំងក្មេងទាំងចាស់ឲ្យសម្លាប់សត្រូវ ។ ជាក់ស្តែង បុរសទុតស៊ីម្នាក់នៅអឺនតាំហ៊ាំម៉ា ដែល ម៉ាំដានី បានសម្ភាសកាលពីឆ្នាំ១៩៩៥ បានផ្តល់សក្ខីភាពថាៈ

«ការសម្លាប់គឺមានគម្រោងទុកជាមុន ដោយសារមានការចែកកាំភ្លើង ។ នៅក្នុងពេលមានសង្គ្រាមជាមួយរណសិរ្សស្នេហាជាតិរ៉្វាន់ដា បុរសវ័យក្មេងជាច្រើនត្រូវបានជ្រើសរើសឲ្យធ្វើជាទាហានបម្រុង និងត្រូវបង្ហឹកឲ្យកាន់កាំភ្លើង ។ បន្ទាប់ពីការហ្វឹកហ្វឺន បុរសវ័យក្មេងទាំងនោះនឹងផ្តាច់ខ្លួនចេញពីក្រុមទុតស៊ី ។ មិត្តភក្តិរបស់ខ្ញុំមួយចំនួនបានចូលរួមក្នុងការហ្វឹកហ្វឺននេះ ។ នៅពេលត្រឡប់មកវិញ អ្នកទាំងនោះខ្ញុំមិនដែលមានពេលមកលេងខ្ញុំទេ ព្រោះរវល់តែដើរបញ្ចុះបញ្ចូលអ្នកដទៃទៀតឲ្យចូលរួមក្នុងការហ្វឹកហ្វឺនដែរ» ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទរបស់សង្គ្រាមស៊ីវិល ផែនការណ៍ទាំងនេះមុនដំបូងមិនត្រូវបានបង្កើតឡើងក្នុងគោលបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ប៉ុន្តែដើម្បីបម្រើគោលដៅនេះនៅពេលដែលខ្លួនចាញ់សង្គ្រាម ។ នៅក្នុងគំនិតរបស់ជនហ៊ូទូធម្មតា សង្គ្រាមបានធ្វើឲ្យអាជ្ញាធរកាន់អំណាចមានភាពស្របច្បាប់ និងបង្កើនឆន្ទៈក្នុងការចូលរួមការហ្វឹកហ្វឺនទាហាន ។

យើងមិនអាចមើលរំលងការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការញុះញង់ឲ្យជនហ៊ូទូធម្មតាចូលរួមនៅក្នុងប្រតិបត្តិការប្រល័យពូជសាសន៍នេះទេ ។ អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាមិនមែនជា «ការបញ្ចេញកំហឹងតបតភ្លាមៗរបស់អ្នកដែលត្រូវគេធ្វើបាប» នៅក្នុងស្ថានភាពអានាធិបតេយ្យដូចអ្នកខ្លះបានលើកឡើងនោះទេ ។ អង្គរក្សរបស់ប្រធានាធិបតី ប៉ូលិសជាតិ និងក្រុមខុទ្ទាមអ៊ីនថឺរ៉ាហាមវី (ក្រុមខុទ្ទាមហ៊ូទូ) ដែលត្រូវបានបញ្ជូនចេញពីទីក្រុង បានចាប់ផ្តើមចេញបញ្ជាឲ្យសម្លាប់រង្គាលមនុស្សដោយប្រើកាំបិត ។ ក្រុមនេះក៏បានដឹកជញ្ជូនអាវុធ ប្រមូលផ្តុំជនទុតស៊ីនៅតាមទីសាធារណៈ និងសម្លាប់ជនទុតស៊ីទាំងនោះរួចទើបកប់សាកសពទាំងនោះតាមក្រោយ ។ នៅកន្លែងខ្លះ ដូចជានៅប៊ូតារ៉េ ជនហ៊ូទូជាច្រើនបានបដិសេធមិនចូលរួមនៅក្នុងប្រតិបត្តិការប្រល័យពូជសាសន៍នេះ ប៉ុន្តែអ្នកទាំងនោះបានទទួលរងនូវការគំរាមកំហែងពីសំណាក់ទាហាន ។ សហគមន៍ទាំងមូលនៅខាងកើតបឹងគីវូ ដែលក្នុងនោះមានជនទុតស៊ី ហ៊ូទូ និងត្វា កាលពីដំបូងធ្លាប់ប្រយុទ្ធប្រឆាំងនឹងក្រុមខុទ្ទាមអ៊ីនធែរ៉ាហាមវីជាមួយគ្នា ប៉ុន្តែក្រោយមក ក្រុមខុទ្ទាមអ៊ីនធែរ៉ាហាមវីបានគំរាមកំហែងនិងផ្តល់សម្ភារផ្សេងដល់ជនហ៊ូទូនៅក្នុងសហគមន៍នោះឲ្យសម្លាប់ជនទុតស៊ីដែលជាអ្នកជិតខាងរបស់ខ្លួន ។ ជាការពិត អំពើប្រល័យពូជសាសន៍ប្រហែលជាមិនបានកើតឡើងនោះទេប្រសិនបើរដ្ឋាភិបាលនិយមជ្រុលមួយនេះមិនបានរៀបចំការសម្លាប់មនុស្សជាខ្សែសង្វាក់យ៉ាងល្អិតល្អន់ ។

## គ) ទំហំនិងទ្រង់ទ្រាយនៃការចូលរួមរបស់ប្រជាជន

អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉្វាន់ដាមិនមែនគ្រាន់តែជាគម្រោងរបស់រដ្ឋប៉ុណ្ណោះទេ ។ ទោះបីរដ្ឋអំណាចជាអ្នករៀបចំគម្រោងនៃការសម្លាប់នោះក៏ដោយ ក៏វាតម្រូវឲ្យមានការចូលរួមរបស់ប្រជាជនថែមទៀតដើម្បីអាចសម្លាប់មនុស្ស ៨០ម៉ឺននាក់នៅក្នុងរយៈពេលមិនដល់១០០ថ្ងៃដូច្នេះ ។ អំពើ

ប្រល័យពូជសាសន៍នៅរ៉្វាន់ដាខុសគ្នាពីការសម្លាប់រង្គាលរបស់ក្រុមណាហ្ស៊ីនៅអាល្លឺម៉ង់បើពិនិត្យមើលទៅលើទំហំនិងលក្ខណៈនៃការចូលរួមរបស់ប្រជាជន។ ជំនួសឲ្យការប្រើបច្ចេកវិទ្យាទំនើបដើម្បីសម្លាប់មនុស្សដូចជាការប្រើប្រាស់ផ្សែងពុលជាដើម ជនដៃដល់នៃអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាស្ទើរតែទាំងអស់បានប្រើប្រាស់កាំបិតជាអាវុធសម្លាប់មនុស្ស។ នេះមានន័យថា ជនដៃដល់ត្រូវតែកាប់ជាច្រើនកាំបិតដើម្បីសម្លាប់មនុស្សម្នាក់ ហើយនេះក៏មានន័យថា ដើម្បីសម្លាប់មនុស្ស១សែននាក់ យ៉ាងហោចណាស់ក៏ត្រូវមានជនដៃដល់ជាច្រើនពាន់នាក់ដែរ។ បើយោងទៅតាមការសម្ភាសរបស់ ម៉ាំដានី កាលពីឆ្នាំ១៩៩៥ បុរសទុតស៊ីម្នាក់បានផ្តល់សក្ខីភាពថា នៅក្នុងទីក្រុងដែលគាត់រស់នៅ បុរសទាំងអស់នៅក្នុងចំណោមជនហ៊ូទូចំនួន ៣.៥០០នាក់ បានចូលរួមក្នុងការសម្លាប់មនុស្ស។ ម៉ាំដានី បានសរសេរថាៈ

*នរណាខ្លះជាឃាតករនៅអ៊ីនតារ៉ាម៉ា? អង្គរក្សរបស់ប្រធានាធិបតីជាច្រើនអង្គភាពបានធ្វើដំណើរមកពីទីក្រុងឃីហ្គាលី។ ក្រុមខុទ្ទាមអ៊ីនធែរ៉ាហាមវីត្រូវបានបញ្ជូនមកពីសហគមន៍ជិតខាង។ យុវជនដែលត្រូវបានបង្ហឹកនៅក្នុង «អង្គភាពការពារខ្លួន» បានចូលរួមនៅក្នុងកងកម្លាំងមូលដ្ឋានបន្ទាប់ពីសង្គ្រាមស៊ីវិល។ ប៉ុន្តែអ្វីដែលជាការពិតនោះគឺថា អ្នកទាំងនេះបានចូលរួមនៅក្នុងការសម្លាប់រង្គាលនេះ។ មិនត្រឹមតែបុរសប៉ុណ្ណោះទេ ស្ត្រីក៏បានចូលរួមចំណែកដែរ។ ស្ត្រីបានសាទរចំពោះសកម្មភាពសម្លាប់មនុស្សរបស់ប្តីនិងក្រុមគ្រួសាររបស់ខ្លួន។*

ការសម្លាប់រង្គាលមិនមែនកើតឡើងតែនៅក្នុងជំរំដាច់ស្រយាលប៉ុណ្ណោះទេ ប៉ុន្តែកើតឡើងនៅក្នុងសាលារៀន ព្រះវិហារសាសនាគ្រិស្ត និងមន្ទីរពេទ្យ ជាកន្លែងដែលជនរងគ្រោះរត់ទៅស្នាក់អាស្រ័យ។ ជនរងគ្រោះត្រូវបានអ្នកជិតខាងរបស់ខ្លួនកាត់អវៈយវៈ ដុតដោយភ្លើង និងរំលោភផ្លូវភេទ នៅតាមទីសាធារណៈ។ វេជ្ជបណ្ឌិតមួយចំនួនបានសម្លាប់អ្នកជំងឺ សហការីនិងអ្នកជិតខាងរបស់ខ្លួន។ បព្វជិតសាសនាបានជួយសម្រួលដល់ការសម្លាប់ជនទុតស៊ីដែលជាអ្នកធ្វើកិច្ចការសាសនាដូចគ្នា។ ជួនកាលបុរសហ៊ូទូខ្លះបានសម្លាប់ប្រពន្ធនិងសាច់ញាតិរបស់ខ្លួនដែលជាជនទុតស៊ី។ មិនមែនជនហ៊ូទូទាំងអស់សុទ្ធតែចូលរួមនៅក្នុងការសម្លាប់នេះទេ។ អ្នកខ្លះចូលរួមសម្លាប់មនុស្សដោយសារខ្លួនត្រូវគេគំរាមកំហែង ហើយក៏មានជនហ៊ូទូជាច្រើននាក់ទៀតបានប្រថុយជីវិតរបស់ខ្លួនសង្គ្រោះជីវិតជនទុតស៊ីដែលជាមិត្តភក្តិរបស់ខ្លួន និងជួនកាលជាអ្នកមិនស្គាល់គ្នាសោះទៀតផង។ ទោះជាយ៉ាងណាក៏ដោយ ទំហំដ៏ធំនៃការចូលរួមរបស់ប្រជាជននៅក្នុងអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាមិនអាចបដិសេធបានទេ។

## ឃ) ការទទួលខុសត្រូវចំពោះការចូលរួមរបស់ប្រជាជន

តើយើងអាចពន្យល់អំពីការចូលរួមរបស់ជនហ៊ូទូធម្មតានៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាយ៉ាងដូចម្តេច? ការត្រួតពិនិត្យមើលមូលហេតុនៅពីក្រោយការសម្លាប់រង្គាលនេះគឺមានសារសំខាន់ខ្លាំងណាស់ប្រសិនបើយើងចង់ស្វែងរកមធ្យោបាយដើម្បីដោះស្រាយជម្លោះ និងដើម្បីការពារកុំឲ្យទង្វើនេះកើតឡើងម្តងទៀតនៅពេលអនាគត។

មុនពេលបង្ហាញទស្សនៈនៃការសិក្សានេះ ជាដំបូងខ្ញុំនឹងបង្ហាញអំពីការពន្យល់សំខាន់ៗចំនួន៤។ ទី១) ការបង្ហាញអំពីធម្មជាតិអាក្រក់របស់មនុស្ស។ ប្រសិនបើយើងនិយាយថា ធម្មជាតិរបស់មនុស្សគឺជាបុព្វហេតុដ៏មានសារសំខាន់និងគ្រប់គ្រាន់នៃអំពើប្រល័យពូជសាសន៍ នោះមានក្តីសង្ឃឹមតិចតួចឬមិនមានក្តីសង្ឃឹមសោះតែម្តងសម្រាប់ប្រទេសរ៉្វាន់ដា ឬសម្រាប់ប្រទេសផ្សេងទៀតនៅក្នុងពិភពលោក ដោយសារថាធម្មជាតិរបស់មនុស្សគឺពិបាកនឹងកែប្រែណាស់។ ដូចគ្នានេះដែរ ធម្មជាតិរបស់មនុស្សក៏មិនមែនជាមូលហេតុនៃការរៀបចំបង្កជាអំពើប្រល័យពូជសាសន៍ដែរ។ ទី២) លទ្ធផលនៃការចង់រស់ដោយមិនគិតពីអ្នកដទៃ។ ដូចបានបង្ហាញនៅក្នុងផ្នែកមុនៗរួចហើយ រ៉្វាន់ដាមានបញ្ហាកំណើនប្រជាជន កង្វះខាតដីធ្លី និងការធ្លាក់ចុះនូវផលិតផលស្បៀងអាហារ ចាប់តាំងពីឆ្នាំ១៩៨៤មកម្ល៉េះ។ ប្រសិនបើយើងទទួលស្គាល់ថាការអះអាងនេះជាការពិត អំពើប្រល័យពូជសាសន៍គួរតែកើតមាននៅលើប្រទេសជាច្រើនទៀតជាមិនខាន ព្រោះមានប្រទេសជាច្រើនដែលជួបបញ្ហាខ្វះខាតធនធានបែបនេះ

ហើយធ្ងន់ធ្ងរជាងវ៉ាន់ដាទៀតផង ។ ទី៣) ការឆ្លៀតឱកាសដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ អាលីហ្សុង ដេហ្វូច មកពីអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ បានលើកឡើងថា ជនហ៊ូទូក្រីក្រជាច្រើននាក់បានយល់ព្រមចូលរួមសម្លាប់មនុស្សដើម្បីជាថ្នូរនឹងសម្ភារផ្សេងៗដែលអាជ្ញាធរប្រគល់ឲ្យ ដូចជា ទ្រព្យសម្បត្តិ និងដីរបស់អ្នកជិតខាង ។ ក៏ប៉ុន្តែ ការលើកឡើងនេះមិនអាចពន្យល់អំពីមូលហេតុដែលជនដែលជាច្រើនបានបញ្ចេញនូវកំហឹងក្រេវក្រោធក្នុងការសម្លាប់រង្គាលជីវិតមនុស្ស បើទោះបីជាខ្លួនមិនបានទទួលការសន្យាផ្តល់រង្វាន់ចំពោះទង្វើនេះក៏ដោយ ។ ជាងនេះទៅទៀត វាផ្ទុយទៅនឹងការណ៍ដែលថាជនហ៊ូទូជាច្រើនបានប្រថុយជីវិតរបស់ខ្លួនក្នុងការជួយសង្គ្រោះជនទុតស៊ី ។ ទី៤) ការគោរពបញ្ជារបស់អាជ្ញាធរទាំងងឹតងងល់ ។ ជ័រ៉ាដ ព្រូនីញេ៉ បានពិពណ៌នាទម្លាប់នយោបាយវ៉ាន់ដាថាជា «ទម្លាប់មួយដែលគោរពអាជ្ញាធរដោយគ្មានលក្ខខណ្ឌ» ។ មេធាវីជនជាតិហ៊ូទូម្នាក់ដែលគាំទ្រការអះអាងនេះដែរ បានសម្តែងថា «មនុស្សតែងតែស្រលាញ់អំណាច ហើយមិនមានការអប់រំគ្រប់គ្រាន់ ។ ប្រសិនបើអ្នកផ្តល់អាវុធឲ្យទៅប្រជាជនដែលក្រីក្រនិងមិនមានចំណេះដឹង ហើយប្រាប់អ្នកទាំងនោះថា អ្នកឯងអាចសម្លាប់មនុស្សបានតាមអំពើចិត្ត អ្នកទាំងនោះប្រាកដជាធ្វើតាម» ។ ប៉ុន្តែគំនិតនេះគឺខកខានក្នុងការទទួលស្គាល់តួនាទីរបស់មនុស្ស បើទោះបីជាតិចតួចយ៉ាងណាក៏ដោយ គ្រប់ស្ថានភាពទាំងអស់តែងតែមានជម្រើសជានិច្ច ។

បើទោះបីជាមិនទាន់គ្រប់គ្រាន់ក៏ដោយ ការពន្យល់ទាំងបួនខាងលើបានផ្តល់មូលហេតុដោយផ្អែកនៃអំពើប្រល័យពូជសាសន៍ ។ ជម្លោះហិង្សានេះជាលទ្ធផលនៃមូលហេតុជាច្រើន ប៉ុន្តែអ្វីដែលខ្ញុំចង់សង្កត់ធ្ងន់នៅទីនេះគឺថា គ្មានការពន្យល់មួយណាឆ្លើយតបទៅនឹងសំណួរ «តើតាមរបៀបណាដែលជនប្រព្រឹត្តអំពើប្រល័យពូជសាសន៍មួយចំនួនតូចអាចបញ្ចុះបញ្ចូលមនុស្សរាប់សែននាក់ឲ្យចូលរួមប្រព្រឹត្តអំពើយង់ឃ្នងយ៉ាងនេះ?» ។

ម៉ាំដានី បានកត់សម្គាល់ថា «ដើម្បីពន្យល់ពីមូលហេតុនៃអំពើឃោរឃៅ យើងត្រូវតែក្រឡេកទៅមើលប្រវត្តិសាស្ត្រវិញ» ។ ជាការពិត ដើម្បីយល់ដឹងអំពីការចូលរួមរបស់ប្រជាជនយើងត្រូវតែត្រឡប់ទៅមើលប្រវត្តិសាស្ត្រ បញ្ហាអត្តសញ្ញាណដែលខ្ញុំបានពិភាក្សាកាលពីដើមដំបូងនៃការសិក្សានេះ និងកំណត់ថាតើបញ្ហាអត្តសញ្ញាណមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើរបៀបដែលជនប្រព្រឹត្តអំពើប្រល័យពូជសាសន៍យល់ឃើញចំពោះជម្លោះ? នៅអំឡុងពេលមានអំពើប្រល័យពូជសាសន៍ ក្រុមហ៊ូទូវណ្ណៈកណ្តាលគឺជាអ្នកដែលមានមោទកភាពបំផុតដោយសារបដិវត្តន៍ឆ្នាំ១៩៥៩ដែលក្រុមហ៊ូទូទាំងនេះចងចាំថាជាឆ្នាំនៃការរំដោះខ្លួនចេញពីការគាបសង្កត់របស់ក្រុមទុតស៊ី ។ អរគុណចំពោះនយោបាយឆ្គួតៗរបស់សាធារណរដ្ឋទីមួយ ការចងចាំជាប្រវត្តិសាស្ត្រអំពីទុក្ខវេទនាកាលពីនៅក្រោមការគ្រប់គ្រងរបស់ក្រុមទុតស៊ីនៅតែមានសារសំខាន់ដដែលនៅក្នុងប្រទេសវ៉ាន់ដាក្រោយសម័យអាណានិគម ។ ដូច្នេះហើយ នៅពេលដែលក្រុមហ៊ូទូវណ្ណៈកណ្តាលអំពាវនាវឲ្យមានសិទ្ធិប្រជាធិបតេយ្យធំជាងមុនកាលពីចុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រុមនេះធ្វើដូច្នេះដោយផ្អែកលើការសន្មតថាខ្លួនអាចថែរក្សាផលប្រយោជន៍ដែលបានមកពីបដិវត្តនេះជារៀងរហូត ហើយការណ៍នេះមានន័យថា «អនាគតរបស់ក្រុមហ៊ូទូមានន័យប្រហាក់ប្រហែលនឹងអត្ថិភាពនិងការពង្រីកឥទ្ធិពលរបស់ក្រុមហ៊ូទូវណ្ណៈកណ្តាល» ។

ប៉ុន្តែក្រោយមក សង្គ្រាមស៊ីវិលជាមួយរណសិរ្សស្នេហាជាតិវ៉ាន់ដាបានបំផ្លាញភាពពិតប្រាកដនេះ ។ ជាក់ស្តែង រដ្ឋមន្ត្រីក្រសួងការបរទេស កៃមៀ បីហ្សីមុាំងហ្គូ បានប្រកាសកាលពីខែតុលាឆ្នាំ១៩៩០ថា គោលបំណងនៃការឈ្លានពានរបស់រណសិរ្សស្នេហាជាតិវ៉ាន់ដាគឺជាការ«នាំមកវិញនូវប្រវត្តិសាស្ត្រ» (ការវិលមកវិញនូវការគ្រប់គ្រងរបស់ទុតស៊ី) ឬការបញ្ចប់បដិវត្តន៍ឆ្នាំ១៩៥៩ ។ ខសារីន និង ដេវីដ ញូបឺរី កត់សម្គាល់ការសម្ភាសន៍ដែលខ្លួនបានធ្វើជាមួយជនភៀសខ្លួនហ៊ូទូនៅក្នុងប្រទេសតង់ហ្សានីកាលពីឆ្នាំ១៩៩៨ថាៈ «ជាថ្មីម្តងទៀត ការសន្ទនានៅក្នុងជំរំជនភៀសខ្លួនបានផ្តោតទៅលើរបបរាជានិយមមុនឯករាជ្យនិងមុនបដិវត្តន៍ឆ្នាំ១៩៥៩ ។ មនុស្សជាច្រើនបានមើលឃើញថា រណសិរ្សស្នេហាជាតិវ៉ាន់ដាគឺជារចនាសម្ព័ន្ធរស់

ឡើងវិញនៃអំណាចមុនបដិវត្តន៍ (ការគ្រប់គ្រងដោយទុតស៊ី)» ។ ជនហ៊ូទូជាច្រើនជឿជាក់ថា ផលប្រយោជន៍ពិតប្រាកដនៅក្នុងសង្គ្រាមស៊ីវិលគឺជាជោគវាសនាអនាគតប្រវត្តិសាស្ត្ររបស់ក្រុមខ្លួន ។

ប៉ុន្តែ ការជឿជាក់បែបនេះមិនមែនជាលទ្ធផលចុងក្រោយបំផុតដែលមិនអាចចៀសវាងបាននៃការចងចាំជាប្រវត្តិសាស្ត្រនោះទេ ។ ការជឿជាក់បែបនេះពិតជាទទួលឥទ្ធិពលពីកត្តាមួយចំនួន ។ ទីមួយ បើទោះបីជានៅក្នុងជួរថ្នាក់ដឹកនាំរបស់រណសិរ្សស្នេហាជាតិរ៉ាន់ដាមានជនហ៊ូទូមួយចំនួនតូចក៏ដោយ ក៏រណសិរ្សនេះភាគច្រើនគ្រប់គ្រងដោយជនទុតស៊ីនៅអ៊ុយហ្គាន់ដា ហើយតាមរយៈនេះ រណសិរ្សស្នេហាជាតិរ៉ាន់ដាត្រូវបានមើលឃើញថាជា«កងកម្លាំងទុតស៊ី» ។ ហេតុដូច្នេះហើយ កសិករហ៊ូទូមិនស្វាគមន៍រណសិរ្សស្នេហាជាតិរ៉ាន់ដាថាជា «អ្នករំដោះ» ដូចដែលរណសិរ្សនេះរំពឹងទុកឡើយ ។ ឆ្លើយតបទៅនឹងការមិនទទួលស្វាគមន៍នេះ មេដឹកនាំរណសិរ្សស្នេហាជាតិរ៉ាន់ដាបានចាប់ផ្តើមពិពណ៌នាអំពីកសិករហ៊ូទូទាំងនោះថាជាជនប្រតិកិរិយានិងជាមនុស្សល្ងង់ ព្រមទាំងបានលួចនិងបំផ្លាញទ្រព្យសម្បត្តិរបស់កសិករទាំងនេះអស់ជាច្រើន ។ រណសិរ្សនេះក៏បានបង្ខំបុរសនិងក្មេងប្រុសៗកសិករហ៊ូទូឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរទៀតផង ។ ឧក្រិដ្ឋកម្មបែបនេះបានកើនឡើងយ៉ាងខ្លាំងបន្ទាប់ពីខែកុម្ភៈ ឆ្នាំ១៩៩៣ ហើយករណីនេះបន្តឲ្យមានការស្អប់ខ្ពើមកាន់តែខ្លាំងនៅក្នុងចំណោមប្រជាជន ។ ទីពីរ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សាបានបញ្ជាក់បន្ថែមអំពីការជឿជាក់ថាគោលបំណងពិតប្រាកដរបស់រណសិរ្សស្នេហាជាតិរ៉ាន់ដាគឺមិនមែនសិទ្ធិសេរីភាពរបស់ជនជាតិរ៉ាន់ដាជារួមនោះទេ ប៉ុន្តែគឺដើម្បីតែអំណាចរបស់ទុតស៊ីតែប៉ុណ្ណោះ ។ ដោយឡែក ខបែងដែលទទួលស្គាល់វិលត្រឡប់ចូលប្រទេសវិញនូវរាល់ជនភៀសខ្លួនទាំងអស់ (ស្ទើរតែទាំងអស់ជាទុតស៊ី) បានធ្វើឲ្យជនហ៊ូទូភាគច្រើនយល់ឃើញថាសន្តិភាពនឹងធ្វើឲ្យក្រុមខ្លួនទទួលបានផលប្រយោជន៍កាលពីបដិវត្តន៍ឆ្នាំ១៩៥៩ឡើងវិញ ។ ជាងនេះទៅទៀត ឃាតកម្មទៅលើប្រធានាធិបតីជនជាតិហ៊ូទូរបស់ប្រទេសប៊ូរុនឌីកាលពីឆ្នាំ១៩៩៣ បានធ្វើឲ្យមនុស្សភាគច្រើនយល់ឃើញក្រុមហ៊ូទូត្រូវតែជ្រើសរើសរវាងអំណាចឬការបាត់បង់សេរីភាព ។

ការយល់ឃើញបែបនេះគឺជាជោគជ័យនៃយុទ្ធនាការឃោសនារបស់ក្រុមហ៊ូទូនិយមជ្រុល ។ ជនប្រព្រឹត្តប្រល័យពូជសាសន៍បានប្រើប្រាស់ពាក្យសម្តីប្រល័យពូជសាសន៍ និងបន្ថយតម្លៃរបស់ជនទុតស៊ីតាមរយៈវិទ្យុនិងទូរទស្សន៍ *RTLM (Radio et Television Libre des Mille Collines)* និងកាសែតកង់ហ្គូរ៉ា ។ ជាក់ស្តែង វិទ្យុរើសអើងមួយនេះបានហៅជនទុតស៊ីថាជា «កន្លាតស៊ីមនុស្ស» ។ ជនប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទាំងនេះក៏បានហៅជនទុតស៊ីទាំងនោះថាជាពូជសាសន៍បរទេស ហើយក្រុមនេះរស់នៅលើទឹកដីរ៉ាន់ដាដោយខុសច្បាប់ ។ ជាងនេះទៅទៀត ការប្រកាសថា «ប្រសិនបើមិនសម្លាប់ទុតស៊ីទេ ទុតស៊ីនឹងសម្លាប់វិញ» បានធ្វើឲ្យជនហ៊ូទូយល់ថាការសម្លាប់ជនទុតស៊ីជាការចាំបាច់ និងជាការការពារខ្លួន ។ ជនភៀសខ្លួនហ៊ូទូម្នាក់បានពន្យល់ថា «យើងឮម្តងហើយម្តងទៀតថាជនទុតស៊ីនឹងមកសម្លាប់យើង ។ ដូច្នេះ ជនហ៊ូទូបានចាប់ផ្តើមសម្លាប់ជនទុតស៊ី ហើយការសម្លាប់នេះគឺដោយសារការភ័យខ្លាច មិនមែនដោយសារការស្អប់ខ្ពើមជនទុតស៊ីនោះទេ ។ ជនហ៊ូទូទាំងនោះគិតថាខ្លួនមានជម្រើសតែមួយប៉ុណ្ណោះ គឺសម្លាប់ទុតស៊ី ឬត្រូវទុតស៊ីសម្លាប់វិញ» ។ ម៉ាំដានី បានសរសេរថា «ជនដៃដល់នៃអំពើប្រល័យពូជសាសន៍ទាំងនោះបានមើលឃើញថា ខ្លួនឯងទើបជាជនរងគ្រោះពិតប្រាកដនៃឆាកល្បែងនយោបាយ និងជាជនរងគ្រោះនៃអតីតកាលដែលអាចក្លាយជាជនរងគ្រោះម្តងទៀត» ។ ជារួម គោលបំណងដើម្បីកាន់កាប់អំណាចនយោបាយគឺជាមូលហេតុសំខាន់ដែលបង្កជាអំពើប្រល័យពូជសាសន៍ ប៉ុន្តែការភ័យខ្លាចបានដើរតួនាទីយ៉ាងសំខាន់ក្នុងការញុះញង់ឲ្យមានអំពើហិង្សា ហើយភាពភ័យខ្លាចទាំងនោះត្រូវបានបង្កើតជាខ្សែសង្វាក់ដោយសារការឃោសនា ។

ការភ័យខ្លាចតែមួយមុខមិនគ្រប់គ្រាន់ដើម្បីបង្កជាអំពើប្រល័យពូជសាសន៍នោះទេ ។ ជនហ៊ូទូធម្មតាបានគិតដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយសារអំពើហិង្សានៅអំឡុង

សម័យសង្គ្រាមស៊ីវិល ។ បន្ទាប់ពីការលុកលុយដំបូងរបស់រណសិរ្សស្នេហាជាតិរ៉ាន់ដា រដ្ឋាភិបាលរបស់រ៉ាន់ដាបានចោទប្រកាន់ជនទុតស៊ីរាប់ពាន់នាក់ថាបានគាំទ្ររណសិរ្សស្នេហាជាតិរ៉ាន់ដា ហើយចាប់ខ្លួនអ្នកទាំងនេះឃុំឃាំង ។ នៅចន្លោះឆ្នាំ១៩៩០ និងឆ្នាំ១៩៩៣ ការសម្លាប់រង្គាលបានកើតនៅក្នុងប្រទេសរ៉ាន់ដាចំនួន៤លើក សម្លាប់ជនទុតស៊ីអស់ប្រមាណ៣ពាន់នាក់ ។ ទោះបីជាការសម្លាប់រង្គាលទាំងនេះចាប់ផ្តើមចេញពីមជ្ឈិមក៏ដោយ ប៉ុន្តែជនទុតស៊ីទាំងនេះត្រូវសម្លាប់នៅតាមមូលដ្ឋានដែលគេរស់នៅ ។ រាល់ការសម្លាប់រង្គាលមួយលើកៗ ជនជ្រុលនិយមបានស៊ុះស្រែងប្រើប្រាស់អំណាច«ទំនៀមទម្លាប់»ដែលបានកើតឡើងតាំងពីសម័យមុននិងក្រោយអាណានិគមដើម្បីដាក់សម្ពាធទៅលើសហគមន៍ទាំងឡាយ ។ លទ្ធផលចុងក្រោយនៃការអនុវត្តបែបនេះគឺជាការបង្ហាញឲ្យជនហ៊ូទូទៅមើលឃើញថា ការសម្លាប់ជនទុតស៊ីគឺជាផ្នែកមួយនៃកម្មវិធីរបស់សហគមន៍ ។ ជាងនេះទៅទៀត នៅក្នុងបរិបទនយោបាយរបស់សង្គ្រាមស៊ីវិល ការសម្លាប់នេះហាក់បីដូចជារឿងស្របច្បាប់ ។

## ផ្នែកទី២ៈ ការស្វែងយល់អំពីបច្ចុប្បន្នភាព

កន្លងមក យើងបានពិនិត្យទៅលើការវិវត្តជាប្រវត្តិសាស្ត្រនៃការឈឺចាប់របស់ជាតិពន្ធទាំងពីរ និងបុព្វហេតុនិងការវិវត្តនៃអំពើប្រល័យពូជសាសន៍ ដោយផ្អែកទៅលើហេតុផលដែលថាគ្មានក្តីសង្ឃឹមណាមួយអាចកើតឡើងដោយគ្មានការយល់ដឹងដ៏ជាក់ច្បាស់អំពីអតីតកាលទេ ។ ឥឡូវនេះ បើយើងត្រឡប់ទៅមើលសំណួរដែលបានលើកឡើងកាលពីដំបូង «តើមានក្តីសង្ឃឹមសម្រាប់ប្រទេសនេះដែរទេ?» ខ្ញុំចង់ស្វែងរកការយល់ដឹងដ៏ជាក់ច្បាស់អំពី«បច្ចុប្បន្នភាព» ពោលគឺព្រឹត្តិការណ៍វិវត្តចាប់តាំងពីអំពើប្រល័យពូជសាសន៍កាលពីឆ្នាំ១៩៩៤ ។ ដើម្បីធ្វើដូច្នេះ ជាដំបូងខ្ញុំនឹងពិនិត្យមើលទៅលើបុព្វហេតុនិងការវិវត្តនៃជម្លោះដែលកំពុងតែមានជាបន្តរវាងក្រុមហ៊ូទូនិងទុតស៊ី បន្ទាប់មកខ្ញុំនឹងពិនិត្យមើលទៅលើកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពចាប់តាំងពីអំពើប្រល័យពូជសាសន៍ ដើម្បីបំភ្លឺអំពីការខិតខំប្រឹងប្រែងដើម្បីសន្តិភាព យុត្តិធម៌ និងការផ្សះផ្សា ដ៏យូរអង្វែងនៅប្រទេសរ៉ាន់ដា ។

### ១) បុព្វហេតុនិងការវិវត្តនៃសង្គ្រាមក្នុងតំបន់នៅប្រទេសកុងហ្គោ-ហ្ស៊ៃរ

សង្គ្រាមស៊ីវិលនិងអំពើប្រល័យពូជសាសន៍នៅរ៉ាន់ដាបានបញ្ចប់ជាផ្លូវការកាលពីខែកក្កដាឆ្នាំ១៩៩៤ នៅពេលដែលក្រុមខុទ្ទាម«រណសិរ្សស្នេហាជាតិរ៉ាន់ដា»បានទទួលជ័យជម្នះលើកងទ័ពរ៉ាន់ដា និងដណ្តើមកាន់កាប់អំណាចនៅរដ្ឋធានីឃីហ្គាលី ។ ទោះជាយ៉ាងណាក៏ដោយ ជម្លោះប្រដាប់អាវុធមិនទាន់បញ្ចប់នៅឡើយទេនៅពេលនោះ ។ ជម្លោះដែលនៅតែបន្តនៅតំបន់ពាយ័ព្យរវាងកងកម្លាំង «រណសិរ្សស្នេហាជាតិរ៉ាន់ដា» និងក្រុមខុទ្ទាមហ៊ូទូ (ដែលក្នុងនោះមាន កងទ័ពអតីតរដ្ឋាភិបាលរ៉ាន់ដា និងក្រុមខុទ្ទាមអ៊ីនធឺរ៉ាហាមវី) បានបណ្តាលឲ្យបាត់បង់ជីវិតជនស៊ីវិលទាំងសងខាងអស់រាប់ពាន់នាក់ ។ ជម្លោះក៏បានរីករាលដាលទៅភាគខាងកើតនៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (កុងហ្គោ-ហ្ស៊ៃរខាងកើត) និងបន្តិចម្តងៗបានក្លាយទៅជាសង្គ្រាមតំបន់ដោយសារតែ«រណសិរ្សស្នេហាជាតិរ៉ាន់ដា»បានបង្វឹកនិងបំពាក់អាវុធដល់កងទ័ពទុតស៊ី នៅក្នុងប្រទេសជិតខាង ហើយថែមទាំងបានបញ្ជូនកងទ័ពរបស់ខ្លួនឲ្យជួយដល់កងទ័ពទុតស៊ីនេះថែមទៀត ។ ជាការពិត អំពើប្រល័យពូជសាសន៍នៅរ៉ាន់ដាបានបង្កើតជាស្ថានភាពមួយដែលជនជាតិដើមត្រូវបានបណ្តេញចេញពីទឹកដីកំណើតរបស់ខ្លួន ដោយផ្អែកលើជំនឿពីរៈ ទី១) រដ្ឋាភិបាលរ៉ាន់ដាត្រូវទទួលខុសត្រូវចំពោះជនទុតស៊ីដែលនៅសេសសល់ និងទី២) អំណាចគឺជាលក្ខខណ្ឌសម្រាប់ធានាការរស់រានជីវិតរបស់ជនទុតស៊ី ។ ជាលទ្ធផល ការបែងចែកគ្នារវាងជនហ៊ូទូនិងទុតស៊ី នៅក្នុងតំបន់ហ្គ្រេតឡេកបានបង្កទៅជាការប្រឈមមុខស្លាប់រស់ ។ សង្គ្រាមតំបន់នេះបានបង្កទៅជាអស្ថិរភាពនៅក្នុងប្រទេសរ៉ាន់ដា ព្រមទាំងបានបង្កើតទៅជាឧបសគ្គដ៏ធំដល់ការកសាងសន្តិភាពនៅក្នុងប្រទេសរ៉ាន់ដា ។ ដូចដែលបានលើកឡើងរួចហើយនៅក្នុងផ្នែកមុន ព្រឹត្តិការណ៍វិវត្តនៅក្នុងតំបន់ ជាពិសេសប្រទេសអ៊ូហ្គាន់ដានិងប៊ូរុនឌី ជះឥទ្ធិពលយ៉ាងខ្លាំងដល់ជម្លោះនៅក្នុងប្រទេសរ៉ាន់ដាដែលនាំទៅដល់ការប្រល័យ

ពូជសាសន៍ ។ ដូច្នេះហើយ នៅក្នុងការឆ្លើយតបទៅនឹងសំណួរអំពី«ក្តីសង្ឃឹមសម្រាប់វៀតណាម» យើងត្រូវតែពិនិត្យមើលឲ្យបានដាក់លាក់អំពីបុព្វហេតុនិងការវិវត្តនៃអំពើប្រល័យពូជសាសន៍ដែលបង្កដោយសង្គ្រាមនៅក្នុងតំបន់នេះ ។ ក្នុងការសិក្សានេះ ខ្ញុំនឹងផ្តោតទៅលើរបៀបដែលជម្លោះក្នុងស្រុកជុំវិញបញ្ហាសញ្ជាតិនៅក្នុងប្រទេសកុងហ្គោ-ហ្សៃអ៊ែរអាចជះឥទ្ធិពលទៅលើការវិវត្តន៍នៃសង្គ្រាមជាមួយវៀតណាមបន្ទាប់ពីឆ្នាំ១៩៩៤ ដើម្បីបង្ហាញអំពីភាពចាំបាច់នៃការយល់ដឹង និងដើម្បីដោះស្រាយវិបត្តិសញ្ជាតិនៅក្នុងតំបន់ក្នុងការពិភាក្សាអំពីប្រទេសវៀតណាមបន្ទាប់ពីពេលមានអំពើប្រល័យពូជសាសន៍ ។

ឯកសារជាសារពត៌មានជាច្រើនបានជួយឲ្យយើងចងចាំអំពីជម្លោះនៅភាគខាងកើតប្រទេសកុងហ្គោ-ហ្សៃអ៊ែរតាមរយៈការពិពណ៌នាព្រឹត្តិការណ៍នោះឲ្យទៅជាលទ្ធផលដែលអាចចៀសវាងបាននៃការហូរចូលជនភៀសខ្លួនដ៏ច្រើនសន្ធឹកសន្ធាប់ពីប្រទេសវៀតណាមបន្ទាប់ពីមានអំពើប្រល័យពូជសាសន៍ ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍នៅភាគខាងកើតនៃប្រទេសកុងហ្គោ-ហ្សៃអ៊ែរបន្ទាប់ពីការកើតឡើងនៃអំពើប្រល័យពូជសាសន៍នៅវៀតណាមក្នុងឆ្នាំ១៩៩៤មិនអាចត្រូវបានយល់ឲ្យបានច្បាស់លាស់ទេ លុះត្រាតែយើងពិនិត្យមើលព្រឹត្តិការណ៍មុនពេលដែលមានការហូរចូលនូវជនភៀសខ្លួនវៀតណាម ។ ដូចនៅក្នុងប្រទេសអ៊ុយហ្កាន់ដា ប៊ូរុនឌី និងវៀតណាមដែរ បញ្ហានៃភាពជាជនជាតិដើម អំណាច និងសញ្ជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កជាជម្លោះឲ្យនៅភាគខាងជើងនិងខាងត្បូងខេត្តគីវូនៃប្រទេសកុងហ្គោ-ហ្សៃអ៊ែរខាងកើត ។ ដូចនៅក្នុងប្រទេសវៀតណាមកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០ដែរ ជម្លោះនេះគឺបណ្តាលមកពីទំនាក់ទំនងដ៏សាំញ៉ាំរវាងជម្លោះជាតិពន្ធុ និងការគំរាមកំហែងផ្នែកសន្តិសុខពីប្រទេសវៀតណាម ។

ដើម្បីឲ្យសម្រេចគម្រោងធ្វើចម្ការធំៗរបស់ខ្លួន អាជ្ញាធរអាណានិគមប៊ែលហ្ស៊ិកបានរៀបចំផែនការនិងជួយឲ្យអ្នកធ្វើអន្តោប្រវេសន៍បាន់យ៉ាវៀតណាម (ឬអ្នកមកពីវៀតណាម) ជាច្រើននាក់បានចូលទៅរស់នៅក្នុងខេត្តគីវូកាលពីដើមសតវត្សរ៍ទី២០ ។ អាណានិគមប៊ែលហ្ស៊ិកបានដាក់ចេញនូវគោលនយោបាយអាប៉ាថេត ដោយបានតែងតាំងជនហ៊ូទូជាប្រធានផ្នែកអន្តោប្រវេសន៍ ព្រមទាំងបានបន្ថយតំណែងរបស់ជនម្ចាស់ស្រុក ។ ជាងនេះទៅទៀត រដ្ឋបាលអាណានិគមបានធ្វើកិច្ចព្រមព្រៀងដូលដីមិនច្បាស់លាស់ជាមួយមេដឹកនាំជនម្ចាស់ស្រុក ហើយសកម្មភាពនេះបានបង្កជាជម្លោះក្រោយមកទៀតអំពីសិទ្ធិគ្រប់គ្រងដីធ្លី ។ បន្ទាប់ពីបានឯករាជ្យ ប្រជាជនម្ចាស់ស្រុកបានទាមទារសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួនឡើងវិញ ហើយបានព្យាយាមដេញជនបាន់យ៉ាវៀតណាមដែលខ្លួនចាត់ទុកជាជនបរទេសឲ្យចេញពីលើដីធ្លីរបស់ខ្លួន ។ ភាពចម្រូងចម្រាស់និងការពិភាក្សានយោបាយជុំវិញ «បញ្ហាសញ្ជាតិ» កាន់តែធ្វើឲ្យការខ្វះខាតដីធ្លីធ្វើស្រែចម្ការ និងការហូរចូលនូវជនភៀសខ្លួនទុតស៊ីពីប្រទេសវៀតណាមកាន់តែខ្លាំងក្លាថែមទៀតក្នុងឆ្នាំ១៩៥៩-៦១ និងឆ្នាំ១៩៦៣-៦៤ ។ បន្ទាប់ពីបដិវត្តន៍ហិង្សាកាលពីឆ្នាំ១៩៥៩នៅវៀតណាម និងជាពិសេសអំពើប្រល័យពូជសាសន៍នៅប្រទេសប៊ូរុនឌី ជនទុតស៊ីនៅក្នុងខេត្តគីវូភាគខាងត្បូងបានព្យាយាមធ្វើឲ្យខ្លួនឯងក្លាយជាជនជាតិហ្សៃអ៊ែរ (កុងហ្គោ) ។ ទោះជាយ៉ាងណាក៏ដោយ ជនបាន់យ៉ាវៀតណាមនៅតែជាជនរងគ្រោះនៅក្នុងប្រទេសកុងហ្គោហ្សៃអ៊ែរប៉ែកខាងកើតដដែល ដោយសារភាគច្រើននៃជនបាន់យ៉ាវៀតណាមទាំងនេះត្រូវបានរដ្ឋធម្មនុញ្ញឆ្នាំ១៩៦៤របស់ប្រទេសកុងហ្គោ-ហ្សៃអ៊ែរ បដិសេធមិនផ្តល់សញ្ជាតិ ។ ដោយមិនមានសញ្ជាតិហ្សៃអ៊ែរ ជនទុតស៊ីទាំងនោះត្រូវតែបង់វិភាគទានទៅឲ្យជនម្ចាស់ស្រុកដើម្បីអាចទទួលបានសិទ្ធិកាន់កាប់ដីធ្លី ។ កាលពីឆ្នាំ១៩៧២ ស្ថានភាពរបស់ជនទុតស៊ីទាំងនេះប្រសើរជាងមុនដោយសារមានការកែប្រែច្បាប់សញ្ជាតិ ដោយច្បាប់នេះបានផ្តល់សញ្ជាតិដល់អ្នកទាំងឡាយដែលមកពីប្រទេសវៀតណាមនិងប្រទេសប៊ូរុនឌីមុន ឆ្នាំ១៩៥០ ។ ក៏ប៉ុន្តែបន្ទាប់ពីមោឃភាពរបស់ច្បាប់នេះនៅក្នុងឆ្នាំ១៩៨១ ជនបាន់យ៉ាវៀតណាមត្រូវបានដកចេញពីដំណើរការនយោបាយជាតិ ។ នៅអំឡុងពេលមានវិបត្តិស្បៀងអាហារនៅក្នុងខេត្តគីវូ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០និង១៩៨០ ជនម្ចាស់ស្រុកដែលព្យាយាមកែប្រែការតស៊ូវណ្ណៈនិងសេដ្ឋកិច្ចឲ្យទៅជាបញ្ហាជាតិពន្ធុ និងជនបរទេសបានទម្លាក់កំហុសលើជនទុតស៊ី

ទាំងនេះ ។

កាលពីដើមឆ្នាំ១៩៩៣ ជម្លោះហិង្សាបានផ្ទុះឡើងនៅក្នុងតំបន់ម៉ាស៊ីស៊ីដែលជាតំបន់មួយមានជនអន្តោប្រវេសន៍ភាគច្រើនរស់នៅ ។ បើទោះបីជាជម្លោះចាប់ផ្តើមដោយជនអន្តោប្រវេសន៍ហ៊ូទូ (និងទុតស៊ី) ដែលមានទ្រព្យសម្បត្តិ ដណ្តើមកាន់កាប់ដីធ្លីរបស់ជនហ៊ូទូក្រីក្រនិងបាហ៊ុនដេ (ជនភាគតិចមួយក្រុមដែលជាម្ចាស់ស្រុក) ប៉ុន្តែក្រោយមកជម្លោះនេះបានក្លាយទៅជាជម្លោះជាតិពន្ធរវាង «ជនម្ចាស់ស្រុក» (ក្នុងនោះមានក្រុមបាហ៊ុនដេនិងបានយ៉ាងហ្គូ) ជាមួយនឹង«ជនមិនមែនម្ចាស់ស្រុក» (ក្រុមហ៊ូទូនិងក្រុមទុតស៊ី) ។ ក្រុមម្ចាស់ស្រុកបាននាំទាហានមកសម្លាប់ទាំងជនហ៊ូទូនិងជនទុតស៊ី ។ ជម្លោះនេះបានបណ្តាលឲ្យបាត់បង់ជីវិតប្រជាជនទាំងសងខាងអស់ប្រមាណពី១ម៉ឺនទៅ២ម៉ឺននាក់ និងបណ្តាលឲ្យមានជនភៀសសឹកចំនួន៣៥ម៉ឺននាក់ ។

ស្ថានភាពផ្ទៃក្នុងទាំងនេះបានជះឥទ្ធិពលជាពិសេសទៅលើការវិវត្តន៍នៃជម្លោះនៅក្នុងតំបន់បន្ទាប់ពីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា នៅឆ្នាំ១៩៩៤ ។ ផ្ទុយទៅនឹងការវិភាគដែលបានលើកឡើងដោយអ្នកវិភាគមួយចំនួនជម្លោះនៅក្នុងខេត្តគីវូគឺធ្ងន់ធ្ងរជាងការប្រឈមមុខគ្នារវាងក្រុមហ៊ូទូនិងទុតស៊ី ។ ជាក់ស្តែងនៅក្នុងតំបន់ម៉ាស៊ីស៊ី នៅពេលដែលជនភៀសខ្លួនហ៊ូទូមកពីរ៉្វាន់ដាបានមកដល់នៅក្នុងខែកក្កដាឆ្នាំ១៩៩៤ ជនភៀសសឹកចំនួន១ម៉ឺននាក់ក្នុងចំណោមជនភៀសសឹកចំនួន៣៥ម៉ឺននាក់ (ភាគច្រើនជាជនហ៊ូទូ) ដែលបានភៀសសឹកកាលពីឆ្នាំ១៩៩៣ នៅតែជាជនភៀសសឹកដដែល ។ ជនភៀសសឹកហ៊ូទូហ្សៃអ៊ែរទាំងនេះដែលសហការជាមួយក្រុមអ៊ីនធើរ៉ាហាមវេ មិនត្រឹមតែវាយប្រហារតែជនទុតស៊ីប៉ុណ្ណោះទេ ប៉ុន្តែវាយប្រហារទាំងជនម្ចាស់ស្រុកទៀតផង ដើម្បីដណ្តើមសិទ្ធិកាន់កាប់ដីដែលខ្លួនបានបាត់បង់បន្ទាប់ពីឆ្នាំ១៩៨១និងជាពិសេសបន្ទាប់ពីឆ្នាំ១៩៩៣ ។ គិតត្រឹមឆ្នាំ១៩៩៦ ជនបាហ៊ុនដេនិងជនបានយ៉ាងហ្គូចំនួន២៥ម៉ឺននាក់បានបង្ខំចិត្តចាកចេញពីតំបន់ម៉ាស៊ីស៊ី ។

«ការបះបោរលើកទីមួយ» គឺជាមូលហេតុយ៉ាងច្បាស់ក្រឡែតនៃជម្លោះនេះ ។ នៅក្នុងនាមជាអ្នកការពារសុវត្ថិភាពរ៉្វាន់ដានិងការពារជនទុតស៊ីនៅក្នុងជំរំជនភៀសខ្លួនពីការវាយប្រហាររបស់កងជីវពលហ៊ូទូ អនុប្រធានាធិបតីរបស់រ៉្វាន់ដាបានជួយ «ក្រុមសម្ព័ន្ធមិត្តនៃកងកម្លាំងប្រជាធិបតេយ្យដើម្បីរំដោះប្រទេសកុងហ្គោ-ហ្សៃអ៊ែរ (Alliance of Democratic Forces for the Liberation of Congo-Zaire)» របស់ប្រធានាធិបតីកុងហ្គោ ខាប៊ីឡា ដើម្បីផ្តួលរំលំជនផ្តាច់ការ ម៉ូប៊ូទូ (ជនជាតិហ្សៃអ៊ែរដែលនិយមហ៊ូទូ) ។ នៅក្នុង «ការបះបោរលើកទីមួយ» នេះ «ក្រុមសម្ព័ន្ធមិត្តនៃកងកម្លាំងប្រជាធិបតេយ្យដើម្បីរំដោះប្រទេសកុងហ្គោ-ហ្សៃអ៊ែរ» បានផ្តោតការវាយប្រហារទៅលើក្រុមអ៊ីនធើរ៉ាហាមវេ ជនហ៊ូទូសញ្ជាតិកុងហ្គោ និងកងទ័ពសម្ព័ន្ធមិត្តកុងហ្គោព្រមទាំងបានធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន ហ៊ូទូមកពីរ៉្វាន់ដាប្រមាណ៧សែននាក់ ។ បើទោះបីជាកងជីវពលដែលជាជនម្ចាស់ស្រុកខ្លះបានគាំទ្រការបះបោរប្រឆាំងនឹងជនផ្តាច់ការក្តី មិនយូរប៉ុន្មានអ្នកទាំងនេះចាប់ផ្តើមព្រួយបារម្ភថា ការបះបោរនេះអាចក្លាយទៅជាការដណ្តើមកាន់កាប់«ខេត្តគីវូ» ដោយជនជាតិរ៉្វាន់ដា ។ ម៉ាំដានី បានពន្យល់ថា «នៅក្នុងគំនិតរបស់ជនម្ចាស់ស្រុកនៅក្នុងខេត្តគីវូ កងទ័ពរ៉្វាន់ដាដែលមានក្រោយពីព្រឹត្តិការណ៍ប្រល័យពូជសាសន៍គឺជាសញ្ញានៃអំណាចរបស់ក្រុមទុតស៊ី ហើយអំណាចនេះនឹងត្រូវប្រើប្រាស់ដើម្បីឲ្យជនទុតស៊ីអះអាងថាខ្លួនជាជនម្ចាស់ស្រុកនៅក្នុងប្រទេសកុងហ្គោ ឬកាន់តែអាក្រក់ជាងនេះទៅទៀត អំណាចនេះអាចនឹងត្រូវបានប្រើប្រាស់ដើម្បីភ្ជាប់ខេត្តគីវូមកជាខេត្តមួយរបស់ប្រទេសរ៉្វាន់ដា» ។ ដើម្បីបញ្ជាក់អំពីការព្រួយបារម្ភទាំងនេះ ការបះបោរនេះបានក្លាយទៅជាការសងសឹកនៅក្នុងខេត្តគីវូ ។ ជនទុតស៊ីសញ្ជាតិកុងហ្គោទាំងនេះបានប្រើប្រាស់ឱកាសនៃការបះបោរនេះដើម្បីដោះស្រាយការសងសឹកជាមួយសត្រូវរបស់ខ្លួន ។ នៅពាក់កណ្តាលដំបូងនៃឆ្នាំ១៩៩៧ ជនទុតស៊ីសញ្ជាតិកុងហ្គោមិនត្រឹមតែសម្លាប់ជនហ៊ូទូប្រមាណ៦នាក់នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវាយប្រហារលើជនម្ចាស់ស្រុកទៀតផង ។ បន្ទាប់មក ជនម្ចាស់ស្រុកបានឆ្លើយតបវិញដោយវាយប្រហារទាំងជនទុតស៊ីសញ្ជាតិរ៉្វាន់ដានិងទាំងជនទុតស៊ីសញ្ជាតិហ្សៃអ៊ែរ ។ សង្គ្រាមនេះបានបន្តរីករាលដាល ហើយនៅទីបំផុត

សង្គ្រាមនេះបានរាលដាលនៅក្នុងគ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់ហ្គ្រេតឡេក ។

កន្លងមក ខ្ញុំបានបញ្ជាក់រួចហើយអំពីបុព្វហេតុនិងការវិវត្តនៃសង្គ្រាមនៅក្នុងតំបន់ ដើម្បីយើងអាចសិក្សាអំពីបច្ចុប្បន្នកាលរបស់ប្រទេសរ៉្វាន់ដានៅក្នុងបរិបទរបស់វាទាំងមូល ។ ជាការពិតយើងមិនអាចនិយាយអំពី "ក្តីសង្ឃឹមសម្រាប់រ៉្វាន់ដា" ដោយមិនបានគិតអំពីក្តីសង្ឃឹមសម្រាប់តំបន់ហ្គ្រេតឡេកទាំងមូលនោះទេ ជាពិសេសសម្រាប់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។ នៅក្នុងជំពូកបន្ទាប់ ខ្ញុំចង់ពិនិត្យមើលទៅលើកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសន្តិភាពនៅក្នុងប្រទេសរ៉្វាន់ដាចាប់តាំងពីអំពើប្រល័យពូជសាសន៍ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាយុត្តិធម៌ ការពិត ការអត់ឱន និងការផ្សះផ្សាជាតិ ។ ឥឡូវនេះ ខ្ញុំនឹងនាំអ្នកអានទៅមើលកេរដំណែលនៃអំពើប្រល័យពូជសាសន៍និងឧបសគ្គនៅក្នុងកសាងសន្តិភាពនៅក្នុងប្រទេសរ៉្វាន់ដា ។

## ២) កេរដំណែលនៃអំពើប្រល័យពូជសាសន៍ និងឧបសគ្គនៅក្នុងការកសាងសន្តិភាពនៅប្រទេសរ៉្វាន់ដា

អំពើប្រល័យពូជសាសន៍មានឥទ្ធិពលយ៉ាងធំធេងទៅលើប្រទេសរ៉្វាន់ដា ។ បើទោះបីជាជាង៨ឆ្នាំបានកន្លងផុតទៅក៏ដោយ ក៏កេរដំណែលរបស់អំពើឃោរឃៅនេះនៅតែមានឥទ្ធិពលទៅលើគ្រប់វិស័យទាំងអស់របស់ប្រជាជនរ៉្វាន់ដាទាំង៨លាននាក់ ។ អំពើប្រល័យពូជសាសន៍នេះបានសម្លាប់ជីវិតប្រជាជនរ៉្វាន់ដាចំនួន ១លាននាក់ និងបណ្តាលឲ្យប្រជាជនចំនួន៣លាននាក់ត្រូវភៀសខ្លួនទៅកាន់ប្រទេសជិតខាង ។ នៅក្នុងជំរំជនភៀសខ្លួន ជនហ៊ូទូរាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិតដោយសារកង្វះខាតអាហារ ជំងឺ និងអំពើហិង្សា ។ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកបានពិពណ៌នាថា "អំពើប្រល័យពូជសាសន៍កាលពីឆ្នាំ១៩៩៤ បានបំផ្លិចបំផ្លាញរបៀបរបបសង្គម ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គម" ។ ដោយសារបម្លាស់ទីប្រជាជនដ៏សន្ធឹកសន្ធាប់ និងការប្រើប្រាស់អំពើរំលោភផ្លូវភេទជាអាវុធនៃសង្គ្រាម ជំងឺអេដស៍បានរីករាលដាលយ៉ាងខ្លាំងរហូតដល់អត្រា១១,២ភាគរយកាលពីឆ្នាំ២០០១ ។

អំពើហិង្សាបានធ្វើឲ្យមានការប៉ះពាល់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនរ៉្វាន់ដា ព្រមទាំងបណ្តាលឲ្យប្រជាជនបាត់បង់ជំនឿចិត្ត ។ ការបែកបាក់ជាតិពន្ធុធ្វើឲ្យស្ថានភាពរស់នៅពោរពេញដោយការមិនទុកចិត្តគ្នា ការភ័យខ្លាច និងកំហឹង ។ អង្គការគ្រូពេទ្យគ្មានព្រំដែនបានកត់សម្គាល់ថា "ក្នុងនាមជាជនទុតស៊ីឬជាជនហ៊ូទូមានន័យថា អ្នកត្រូវតែចងចាំថាអ្នកណាជាអ្នកសម្លាប់ឪពុកម្តាយរបស់អ្នក... ហើយអ្នកត្រូវតែស្រមៃថាអ្នកណាម្នាក់ដែលទំនងជានឹងសម្លាប់កូនចៅរបស់អ្នកនៅក្នុងរយៈពេល១០ឆ្នាំទៀត" ។ ជាងនេះទៅទៀត យោងតាមទិន្នន័យពីអង្គការសហប្រជាជាតិ ករណីនៃការរំលោភមានចំនួនប្រមាណពី២៥ម៉ឺននាក់ទៅ៥០ម៉ឺននាក់ ហើយក្មេងៗដែលមានកំណើតពីការរំលោភគឺជាវិបត្តិសង្គមយ៉ាងធ្ងន់ធ្ងរ ។ កាន់តែអាក្រក់ជាងនេះទៅទៀត ជនហ៊ូទូជាច្រើនដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ មិនបានសុំអភ័យទោសចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនឡើយ ហើយអ្នកទាំងនោះនៅតែបន្តជឿជាក់ថាខ្លួនបានធ្វើការងារមួយដើម្បីប្រជាជនរបស់ខ្លួន គឺសម្លាប់ជនឈ្លានពាន "ទុតស៊ី" ។ ឥទ្ធិពលចុងក្រោយបង្អស់របស់ការឃោសនាជ្រុលនិយមទាំងនោះគឺការបន្ថយតម្លៃជាមនុស្សរបស់ជនទុតស៊ី ។ គំនុំគំគួនមិនបានបញ្ចប់ត្រឹមជ័យជម្នះរបស់រណសិរ្សស្នេហាជាតិរ៉្វាន់ដានោះទេ ។ គំនុំនេះនៅតែបន្តញាំញីប្រទេសរ៉្វាន់ដាដដែល ។ អំពើប្រល័យពូជសាសន៍នេះបានធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់ប្រជាជនជាខ្លាំង ។ អ្នកខ្លះបានសម្តែងក្តីត្រេកអរដោយបានរួចជីវិតពីអំពើប្រល័យពូជសាសន៍ ប៉ុន្តែអ្នកខ្លះសម្តែងភាពអស់សង្ឃឹមរបស់ខ្លួន ហើយគិតថាខ្លួនគួរតែស្លាប់ទៅជាមួយសមាជិកក្រុមគ្រួសារនិងមិត្តភក្តិប្រសើរជាង ។ ជាការពិត គ្រប់ៗគ្នាអាចយល់បានអំពីជីវិតរស់នៅមួយដែលពោរពេញដោយទុក្ខសោក ដែលសូម្បីតែគ្រោងឆ្អឹងរបស់មនុស្សជាទីស្រលាញ់របស់ខ្លួននៅរាយប៉ាយតាមព្រះវិហារសាសនាគ្រិស្តមិនទាន់ត្រូវបានបញ្ចុះឲ្យបានស្រួលបួលនៅឡើយ ។ **(នៅមានត)**

**អាឌុំ លី**

# ការិយាល័យពត៌មានសាធារណៈ

*អគារលេខ៦៦ វិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ*

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែ្សតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ពត៌មានសាធារណៈ

# កុមារភាពរបស់ខ្ញុំ

ពេលដែលខ្មែរក្រហមឈ្នះសង្គ្រាមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ៩ឆ្នាំ ។ កាលនោះខ្ញុំរស់នៅខេត្តកំពង់ចាម ។ ផ្ទះខ្ញុំនៅជិតពេទ្យធំនិងជិតសាលាខេត្ត ។

ខ្ញុំនៅចាំថា មួយថ្ងៃមុននេះ កងទ័ពលន់នល់បានជិះម៉ាស៊ីនពីកំពង់ផែទៅត្រើយម្ខាងទៀត គឺដីរោងម៉ាស៊ីនភ្លើងបិទ ដើម្បីទទួលកម្មា-ភិបាលខ្មែរក្រហមមកចរចាគ្នាក្នុងបរិវេណសាលាខេត្តកំពង់ចាម ។ ឪពុកខ្ញុំបាននាំខ្ញុំទៅឈរតាមផ្លូវជាមួយប្រជាជនរាប់ពាន់នាក់ ដើម្បីអបអរសាទរកងទ័ពខ្មែរក្រហមដែលធ្វើដំណើរចូលសាលាខេត្ត ។ ម្នាក់ៗនាំគ្នាទះដៃដោយទឹកមុខញញឹមញញែមសង្ឃឹមថាសង្គ្រាមរវាងខ្មែរនិងខ្មែរចប់ហើយ ។ មីងម្នាក់ឈ្មោះ ធួន ជាអ្នកជិតខាងរបស់ខ្ញុំ ពេលត្រឡប់មកពីអបអរសាទរក្បួនខ្មែរក្រហមលាន់មាត់ថាៈ "គិតទៅអ្នកឈ្នះនិងអ្នកចាញ់ដូចតែគ្នា" ។ ដល់ពេលល្ងាចទាហានជើងទឹកលន់នល់បានដឹកជញ្ជូនកងទ័ពខ្មែរក្រហមតាមម៉ាស៊ីនឆ្លងត្រឡប់ទៅមូលដ្ឋាននៅដីរោងវិញ ។

ខ្ញុំឮថា មេបញ្ជាការទាហានម៉ាស៊ីនម្នាក់ដែលបានជូនដំណើរកងទ័ពខ្មែរក្រហមទៅវិញក្នុងម៉ាស៊ីនជើងចុងក្រោយត្រូវខ្មែរក្រហមអូសទម្លាក់ពីម៉ាស៊ីន ហើយបាញ់សម្លាប់ចោល ។ ដំណឹងនេះធ្វើឲ្យឪពុកខ្ញុំនិងអ្នកជិតខាងដែលបានទៅឈរទទួលខ្មែរក្រហមតាំងពីមាត់ទន្លេរហូតដល់សាលាខេត្ត ហើយបានឃើញកងទ័ពខ្មែរក្រហមថើបគ្នាជាមួយទាហានលន់នល់តាំងពីពេលថ្ងៃ មានការព្រួយបារម្ភជាខ្លាំងអំពីប្រផ្នូលមិនល្អដែលរង់ចាំទទួលវាសនាប្រទេសជាតិ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលពាសពេញទីក្រុងកំពង់ចាម ដោយគ្មានវត្តមានទាហានលន់នល់ការពារទីរួមខេត្តបន្តិចសោះ ។ ប្រហែលម៉ោង១០ព្រឹកខ្ញុំឃើញកងទ័ពខ្មែរក្រហមម្នាក់ដើរយឺតៗ នៅមុខផ្ទះខ្ញុំ ។ ដោយចង់ដឹងសភាពការណ៍ស្រុកទេស ឪពុកខ្ញុំក៏ចុះទៅសួរកងទ័ពខ្មែរក្រហមនោះ ។ កងទ័ពនោះប្រាប់ឪពុកខ្ញុំរៀបអីវ៉ាន់ចេញពីផ្ទះចំនួនបីថ្ងៃ ។ យើងក៏នាំគ្នារៀបចំអីវ៉ាន់ទាំងប្រញាប់ប្រញាល់ ។

ឪពុកខ្ញុំបានយកកាំភ្លើងមួយដើមទៅទុកនៅការិយាល័យមេព្រៃវិញ ។ នៅតាមផ្លូវកកស្ទះទៅដោយប្រជាជន ម្នាក់ៗគ្មានបានយករបស់របរទៅជាមួយច្រើនទេ ។ បន្តិចក្រោយមកកងទ័ពខ្មែរក្រហមប្រកាសឲ្យប្រជាជនធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួនវិញ ។ ឪពុកខ្ញុំក៏សម្រេចចិត្តធ្វើដំណើរត្រឡប់មកស្រុកស្អាងខេត្ត កណ្តាល ។ យើងដើររហូតលើកលែងតែពេលមកដល់ផ្លូវទាល់ត្រូវឆ្លងទឹកទើបមានកាណូតខ្មែរក្រហមមកដឹកយើង ។ បន្ទាប់ពីដើរបានពីរបីថ្ងៃ យើងមកដល់វត្តអន្ទង់សហើយសម្រាកនៅទីនោះពីរបីថ្ងៃ ។ ខ្មែរក្រហមបានដាំបាយអង្ករក្រហមនិងស្លម្ហូទទួលប្រជាជនជម្លៀស ។

បន្ទាប់ពីសម្រាកនៅវត្តអន្ទង់ស យើងបន្តដំណើរកាត់តាមពាមជីកង ព្រែកពោធិ៍ ជីហែ រការកោង ហើយធ្លាក់មកដល់កោះធំ ។ ដំណើរនេះចំណាយពេលជាងមួយខែ ។ នៅថ្ងៃចុងក្រោយយើងបានឆ្លងទូកមកកោះខ្សាច់ទន្លា ឃុំទឹកវិល ភូមិបទុមសាគរ ។

តាំងពីកើតដឹងក្តីមក ខ្ញុំមិនដែលដឹងថាខ្ញុំមានជីដូនជីតានៅស្រុកស្អាងទេ ហើយឪពុកម្តាយខ្ញុំក៏មិនដែលនិយាយពីសាច់ញាតិជិតឆ្ងាយប្រាប់ខ្ញុំដែរ ។ ប្រហែលម៉ោង៨យប់ឪពុកខ្ញុំបាននាំកូនដើរតម្រង់ផ្ទះឈើប្រក់ស្បូវមួយ ។ ភ្លាមនោះស្រាប់តែមានញាតិមិត្តចេញមកឈូឆរហើយស្រែកថាៈ "លោកបងស្រេងមកវិញហើយ" ។ ខ្ញុំឮដូច្នេះមានអារម្មណ៍សប្បាយ ព្រោះនេះជាលើកទីមួយហើយដែលខ្ញុំបានស្គាល់មាមីងជីដូនជីតា ។

ស្រុកស្អាងធ្លាក់ក្រោមការកាន់កាប់របស់ខ្មែរក្រហមតាំងពីសង្គ្រាមចាប់ផ្តើមមកម្ល៉េះ ។ ដូច្នេះសាច់ញាតិខ្ញុំទាំងអស់ត្រូវអង្គការចាត់ទុកជាអ្នកមូលដ្ឋាន ៦គ្រួសារខ្ញុំនិងអ្នកមកពីទីក្រុងជាអ្នកជម្លៀសដូច្នោះអ្នកភូមិមិនសូវរាប់រកទេ ។

បន្ទាប់ពីរស់នៅស្រុកស្អាងបានប្រហែល៩ឬ១០ខែ អង្គការ

ក៏ដឹកយើងមកខេត្តបាត់ដំបង ។ ម្តាយខ្ញុំសប្បាយចិត្តណាស់ ព្រោះនឹកថាពេលមកដល់ខេត្តបាត់ដំបងប្រាកដជាមានម្ហូបអាហារបរិភោគបរិបូណ៌ ព្រោះគាត់ធ្លាប់ឮប្រជាជននិយាយតៗគ្នាថា ខេត្តបាត់ដំបងសម្បូរអាហារហូបណាស់ ។ យើងជិះរថយន្តធំនិងរថភ្លើងរយៈពេល៣ថ្ងៃទើបមកដល់អូរដំបងខេត្តបាត់ដំបង ។ គ្រួសារខ្ញុំនិងអ្នកជម្លៀសពីរបីគ្រួសារទៀតត្រូវបញ្ជូនឲ្យមករស់នៅតាមដងស្ទឹងសង្កែក្នុងភូមិកំពង់សំបួរស្រុកសង្កែ ។

កាលនោះប្រហែលពាក់កណ្តាលឆ្នាំ១៩៧៦ ។ ខ្ញុំមកដល់ខេត្តបាត់ដំបងមិនយូរប៉ុន្មាន អង្គការបង្កើតសហករណ៍ហូបបាយរួម ។ មេភូមិបានស្នើឲ្យឪពុកខ្ញុំធ្វើជាចុងភៅនៅរោងបាយ ។ ប៉ុន្មានខែដំបូង ថ្វីដ្បិតតែហូបបាយរួម ប៉ុន្តែអាហារគ្រប់គ្រាន់ល្មមអាចរស់នៅបាន ។ ៤-៥ខែក្រោយមក របបអាហារកាន់តែខ្វះទៅៗ ប្រជាជនឈឺដោយសារខ្វះអាហារ ហើយស្លាប់កាន់តែច្រើន ។ ឪពុកខ្ញុំក៏ត្រូវបញ្ជូនទៅឲ្យធ្វើការទាំងថ្ងៃទាំងយប់ ។

ចុងឆ្នាំ១៩៧៦ មេភូមិឈ្មោះ តាឡួន ចាប់ផ្តើមស្រង់ប្រវត្តិរូបប្រជាជន ។ ឪពុករបស់ខ្ញុំក៏ត្រូវធ្វើប្រវត្តិរូបដែរ ប៉ុន្តែខ្ញុំមិនដឹងថាគាត់សរសេរអ្វីខ្លះនៅក្នុងក្រដាសនោះទេ ។

ចម្ងាយប្រហែលមួយគីឡូម៉ែត្រពីភូមិកំពង់សំបួរមានវត្តមួយឈ្មោះវត្តសំរោង ។ ប្រហែលដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានយកវត្តនេះធ្វើជាគុក ។ កាលនោះការសម្លាប់បានចាប់ផ្តើមហើយ ប៉ុន្តែមិនទាន់មានសភាពខ្លាំងក្លាទេ ។ ខ្ញុំចាំបានថា បុរសម្នាក់ធ្លាប់ធ្វើគិញពីសង្គមចាស់ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅគុកនេះ ។ បន្ទាប់ពីសម្លាប់បុរសនោះហើយឈ្លបភូមិម្នាក់ (ខ្ញុំភ្លេចឈ្មោះ) បានដើរបង្អើរពាក្យថាៈ "គិតទៅថ្លើមគិញឆ្ងាញ់ណាស់" ។ ប្រពន្ធឈ្លបនោះមិនសប្បាយចិត្តនឹងពាក្យសម្តីរបស់ប្តីទេ ហើយថែមទាំងជេរប្រទេចដាក់បណ្តាសាប្តីរបស់ខ្លួនថា "អ្នែងស៊ីថ្លើមគេឲ្យអ្នែងត្រូវគ្រាប់ងាប់ថ្ងៃណាមួយ..." ។ ក្រោយមកឈ្លបភូមិនេះក៏បាត់ខ្លួនរហូត ។ នៅពេលជំណាលគ្នានេះ យើងចាប់ផ្តើមឮឈ្មោះ "គោលោត" ជាឃាតកប្រចាំវត្តសំរោង ។ គោលោត កាចសាហាវណាស់ អ្នកណាក៏ខ្លាចដែរ ។ នរណាម្នាក់ដែលត្រូវអង្គការចាប់ខ្លួនចូលវត្តសំរោងហើយពិតជាត្រូវបានស្វាគមន៍ដោយ គោលោត ជាមិនខាន ហើយកម្របានចេញមកវិញណាស់ ។

ចូលដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់បុរសជាច្រើននាក់មកសម្លាប់នៅវត្តសំរោងនេះ ។ នៅភូមិកំពង់សំបួរ ភូមិនរានិងភូមិសំរោង មិនសូវមានបុរសនៅរស់រានមានជីវិតប៉ុន្មានទេ ។ សូម្បីតែអតីតជាងកាត់សក់ក៏ត្រូវខ្មែរក្រហមចោទថាធ្លាប់ធ្វើការបម្រើរបបលន់នល់ដែរ ។ ចូលដល់រដូវវស្សាឆ្នាំ១៩៧៧ ការចាប់ខ្លួនប្រជាជនមកសម្លាប់នៅគុកនេះមានសកម្មភាពកាន់តែខ្លាំងជាងមុន ។ ភូមិនានាដែលនៅជុំវិញគុកនេះមានសភាពស្ងាត់ជ្រងំគួរឲ្យព្រឺខ្លាច ។ នៅរោងបាយ ចុងភៅដាំបបររួមមួយខ្ទះធំដាក់អង្ករតែបីកំប៉ុងរាវកក្តុកធ្វើឲ្យអ្នកភូមិស្លាប់សឹងតែពាយស្មើរ តែរកមនុស្សរកប់សាកសពមិនបាន ។

ពេលនោះ ម្តាយខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការក្នុងកងនារីនៅឯស្វាយធំចម្ងាយ១០គីឡូម៉ែត្រពីភូមិ ។ យូរៗម្តងទើបគាត់បានមកជួបឪពុកខ្ញុំនិងកូនៗ ។ ឪពុកខ្ញុំធ្វើការនៅជុំវិញភូមិជាមួយកូនបួននាក់ ។ បងប្រុសធំបង្អស់របស់ខ្ញុំឈ្មោះ ប៊ុនថន ធ្វើការនៅក្នុងកងចល័តកុមារ ។

ឪពុកខ្ញុំមានទឹកមុខស្រពោនជានិច្ច ។ ខ្ញុំមិនដែលសួរគាត់ថាមកពីមូលហេតុអ្វីទេ ប៉ុន្តែខ្ញុំគិតថាគាត់ពិតជាព្រួយដោយឃើញមនុស្សបាត់ខ្លួនរៀងរាល់យប់ ។ ម្នាក់ៗដឹងថា វេនរបស់ខ្លួននឹងមកដល់ក្នុងពេលឆាប់ៗជាមិនខាន ។ ថ្ងៃមួយហាក់ដូចជាចម្លែកខុសពីធម្មតា ខ្ញុំឃើញឈ្លបខ្មែរក្រហមដើរកាត់មុខផ្ទះខ្ញុំទាំងកណ្តាលថ្ងៃខ្ញុំត្រង់តែម្តង ហើយលួចចោលកន្ទុយភ្នែកមកផ្ទះខ្ញុំជារឿយៗ ។ ឪពុកខ្ញុំដឹងថាពេលវេលារបស់គាត់ជិតមកដល់ហើយ ។

យប់មួយ ម៉ោងប្រហែល៨ ឪពុកខ្ញុំទើបតែឡើងមកពីស្ទឹងសង្កែ ដោះមងបានត្រី៣-៤ស្មោរចែកកូនៗហូប ។ ខ្លួនគាត់អត់ពាក់អាវទេ មានតែក្រណាត់យ័ន្តពណ៌សមួយផ្ទាំងពុំដឹងសល់ពីណាពីណីមកដែលគាត់យកមកស្លៀកជំនួសក្រមា ។ គាត់រៀបចំចូលដំណេកទាំងក្រពះស្រេកឃ្លានជាមួយកូនតូចៗដែលអង្គុយរហង់មើលមុខឪពុក ។ ខ្ញុំអង្គុយក្រោមផ្ទះសម្លឹងមើលដើមដូងទាំងស្រេកឃ្លាន ក្នុងចិត្តគិតថា យប់ជ្រៅបន្តិចនឹងឡើង

ល្ហួចបេះផ្លែដូងហូប ។

កំពុងតែសម្លឹងដើមដូងភ្លឹះៗ ស្រាប់តែខ្ញុំឃើញស្រមោលធំមួយនិងចង្កៀងផ្លុងៗសំដៅមកផ្ទះរបស់ខ្ញុំ ។ ខ្ញុំបុកពោះភឹប តក់ស្លុតភ្លាម ដឹងថាដល់វេនឪពុកខ្ញុំហើយ ។ មែន! ពេលដែលចង្កៀងនោះមកជិតដល់ជណ្តើរផ្ទះខ្ញុំ ខ្ញុំឮសំឡេងស្ត្រីម្នាក់ស្រែកហៅឪពុកខ្ញុំតិចៗៈ «ស្រេងអើយស្រេង!» ខ្ញុំស្គាល់សំឡេងនោះថាគ្មាននរណាក្រៅពី យាយដា ប្រពន្ធមេភូមិឈ្មោះ តាឡួន ដែលអ្នកផងខ្លាចដូចខ្លា ។ យាយដា មកជាមួយឈ្លបបីនាក់ដែលកាន់កាំភ្លើងបីដើម ។

យាយដា ដើរត្រឡប់ទៅវិញ ទុកឲ្យឈ្លបបីនាក់នោះឡើងលើផ្ទះចាប់ឪពុកខ្ញុំចង ។ ភ្លាមនោះ ខ្ញុំឮសំឡេងប្អូនរបស់ខ្ញុំទាំងបីនាក់ស្រែកយំហ៊ូៗឡើង ។ ឈ្លបម្នាក់លួងលោមប្អូនៗខ្ញុំថា «កុំយំបងយកឪពុកអូនឯងទៅរៀនសូត្រតែបន្តិចទេគាត់មកវិញហើយ» ។ ខ្ញុំឮសំឡេងឪពុកខ្ញុំស្រែកថា «ខ្ញុំខុសអី? ខ្ញុំខុសអី? កូនខ្ញុំធ្វើអីខុសខ្ញុំអត់បានដឹងទេ ឲ្យខ្ញុំស្លៀកពាក់សិន» ។ ឈ្លបម្នាក់ឆ្លើយថា «មិនបាច់ស្លៀកពាក់អីទេ មកវិញឥឡូវហើយ» ។ ផ្ទះដែលគ្រួសារខ្ញុំរស់នៅនោះពីដើមជាកម្មសិទ្ធិរបស់ជាងជួសជុលរថយន្តម្នាក់ ។ ដូច្នេះនៅក្នុងផ្ទះនោះនៅសល់ដែកជាច្រើនកំណាត់នៅក្បែរជញ្ជាំង ។ ឈ្លបខ្មែរក្រហមម្នាក់យកដែកមួយកំណាត់មកវាយឪពុកខ្ញុំឮសូរភូស! ភូស! រួចអូសគាត់ចុះតាមជណ្តើរ ។ ចុះមិនទាន់ផុតពីជណ្តើរផងខ្ញុំឮស្នូរវាយបន្ថែមទៀត ឪពុកខ្ញុំស្រែកអូយ! អូយ! ទាំងឈឺចាប់ ។ ឈ្លបម្នាក់គំរាមពុកខ្ញុំថា «កុំស្រែកខ្លាំងពេក កុំឲ្យគេឮ» ។ ខ្ញុំលបមើលពីក្រោមផ្ទះទាំងក្តីរន្ធត់ ។ ពេលដែលឈ្លបកំពុងតែអូសគាត់ចេញទៅ ឪពុកខ្ញុំស្រែកលាកូនៗថា «ប៉ាលាហើយណា៎កូន» ។ មកដល់ពេលនេះ ថ្វីដ្បិតតែជិត៣០ឆ្នាំហើយក្តី ពេលណាដែលខ្ញុំនឹកឃើញដល់ពាក្យនេះ ខ្ញុំស្រក់ទឹកភ្នែកតែម្នាក់ឯង ។

ពេលឈ្លបខ្មែរក្រហមនាំឪពុកខ្ញុំចេញបាត់ទៅ ខ្ញុំស្ទុះមកលើផ្ទះឃើញប្អូនខ្ញុំទាំងបីនាក់កំពុងយំខ្សឹកខ្សួល ។ យប់នោះខ្ញុំមានអារម្មណ៍រន្ធត់លាយឡំនឹងភាពឯកោរហូតគេងមិនលក់ ។ ប៉ុន្មានម៉ោងក្រោយមក មេភូមិនិងកងឈ្លបបាននាំគ្នាមកឆែកឆេរផ្ទះខ្ញុំទាំងយប់ ។ អ្នកទាំងនោះជជុះអីវ៉ាន់របស់ក្រុមគ្រួសារខ្ញុំ ហើយឃើញកូនសៀវភៅតូចមួយដែលឪពុកខ្ញុំកត់ត្រាថ្ងៃខែឆ្នាំកំណើតរបស់កូនៗទាំងអស់និងកូនរូបថតរបស់ឪពុកខ្ញុំកាលពីក្មេងថតពាក់ក្រវ៉ាត់ក ។ តាឡួន ដែលជាមេភូមិលាន់មាត់ថា «ឃើញទេ ទាល់តែធ្វើមេព្រៃខ្លាំងហើយបានជាមានកូនសៀវភៅនិងបេះថតរូបរបៀបនេះ» ។ មេភូមិនោះបន្ថែមថា នឹងយកវត្ថុទាំងពីរនេះធ្វើជាភស្តុតាងបញ្ជូនទៅគុកដើម្បីកាត់ទោសឪពុកខ្ញុំ ។ ខ្ញុំសន្និដ្ឋានថា ឪពុកខ្ញុំត្រូវខ្មែរក្រហមយកទៅដាក់នៅគុកសំរោងនេះឯង ។

ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំយល់សប្តិឃើញឪពុកខ្ញុំមកស្តីបន្ទោសឲ្យខ្ញុំថា «ហេតុអ្វីបានជាឯងឲ្យរូបថតអញទៅវា?» ខ្ញុំភ្ញាក់ពីដំណេកទាំងភ័យញ័រទ្រូងភឹបៗ ព្រោះសំឡេងនោះហាក់ដូចជាសំឡេងមនុស្សរស់ស្រែកដាក់ត្រចៀកខ្ញុំ ។ បងប្រុសខ្ញុំឈ្មោះ ប៊ុនថន បានសុំច្បាប់មេកងដើម្បីមកសួរសុខទុក្ខឪពុកខ្ញុំនៅភូមិ ។ នៅតាមផ្លូវ គាត់ចាប់បានកង្កែបធំមួយ ។ គាត់គិតថា មកដល់ផ្ទះនឹងចម្អិនកង្កែបនេះឲ្យឪពុកពិសា ។ លុះពេលគាត់ឡើងដល់លើផ្ទះប្អូនខ្ញុំគ្រាន់តែក្រឡេកឃើញមុខគាត់ក៏យំហ៊ូ ។ ប៊ុនថន សួរថា «ហេតុអីបានជានាំគ្នាយំ? ចុះប៉ាទៅណាហើយ?» សំណួរនេះធ្វើឲ្យប្អូនៗខ្ញុំយំកាន់តែខ្លាំងថែមទៀត ។ វាឆ្លើយទាំងអួលដើមកថា «ប៉ាត្រូវគេចាប់ហើយ» ។ គ្រាន់តែឮពាក្យនេះ ប៊ុនថន ក៏យំដែរ ។ ខ្ញុំនិងគាត់ក៏បង្កាត់ភ្លើងអាំងកង្កែបនោះឲ្យប្អូនៗញ៉ាំ ។ បន្ទាប់ពីឲ្យប្អូនញ៉ាំកង្កែបរួចហើយ ប៊ុនថន ក៏អៀវប្អូនស្រីពៅទៅជួបម្តាយខ្ញុំនៅកងចល័តរបស់គាត់ ទុកប្អូនឯទៀតនៅភូមិ ។ ម្តាយខ្ញុំឃើញ ប៊ុនថន អៀវប្អូនទៅដល់គាត់ឆ្ងល់ហើយសួរថា «ហេតុអ្វីបានជានាំវាមកទីនេះ?» ប៊ុនថន ស្រក់ទឹកភ្នែកឆ្លើយទាំងអួលដើមកថា «ប៉ាត្រូវគេយកទៅហើយ» ។ ម្តាយខ្ញុំមិនសម្តែងការភ្ញាក់ផ្អើលទេ គាត់ឱនមុខចុះយំស្ងាត់ៗមិនឲ្យនរណាឃើញ ។ ស្ត្រីនៅក្នុងកងរបស់គាត់ភាគច្រើនសុទ្ធតែមេម៉ាយដោយសារប្តីត្រូវខ្មែរក្រហមសម្លាប់ ។

ប៉ុន្មានខែក្រោយមក ម្តាយខ្ញុំត្រូវមេកងបញ្ជូនមកភូមិកំពង់សំបួរវិញឲ្យធ្វើការជិតភូមិដើម្បីបាននៅជាមួយកូន ។ មិនបាន

ប៉ុន្មានផង អង្គការបញ្ជូនក្រុមគ្រួសាររបស់ខ្ញុំនិងគ្រួសារមួយទៀតឲ្យទៅរស់នៅក្នុងព្រៃនាមឈ្មោះ អូរសទូក ចម្ងាយប្រហែល៣០ទៅ៤០ពីភូមិកំពង់សំបួរ ។ ទៅដល់អូរសទូកបានកន្លះថ្ងៃ ខ្ញុំប្រាប់ម្ដាយខ្ញុំថា ខ្ញុំមិនចេះរស់នៅក្នុងព្រៃបែបនេះទេ ព្រោះគ្មានអ្វីទាំងអស់ ហើយសម្បូរមូសទៀត ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំមានគម្រោងលួចរត់ត្រឡប់ទៅភូមិវិញដើម្បីលួចស្រូវនិងដំឡូងខ្លះយកមកឲ្យម្ដាយនិងប្អូនៗហូប ។ ម្ដាយខ្ញុំយល់ព្រមនឹងគំនិតនេះ ។ ខ្ញុំបានបបួលស្ត្រីចំណាស់ម្នាក់និងក្មេងប្រុសម្នាក់ទៀតឈ្មោះ កែវ មកជាមួយគ្នា ។ ម៉ោង៣ទៀបភ្លឺខ្ញុំរៀបចំចេញដំណើរ ។ ម្ដាយខ្ញុំជូនពរខ្ញុំឲ្យជួបតែសេចក្ដីសុខតាមផ្លូវ និងបួងសួងឲ្យព្រលឹងឪពុកខ្ញុំតាមថែរក្សាខ្ញុំផង ។

យើងទាំងបីនាក់ដើរពេញមួយថ្ងៃដោយអត់មានបាយចូលពោះសូម្បីតែ១គ្រាប់ ។ យើងដើរកាត់វាលស្ងាត់ជ្រងំឃើញស្រូវស្កកពេញស្រែដោយសារគ្មានទឹក ។ ផុតពីអូរសទូកចូលដល់វាលក្របីស្លុយ អន្ស្រាម ភូមិបាយ័នដែលគ្មានមនុស្សរស់នៅ វាលដៃទ័ព វាលស្រីស្រណោះ ។ វាលស្រីស្រណោះពិតជាគួរឲ្យស្រណោះមែន ឮសូរតែសំឡេងចាបយំពីដើមក្ទម្មមួយទៅដើមក្ទម្មមួយទៀត ។ ឃើញវាលទាំងនេះ ខ្ញុំនឹកឃើញពេលដែលអង្គការទើបជម្លៀសមកដំបូង ក្រុមគ្រួសារខ្ញុំធ្លាប់មកធ្វើការនៅវាលនេះប៉ុន្មានខែដែរ ប៉ុន្តែឥឡូវនេះឪពុកខ្ញុំត្រូវអង្គការសម្លាប់បាត់ហើយ ។

កំពុងតែដើរយ៉ាងលឿន ស្រាប់តែមានមនុស្សបីនាក់កាន់កាំភ្លើងលោតចុះពីលើដើមឈើមកសម្លុតយើងថា «លើកដៃ!» ។ ខ្ញុំភ័យណាស់ ។ មនុស្សបីនាក់នោះឆែកឆេរខ្លួនយើង រួចហើយអនុញ្ញាតឲ្យយើងបន្តដំណើរ ។ ខ្ញុំគិតថា ក្រុមនោះមិនមែនជាកងទ័ពខ្មែរក្រហមទេ សូម្បីតែសម្លៀកបំពាក់ក៏មិនមែនពណ៌ខ្មៅដែរ ។ បើក្រុមនោះជាខ្មែរក្រហមម្ល៉េះគេមិនលែងយើងឡើយ ។ ពេលល្ងាចយើងមកដល់ភូមិ ។ ស្ត្រីចំណាស់ដែលមកជាមួយខ្ញុំបាននាំពួកខ្ញុំទៅដេកក្នុងផ្ទះរបស់គាត់នៅភូមិចុងតាកុកនិងគ្មានមនុស្សនៅ ។ ដេកបានប៉ុន្មានម៉ោងមេឃក៏ជិតភ្លឺ ។ យើងដាស់គ្នាងើបដើរមកភូមិសំរោងដើម្បីលួចស្រូវនៅក្នុងសហករណ៍ ។ ដើរបានបន្តិច ខ្ញុំចេះតែមានអារម្មណ៍មិនទុកចិត្ត អាកែវ ខ្លាចក្រែងគេចាប់វាបានវាឆ្លើយដាក់ខ្ញុំ ។ ដូច្នេះខ្ញុំក៏លួចដើរបែកផ្លូវពីវា ។ យប់នោះខ្ញុំលួចឡើងយកទឹកត្នោតក្រោយសហករណ៍ក្បែរគុកសំរោងដឹកឆ្អែត សល់ប៉ុន្មានខ្ញុំលាក់ទុកក្នុងស្មៅនៅភ្លឺស្រែជិតនោះ ។

ពេលនោះ ស្រូវចាប់ផ្ដើមទុំបន្តិចៗហើយ ។ ពេលថ្ងៃត្រង់ខ្ញុំទៅសម្ងំបូតស្រូវនៅក្នុងស្រែក្រោយគុកវត្តសំរោង ។ ទើបតែ



បូតស្រូវបាន១ថ្នក់ ស្រាប់តែពេទ្យខ្មែរក្រហមម្នាក់ចាប់ខ្ញុំបាន ។ ពេទ្យនោះប្រាប់ខ្ញុំថា ស្រូវនេះជាកម្មសិទ្ធិរបស់ពេទ្យវត្តញ្ញៀ លើកក្រោយកុំមកលួចទៀត ។ បុរសនោះនិយាយតែប៉ុណ្ណោះក៏លែងខ្ញុំឲ្យរួចខ្លួន ក៏ប៉ុន្តែនៅចម្ងាយប្រហែល៣០០ម៉ែត្រពីកន្លែងខ្ញុំនិងពេទ្យនោះឈរមានយោធាខ្មែរក្រហមមួយក្រុមកំពុងតែយាមអ្នកទោសឲ្យធ្វើការ ។ យោធាខ្មែរក្រហមស្រែកពីចម្ងាយមកថា «កុំអាលលែងវា ចាប់វាមកណេះ» ។ ខ្ញុំឮដូច្នេះព្រលឹងចុងសក់ នឹកក្នុងចិត្តថា អញដល់ថ្ងៃស្លាប់ហើយ ។ កម្មាភិបាលពេទ្យនោះ

ពួកគេនិយាយដូច្នោះក៏ស្ទុះមកចាប់ដៃខ្ញុំទាញទៅប្រគល់ឲ្យយោធាទាំងនោះ ។ យោធាម្នាក់បណ្តើរខ្ញុំចូលវត្តសំរោង ។ ខ្ញុំភ័យណាស់ ។ ចូលដល់ក្រោមកុដិខ្ញុំឃើញយោធាម្នាក់ទៀតកំពុងតែលីងស្រូវដាល់អំបុក ។ យោធាខ្មែរក្រហមម្នាក់នោះក៏ស្ទុះទៅយកកាំភ្លើងដែលនៅជិតខ្លួន ដកចំពុះទុងស្ទុះមកចាក់តម្រង់ក្បាលពោះខ្ញុំមួយទំហឹង ប៉ុន្តែខ្ញុំគេចផុត ។ ខ្ញុំស្រែកអង្វរទាំងភិតភ័យថា "កុំសម្លាប់ខ្ញុំ កុំសម្លាប់ខ្ញុំ មកពីខ្ញុំឃ្លានពេក" ។ យោធាម្នាក់ដែល



បណ្តើរខ្ញុំមក ក៏នាំខ្ញុំដើរកាត់ព្រៃចេកក្រោយវត្ត ។ ខ្ញុំគិតថាខ្មែរក្រហមកំពុងតែនាំខ្ញុំទៅសម្លាប់ហើយ ។ លុះដើរផុតចម្ការចេក ខ្ញុំឃើញអ្នកទោសក្មេងៗជាច្រើនកំពុងតែជម្រះស្មៅ ខ្ញុំក៏អន់ភ័យបន្តិច ។ យោធាខ្មែរក្រហមបញ្ជាឲ្យខ្ញុំធ្វើការជាមួយអ្នកទោសវ័យក្មេងទាំងអស់នោះ ។

បន្ទាប់ពីធ្វើការងាររួច ពេលល្ងាចយោធាខ្មែរក្រហមប្រមូលអ្នកទោសមកជួបជុំគ្នានៅមុខសាលាឆាន់ បន្ទាប់មកចែកបបរឲ្យម្នាក់មួយចាន ។ យើងបានរបបសម្លស្ងោរស្លឹកអង្គារដីម្នាក់មួយវែកហូបជាមួយបបរ ។

ហូបបបររួច យោធាខ្មែរក្រហមស្រែកកៀងអ្នកទោសក្មេងៗឲ្យចូលក្នុងគុកដែលជាអតីតសាលាឆាន់របស់វត្ត ។ ខ្មែរក្រហមមិនបានដាក់ខ្នោះយើងទេ ដោយសារយើងជាកុមារ ។ ចូលដល់ក្នុងគុក ខ្ញុំអង្គុយផ្អែកជញ្ជាំងអស់សង្ឃឹមរលីង ។ ភ្លាមនោះដោយនឹកឃើញថា ប្រមាណបីខែមុនឪពុកខ្ញុំក៏ត្រូវខ្មែរក្រហមចាប់ដាក់គុកនេះដែរ ខ្ញុំក៏ងើបទៅអើតមើលមុខអ្នកទោសចាស់ៗដែលកំពុងជាប់ខ្នោះអង្គុយផ្អែកជញ្ជាំង ។ ដោយងងឹតពេក ខ្ញុំមើលមិនសូវច្បាស់ទេ ។ ខ្ញុំពិនិត្យពីអ្នកទោសម្នាក់ទៅម្នាក់ទៀត ប៉ុន្តែនៅតែមិនឃើញឪពុកខ្ញុំ ។ ខ្ញុំគិតថាប្រហែលជាខ្មែរក្រហមសម្លាប់គាត់បាត់ទៅហើយ ។ ខ្មែរក្រហមយកអ្នកទោសទៅសួរចម្លើយនៅក្នុងកុដិមួយដែលនៅដាច់ពីគេបន្តិចនៅក្រោមដើមពោធិជិតវាលស្រែ ។ ខ្ញុំចាំថា កាលខ្ញុំមិនទាន់មកជាប់ក្នុងគុកនេះ ខ្ញុំដើរមកពីធ្វើការកាត់តាមវាលស្រែចម្ងាយប្រហែល៣០០ ម៉ែត្រពីគុកនេះ ខ្ញុំឮសំឡេងអ្នកសួរចម្លើយគំហកដាក់អ្នកទោស ឮស្នូរវាយដំអ្នកទោស និងសម្រែកឈឺចាប់របស់ជនរងគ្រោះ ។ ដល់ឮសំឡេងនោះញឹកញយពេកទៅខ្ញុំទៅជាលែងយកចិត្តទុកដាក់តទៅទៀត ។

ខ្ញុំកត់សម្គាល់ឃើញថា អ្នកទោសវ័យចំណាស់ដែលកំពុងជាប់ខ្នោះជើងនៅលើសាលាឆាន់នេះមានចំនួន១២នាក់ ។ ក្នុងមួយយប់ៗ គ្មានអ្នកទោសណាម្នាក់អាចដេកលក់ដោយស្រួលទេ ព្រោះបើកាលណាអ្នកទោសណាម្នាក់ចង់ងើបបន្ទោរបង់អ្នកទោសនោះត្រូវនិយាយខ្លាំងៗឲ្យអ្នកទោសផ្សេងទៀតឮ ដើម្បីងើបរំកិលខ្លួនទៅជាមួយដែរ ព្រោះខ្នោះដែលដាក់ជើងនោះជាខ្នោះវែងដែលដាក់ជើងអ្នកទោសទាំងអស់ជាប់គ្នាជាខ្សែ ។ ពេលងើបម្តងៗឮសូរតែសំឡេងរ៉ាវចុះរ៉ាវឡើង ។ នៅចំកណ្តាលសាលធំនោះគឺពាងមួយចំនួនសម្រាប់ឲ្យអ្នកទោសបន្ទោរបង់ដាក់ក្នុងនោះ ។ ដោយពាងអស់នោះស្ថិតនៅចម្ងាយតែ៤-៥ម៉ែត្រពីយើង អ្នកទោសទាំងអស់ដេកហិត អង្គុយហិតតែក្លិនស្អុយភាយៗចេញពីពាងនោះ ។

ខ្ញុំបានឃើញរបៀបដែលខ្មែរក្រហមយកបបរមកឲ្យអ្នក

ទោសចាស់ៗដែលកំពុងជាប់ខ្នោះ មើលទៅវេទនាណាស់ ។ ម៉ោងអាហារមកដល់ ចុងភៅសែងបបររាវកក្កុកលាយស្លឹកអង្គាដីចាស់ៗក្នុងធុងសាំងមួយដែលគេកាត់ពាក់កណ្តាលសម្រាប់ធ្វើជាឆ្នាំង មកដាក់នៅមុខអ្នកទោសទី១ក្បែរទ្វារ ។ ចុងភៅយកថ្ពិលដួសបបរដែលក្តៅគគុកនោះហុចឲ្យអ្នកទោសទី១ហុតភ្លាមៗតែម្តងដោយស្រែកបន្ទំថា «ឲ្យលឿនឡើងៗ» ។ អ្នកទោសតបវិញថា «សូមចាំបន្តិច ក្តៅណាស់» ។ ខ្ញុំសង្កេតឃើញថាអ្នកទោសហុតយឺតបន្តិចត្រូវចុងភៅឆក់យកថ្ពិលពីដៃមកចាក់បបរចូលធុងវិញ រួចក៏ដួសសាថ្មីហុចឲ្យអ្នកទោសបន្ទាប់នៅជិតនោះ ។ ចុងភៅធ្វើដូច្នេះរហូតដល់អ្នកទោសចុងក្រោយ ។ គិតទៅគ្មានអ្នកទោសណាម្នាក់បានហូបអស់បបរពីថ្ពិលនោះទេ ។

យប់ទីពីរដែលខ្ញុំចូលដល់ក្នុងគុក បុរសចំណាស់ម្នាក់ដែលកំពុងជាប់ខ្នោះទល់មុខខ្ញុំ ស្រែកខ្លាំងៗថា «ចុកពោះណាស់សុំទឹកក្តៅមួយពែងមក» ។ បុរសនោះចេះតែស្រែកមិនឈប់សោះ ។ ភ្លាមនោះ ទ្វាររបើកឡើង ខ្មែរក្រហមម្នាក់មាឌក្រអាញទាបបន្តិចភ្នែកធំក្រឡោត ដើរចូលមកហើយស្រែកសួរបុរសនោះថា «តាឯងស្រែករកអី?» បុរសចំណាស់ឆ្លើយថា «ខ្ញុំចុកពោះណាស់សុំទឹកក្តៅមួយពែងមក» ។ ខ្មែរក្រហមនោះគំហកឲ្យថា «តាឯងចង់បានទឹកក្តៅឬក៏ចង់ងាប់?» ។ គ្រាន់តែឮដូច្នេះ បុរសចំណាស់នោះក៏បាត់មាត់ឈឹងតែម្តង ។ សាលាឆាន់ដែលខ្ញុំកំពុងតែជាប់នេះគ្រាន់តែជាផ្នែកមួយនៃគុកវត្តសំរោងតែប៉ុណ្ណោះនៅមានអគារច្រើនទៀតដែលខ្ញុំមិនដឹងថាមានអ្នកទោសប៉ុន្មាននាក់ឡើយ ។

ដល់ថ្ងៃទី៣ ខ្មែរក្រហមបញ្ចេញអ្នកទោសឲ្យទៅជម្រះស្មៅបន្ទាព្រះខ្ទបនៅខាងក្រោយវត្តជិតកន្លែងសម្លាប់មនុស្ស ។ ពេលដែលកំពុងតែធ្វើការយោធាខ្មែរក្រហមបានស្រែកហៅអ្នកទោសឲ្យងើបឡើងម្នាក់ម្តងៗដើម្បីកត់ឈ្មោះអ្នកទោសដែលទើបចូលថ្មី ។ ខ្ញុំគិតថាប្រហែលជាខ្មែរក្រហមស្រង់ឈ្មោះដើម្បីរាយការណ៍ទៅភូមិដែលយើងរស់នៅហើយមើលទៅ ។ តាមពិត កាលពីខ្ញុំនៅក្នុងកងកុមារខ្ញុំមានឈ្មោះមិនសូវល្អទេ ព្រោះពេលណាដែលខ្ញុំឃ្លានខ្ញុំទៅលួចដកដំឡូង លួចបូតស្រូវ ហើយត្រូវខ្មែរក្រហមចាប់បានកសាងនិងធ្វើទារុណកម្មជាញឹកញាប់ ។ ដោយខ្លាចមេកងខ្ញុំរាយការណ៍មកខាងគុកដែលអាចបណ្តាលឲ្យយោធាគុកសម្លាប់ខ្ញុំចោលនោះ ខ្ញុំក៏ប្រថុយរត់ចេញពីគុកនេះ ។ ពេលដែលជិតដល់វេនខ្ញុំឡើងកត់ឈ្មោះ ខ្ញុំលួចលូនចេញតាមរបងលួសក្បែរជើងយោធានោះមួយរំពេច ។ កាលនោះម៉ោងប្រហែលពីររសៀល ។

ចេញផុតមកខាងក្រៅរបងហើយខ្ញុំមិនហ៊ានរត់ទេ ខ្លាចក្រែងអ្នកយាមដែលនៅក្បែរនោះចាប់ភ្លឹកសង្ស័យ ។ បន្ទាប់ពីដើរបានប្រហែល២០០ម៉ែត្រ ខ្ញុំធ្វើពុតជាអង្គុយចុះបត់ជើងធំក្បែរភ្លឺស្រែមួយ ។ ខ្ញុំក្រឡេកមើលក្រោយវិញមិនឃើញអ្នកយាមទាំងនោះមើលមកខ្ញុំសោះ ខ្ញុំក៏លើកខោវិញហើយងើបដើរសំដៅទៅចម្ការក្រូចនៅជិតនោះ ។ នៅតាមផ្លូវ ខ្ញុំបួងសួងដល់វិញ្ញាណក្ខន្ធឪពុកខ្ញុំឲ្យជួយថែរក្សាខ្ញុំ ជួយលាក់កំបាំងខ្ញុំកុំឲ្យខ្មែរក្រហមឃើញ ។ គ្រាន់តែមកដល់ចម្ការក្រូចភ្លាម ខ្ញុំរត់យ៉ាងលឿនសំដៅទៅភូមិកំពង់សំបួរ ហើយបន្តទៅភូមិនរា ។ ភូមិទាំងនោះស្ងាត់ជ្រងំមិនដឹងជាមនុស្សទៅណាអស់ ។ ខ្ញុំសប្បាយចិត្តណាស់ដោយបានរត់រួចពីគុក ។ នេះប្រហែលជាព្រលឹងឪពុកខ្ញុំតាមជួយខ្ញុំហើយ ។

បន្ទាប់ពីរត់រួចពីគុកសំរោងហើយ ខ្ញុំដើរមកជួបបងប្រុសខ្ញុំឈ្មោះ ប៊ុនថន ដែលកំពុងតែលើកដីជួសជុលផ្លូវថ្នល់ឯភូមិនរាចុងតាកុក ។ ប៊ុនថន ប្រាប់ខ្ញុំឲ្យនៅធ្វើការក្នុងកងជាមួយគាត់ទៅព្រោះគេឲ្យបបរខាប់ៗគួរសម ហើយអត់ឆែកឆេរប្រវត្តិរូបយើងទៀត ។ ខ្ញុំចូលរួមលើកដីបានមួយព្រឹកដែរ ប៉ុន្តែដោយខ្មែរក្រហមឲ្យបបរខាប់តែមួយចានហូបមិនឆ្អែត ខ្ញុំក៏ចាកចេញពីទីនោះដើរតម្រង់មកក្រុងបាត់ដំបង ។ តាមផ្លូវស្ងាត់ជ្រងំ ។ ដើរមកដល់មុខវត្តបាឡាដខ្ញុំឃើញបុរសម្នាក់អួសឈ្នាងពីក្នុងស្ទឹងសង្កែបានត្រីច្រើនណាស់ ។ ខ្ញុំឈរគោងមែកឈើតូចមួយអើតមើលបុរសនោះកំពុងតែអួសឈ្នាង ក្នុងចិត្តចង់ហូបត្រីនោះក្រៃលែង ។ ភ្លាមនោះមែកឈើក៏បាក់ ខ្លួនខ្ញុំធ្លាក់ចូលក្នុងផេះអង្កាមដែលគេដឹកពីរោងម៉ាស៊ីនកិនស្រូវវត្តបាឡាដមកចាក់ចោលនៅមាត់ស្ទឹងនេះ ។ ពេលធ្លាក់ចូលទើបខ្ញុំដឹងថាផេះនោះមិនមែនត្រជាក់ទេ គឺសុទ្ធតែរងើកភ្លើង ។ ជើងខ្ញុំរលាកក្តៅស្ទើរ

ទ្រាំមិនបាន ។ សំណាងល្អណាស់ដែលខ្ញុំដួលលើផ្នែកកៀនៗនៃគំនរផេះ ទើបខ្ញុំរលាកតែជើងឆ្វេងប៉ុណ្ណោះ ។ ខ្ញុំក៏ប្រមៀលខ្លួនចូលក្នុងស្ទឹងដើម្បីឲ្យបានត្រជាក់ ។ ខ្ញុំឃុំស្ងាត់ៗតែម្នាក់ឯងនៅក្នុងស្ទឹង ។ កំពុងតែឈឺស្រាប់តែខ្ញុំក្រឡេកឃើញក្រួចពោធិសាត់មួយផ្លែអណ្តែតមកជិតខ្លួន ។ ខ្ញុំក៏ស្ទុះរើសក្រូចនោះបកហូបភ្លាមមានកម្លាំងបន្តិច ។

ជើងឆ្វេងរបស់ខ្ញុំរួញសរសៃឡើងខ្ទុះលាត្រង់លែងបានហើយឡើងពងធំៗប៉ុនកដៃ ។ ខ្ញុំប្រវេប្រវាឡើងលើច្រាំងជាមួយជើងខាងស្តាំដែលនៅល្អ ។ អ្នកបររទេះកាត់តាមផ្លូវនេះឃើញខ្ញុំរលាកជើងដូច្នេះក៏ប្រាប់ខ្ញុំឲ្យយកអាចម៍គោស្រស់មកលាបកុំឲ្យឈឺ ។ ខ្ញុំក៏ធ្វើតាមតែមិនត្រឹមតែមិនបាត់ឈឺទេ ថែមទាំងស្អុយអាចម៍គោទៀត ។ ខ្ញុំខំលោតជើងមួយរហូតមកដល់ពេទ្យវត្តនរា ។ ខ្ញុំលោតចូលពេទ្យដើម្បីសុំថ្នាំខ្លះ ។ នារីពេទ្យម្នាក់ចេញមកស្តីឲ្យខ្ញុំថា «មិត្តឯងដើរលួចគេបានជាអ៊ីចឹង» ។ ខ្ញុំឆ្លើយថា «អត់ទេ ខ្ញុំដើរធ្លាក់ភ្លុក់ភ្លើងដោយចៃដន្យ» ។ នារីពេទ្យនោះយកថ្នាំមកចាក់ឲ្យខ្ញុំមួយម្ជុល ។ ខ្ញុំសម្គាល់ឃើញថា ថ្នាំដែលនារីពេទ្យនោះចាក់ឲ្យខ្ញុំគឺជាថ្នាំសម័យ មិនមែនថ្នាំអាចម៍ទន្សាយទេ ។ ចាក់ថ្នាំហើយខ្ញុំដេកនៅនឹងសំយ៉ាបពេទ្យខាងក្រៅព្រះវិហារ ។ មួយម៉ោងក្រោយមក ខ្ញុំក្រោកចេញពីទីនោះលោតជើងមួយទៅរកប៊ុនថន ដែលកំពុងតែលើកផ្លូវជិតនោះ ។ លោតបានបន្តិច ខ្ញុំឃើញសំបកអណ្តើកមួយដែលគេឆ្អៀលយកសាច់រួចហើយបោះចោល ប៉ុន្តែវានៅជាប់សាច់បន្តិចៗ ។ ខ្ញុំខ្វេះសាច់ដែលជាប់សំបកនោះហូបយ៉ាងឆ្ងាញ់ ។

ពេលដែល ប៊ុនថន ឃើញខ្ញុំពិការជើងដូច្នេះ គាត់និយាយថា «អញមិនដឹងជួយអ្ហែងយ៉ាងម៉េចទេ» ។ ខ្ញុំក៏ធ្វើដំណើរមកភូមិកំពង់សំបួរវិញបានជួបពូម្នាក់ឈ្មោះ ប៉ោ ដែលជម្លៀសមកពីស្រុកស្អាងដែរ ។ យប់នោះខ្ញុំដេកក្រោមខ្ទម ពូប៉ោ ។ គាត់ប្រាប់ខ្ញុំថា កុំទាន់ត្រឡប់ទៅព្រៃវិញអី ចាំគាត់ជាពីឈឺគាត់នឹងទៅជាមួយខ្ញុំ គាត់នឹងយកមងទៅដាក់បានត្រីចែកឲ្យម្តាយខ្ញុំហូបដែរ ។ គាត់និយាយទាំងរវើរវាយដូចក្មេង ។

ស្អែកឡើងរហូតដល់ថ្ងៃត្រង់ស្ទួរជួងហៅប្រជាជនទៅបើករបបអាហារហើយ ពូប៉ោ នៅតែពុំព្រមក្រោកទៅបើកបបរសោះ ។ ខ្ញុំទៅអង្រួនដាស់គាត់ ស្រាប់តែឃើញខ្លួនគាត់ឡើងជាំឈាមពេញខ្លួន ហើយគាត់កំពុងតែដកចង្កាមាន់ត្រដរខ្យល់ទៅហើយ ។ ភ្លាមនោះ យាយណុង ម្តាយរបស់ប្រធានភូមិបានមកដល់ស្តីឲ្យខ្ញុំថា «យើសអាថា! អ្ហែងមករកលួចទៀតហើយអ្ហេស?» ខ្ញុំឆ្លើយវិញថា «ទេ ខ្ញុំមកមើលពូប៉ោឈឺ» ។ យាយណុងតបមកវិញថា «ស្អី អ្ហែងដុកទ័រផង?» ។ យាយណុង ក៏ឲ្យបុរសពីរបីនាក់មកសែងខ្មោច ពូប៉ោ យកទៅកប់នៅក្រោមដើមស្វាយខ្ទិះមួយដើមនៅក្រោយផ្ទះ ។ តាមពិតខ្ញុំសង្ស័យថា ពូប៉ោ មិនទាន់ដាច់ខ្យល់ទេពេលដែលគេសែងគាត់យកទៅកប់នោះ ។

ភ្លាមនោះ មីងម្នាក់ឈ្មោះ លី ដើរមកប្រាប់ខ្ញុំថា ម្តាយខ្ញុំត្រូវខ្មែរក្រហមដឹកពីព្រៃមកដេកពេទ្យនៅវត្តញ្ញោហើយ ។ ខ្ញុំមិនជឿគាត់ទេ ប៉ុន្តែក៏ដាច់ចិត្តលោតជើងមួយចេញពីទីនោះទៅ ។

វត្តញ្ញោស្ថិតនៅមិនឆ្ងាយពីគុកវត្តសំរោងទេ គឺចម្ងាយប្រហែលពាគីឡូម៉ែត្រពីភូមិ ។ ដោយខ្ញុំពិការជើងម្ខាង ខ្ញុំចំណាយពេលយូរណាស់ទម្រាំទៅដល់វត្តញ្ញោ ។ ចូលដល់បរិវេណវត្តភ្លាមខ្ញុំក្រឡេកមើលចុះឡើងឃើញភួយពោះគោពណ៌ក្រហមមួយដែលខ្ញុំចំណាំបានថាជារបស់ម្តាយខ្ញុំតាំងពីឆ្នាំ១៩៧៤មក សំដិលហាលលើខឿនព្រះវិហារ ។ ខ្ញុំខំចែវជើងមួយតម្រង់ទៅទីនោះភ្លាម ។ ពេលនោះម្តាយរបស់ខ្ញុំងើបឡើងក្រឡេកឃើញខ្ញុំ គាត់ក៏ចុះពីលើវិហារមករកខ្ញុំយឺតៗ ។ មកជិតដល់ខ្ញុំ គាត់សួរខ្ញុំថា «ថាកូន! ថាកូន! ឯងឬក៏មិនមែន? ពិតជាឯងមែនឬ?» ខ្ញុំឆ្លើយថា «បាទខ្ញុំអាថាមែន» ។ គាត់ស្ទុះមកឱបខ្ញុំយ៉ាងណែន «ថាកូន! កូនឯងអាយុវែងណាស់ ។ ហេតុអីបានជា អាកែវ ប្រាប់ម៉ាក់ថាគេសម្លាប់ឯងហើយ ។ ម៉ាក់យំអាណិតឯងឡើងឈឺទើបគេដឹកម៉ាក់មកពេទ្យនេះ» ។ ខ្ញុំបានរៀបរាប់រឿងរ៉ាវទាំងអស់ប្រាប់គាត់ ។ ម្តាយខ្ញុំលាន់មាត់ថា «កូនឯងអាយុវែងណាស់» ។

នៅក្នុងពេទ្យនេះ របួសជើងខ្ញុំបានជាសះស្បើយបន្តិចម្តងៗ ។ ពេលនោះមានបាយហូបគួរសមដែរហើយព្រោះជារដូវច្រូតកាត់ ។ ប្អូនស្រីខ្ញុំម្នាក់ឈ្មោះ សុគន្ធា ដែលឈឺដោយអត់

អាហារហួសពេលមើលលែងជា ។ យប់មួយ សុគន្ធា មិនញុាំបាយមួយចានដែលជារបបរបស់នាងទេ ហើយទុកចានបាយចោលនៅចុងជើង ។ ខ្ញុំងើបទាំងកណ្តាលយប់ទៅលួចញុាំបាយនោះអស់ពាក់កណ្តាល ។ ព្រលឹមឡើង ខ្ញុំដេកជិត សុគន្ធា ប៉ុន្តែបែរមុខម្នាងទៀត ។ ពេលនោះខ្ញុំឮសំឡេងម្តាយខ្ញុំយំខ្សឹកខ្សួលតិចៗ ។ គាត់និយាយថា “គន្ធាស្លាប់ហើយ” ។ ខ្ញុំឮបែបនេះក៏ធ្វើមិនដឹងហាក់ដូចជាគ្មានអារម្មណ៍អីបន្តិចសោះ ព្រោះនៅក្នុងពេទ្យឃើញមនុស្សស្លាប់រាល់ថ្ងៃទាល់តែស៊ាំទៅហើយ ។ ខ្ញុំគ្រាន់តែនិយាយតិចៗថា “អ្ហ៎ វាស្លាប់ហើយអ្ហី?” ហើយខ្ញុំងាកមើលមុខប្អូនតែបន្តិចប៉ុណ្ណោះ ។ នារីពេទ្យយកស្នែងមកសែងសពប្អូនខ្ញុំយកទៅកប់នៅក្រោយវត្ត ។ ម្តាយខ្ញុំអូសខ្លួនតាមមើលដល់កន្លែងកប់ ប៉ុន្តែខ្ញុំមិនទៅមើលទេ ។

បីខែក្រោយមក ម្តាយខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ។ ប្រហែលជាម្តាយខ្ញុំដឹងខ្លួនថាគាត់មិនរស់ទេ ទើបគាត់ហៅខ្ញុំមកផ្តែផ្តាំថា “កូនម្តាយ! អត់ពីម៉ាក់ទៅកូនមិនបាច់ខំឱបក្រសោបជុំគ្នាទេ ។ បើពិបាកទេ មានអ្នកណាមកសុំពួកឯងយកទៅចិញ្ចឹមកូនទៅចុះ ។ សូម្បីពួកខ្មែរក្រហមក៏ដោយ បើមានមេភូមិណាចង់យកឯងទៅ ឯងទៅចុះ កុំនៅជុំគ្នា ។ បើទឹកដោះម្តាយថ្ងៃថ្ងៃណាមួយពួកឯងនឹងបានជួបគ្នាវិញជាមិនខាន ។ ស្រុកយើងមិនមែននៅអ៊ីចឹងរហូតទេ ។ គង់មានទ័ពអន្តរជាតិមកជួយយើងជាមិនខាន ។ បើស្រុកសាន្តត្រាណចូរកូនខំរៀនណា៎” ។ ខ្ញុំស្តាប់តាមបណ្តាំនេះដោយមិនទាំងយល់ថាម៉េចផង ហើយក៏ចេះតែចាំរហូតមក ។ គាត់បានប្រាប់ខ្ញុំអំពីសាច់ញាតិដែលមាននៅស្រុកណាខេត្តណាខ្លះ ហើយឲ្យទៅរកនៅថ្ងៃណាមួយ ។ ជាពិសេសគាត់ខស្សាហ៍និយាយអំពីបងប្រុសរបស់គាត់ពីរនាក់ឈ្មោះ ឡេង ស៊ីម និង ឡេង ស៊ីក នៅខេត្តតាកែវ ។

ប៉ុន្មានអាទិត្យក្រោយមក ម្តាយខ្ញុំនិយាយលែងរួច ។ ថ្ងៃមួយ តាំងពីព្រឹក គាត់ចេះតែស្រែកហៅឈ្មោះខ្ញុំ “ថា...ថា ថា...” ។ ខ្ញុំចេះតែឆ្ងល់ថាហេតុអ្វីបានជាម៉ាក់ហៅឈ្មោះខ្ញុំមិនឈប់ដូច្នេះ ។ ប្អូនស្រីពៅខ្ញុំនិងប្អូនប្រុសម្នាក់ចេះតែអង្គុយក្បែរគ្រែមើលមុខម្តាយខ្ញុំ ។ ដល់ពេលថ្ងៃត្រង់ទើបខ្ញុំភ្ញាក់ថា ប្រហែលជាម្តាយខ្ញុំជិតស្លាប់ទេដឹងបានជាគាត់ចេះតែហៅឈ្មោះខ្ញុំហើយដកកង្ដឹកៗដូច្នេះ ។ ខ្ញុំក៏រត់ទៅហៅពេទ្យឈ្មោះ មិត្តធួន ។ មិត្តធួនមកដល់មើលម្តាយខ្ញុំបន្តិច គាត់អង្អែលក្បាលខ្ញុំហើយនិយាយថា “ហួសពេលទៅហើយមិត្តប្អូន” ។ សម្តីនេះធ្វើឲ្យខ្ញុំដឹងភ្លាមថាម្តាយខ្ញុំស្លាប់ហើយ ។ ខ្ញុំចេះតែឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំមិនចេះមើលមនុស្សស្លាប់ ។

ម្តាយខ្ញុំស្លាប់ទៅហើយ ប៉ុន្តែភ្នែកគាត់បិទមិនជិតទេ ព្រោះមិនអស់អាល័យពីកូនតូចៗដែលអង្គុយរហង់ជុំវិញខ្លួន ។ គាត់ស្លាប់នៅខែប្រាំងឆ្នាំ១៩៧៧ក្នុងអាយុ៣២ឆ្នាំ ។ កន្លះម៉ោងក្រោយមកពេទ្យយកស្នែងមកសែងសពម្តាយខ្ញុំយកទៅកប់នៅព្រៃដែលកប់ប្អូនស្រីខ្ញុំពីមុន ។ ម្តងនេះខ្ញុំតាមទៅមើល ឯប្អូនៗខ្ញុំអត់បានទៅទេ ព្រោះនៅតូចៗពេកមិនយល់ហេតុការណ៍ ។ កម្មាភិបាលពេទ្យកប់ម្តាយខ្ញុំក្នុងផ្នូររាក់ៗនៅក្នុងប្រឡាយរីងស្ងួតមួយ ។

ល្ងាចនេះ ខ្ញុំអង្គុយផ្អែកជញ្ជាំងព្រះវិហាររំឭកឡើងវិញនូវអនុស្សាវរីយ៍កាលពីខ្ញុំនៅតូចរស់នៅខេត្តកំពង់ចាមជាមួយឪពុកម្តាយ ។ ខ្ញុំនឹកដល់កាលដែលប៉ាម៉ាក់នាំខ្ញុំដើរលេងជុំវិញក្រុងកំពង់ចាម ។ ឥឡូវនេះខ្ញុំក្លាយជាក្មេងកំព្រាដូចកុមារកំព្រាឯទៀតៗដែរ ។ គិតដល់ត្រង់នេះ ខ្ញុំងើបរត់តម្រង់ទៅរកផ្នូរម្តាយខ្ញុំទាំងព្រលប់ម៉ោងប្រហែល៨ ។ ទៅដល់ខ្ញុំយកដៃកាយផ្នូរដើម្បីមើលមុខម្តាយជាចុងក្រោយ ។ ខ្ញុំអង្អែលសក់គាត់ អង្អែលមុខគាត់ ហើយបួងសួងក្នុងចិត្តថា “សូមឲ្យម៉ាក់កើតជាតិណាៗកុំឲ្យវេទនាដូចជាតិនេះទៀត” ។ ខ្ញុំអង្គុយមើលមុខម្តាយដែលត្រជាក់ស្ពេកស្ពាំងទៅហើយនោះប្រហែល១៥នាទីទើបកាយដីកប់ទៅលើមុខគាត់វិញ ហើយដើរចេញទាំងក្តុកក្តួល ។ ក្រោយមក ពេលដើរទៅណាមកណាកាត់ក្បែរនោះ ខ្ញុំតែងតែក្រឡេកមើលទៅកន្លែងដែលកប់ម្តាយខ្ញុំហើយនឹកក្នុងចិត្តថា ម៉ាក់ខ្ញុំកំពុងតែនៅទីនោះ ។

ថ្វីដ្បិតតែខ្ញុំបានមករស់នៅប្រទេសអូស្ត្រាលីអស់រយៈពេល ២៨ឆ្នាំហើយក្តី ក៏ខ្ញុំនៅតែនឹកឃើញអនុស្សាវរីយ៍កុមារភាពទាំងនោះ ហើយសុបិនអាក្រក់ពីអតីតកាលនៅតែមកដាស់ខ្ញុំពីដំណេកស្ទើរតែរាល់រាត្រី ។

**ញ៉ៀម ប៊ុនថា**

# ជីវិតក្នុងភាពនឹងថ្កល់

**សាយ សំអន**

**យុទ្ធនារី**

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ សាយ ដូលី អាយុ៤៦ឆ្នាំ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម)*


សាយ សំអន ថតប្រហែលក្នុងឆ្នាំ១៩៧០

សំអន ជានារីសាមញ្ញម្នាក់មានរូបរាងស្អាតគួរសមដែរ ។ គាត់ជាកូនទី២នៃគ្រួសារដែលមានកូន៩នាក់ ។ អ្នកជិតខាងតែង សរសើរគាត់ថាជានារីសុភាពរាបសា រម្យទម បេះអាណិត ស្រលាញ់បងប្អូន ។ សំអាន រៀននៅវិទ្យាល័យកំពង់ចាមរហូត គាត់អាយុបាន១៦ឆ្នាំ ប៉ុន្តែគាត់ប្រលងធ្លាក់បាក់អង (Bac I) ធ្លាក់ ហើយចាកចេញពីផ្ទះមុនពេលរដ្ឋប្រហារឆ្នាំ១៩៧០ ។ ក្រោយមក គាត់បានផ្ញើសំបុត្រនិងលុយមួយចំនួនមកផ្ទះ ប៉ុន្តែ គាត់មិនដែលមកលេងទេ ។ សំបុត្ររបស់គាត់សរសេរសួរតែអំពី សុខទុក្ខនិងសុវត្ថិភាពរបស់ក្រុមគ្រួសារតែប៉ុណ្ណឹង ។

បងប្រុសខ្ញុំបាននាំ បងអាន ទៅភ្នំពេញដើម្បីគេចពីភាព ចលាចលនៅក្នុងភូមិ ។ បងប្រុសខ្ញុំមានបំណងរៀបចំឲ្យ បងអាន រៀបការជាមួយនឹងបុរសពោះម៉ាយម្នាក់ឈ្មោះ អ៊ុន ថា ។ អ៊ុន ថា ជាជាងជួសជុលម៉ាស៊ីន ក្រោយមកបានធ្វើជាវរសេនីយ៍ឯក នៅក្នុងរបបខ្មែរក្រហម ។ គាត់ជាអ្នកសុំ បងអាន រៀបការ ។ ក្រោយពេលរៀបការរួច អ្នកទាំងពីរមិនចុះសម្រុងនឹងគ្នាសោះ ។ បងអាន និយាយថាគាត់មិនស្រលាញ់ អ៊ុន ថា ទេ ។

ម្ដាយខ្ញុំចាំរឿងរ៉ាវរបស់បងស្រីខ្ញុំបានល្អជាងខ្ញុំ តែគាត់មាន បញ្ហាខាងខួរក្បាលដោយសារគាត់បានបាត់បង់កូនជាច្រើននាក់ នៅក្នុងរបបបីឆ្នាំ ។ ខ្មែរក្រហមបានសម្លាប់បងប្អូនខ្ញុំទាំងអស់៦ នាក់ ។ បងប្រុសខ្ញុំឈ្មោះ សាយ គឹមហៀង ត្រូវសម្លាប់ក្នុងឆ្នាំ ១៩៧៨ ។ គាត់ជាមេរបស់ខ្ញុំនៅសមរភូមិ និងជាអ្នកគ្រប់គ្រង កន្លែងបិតស្រាអង្ករប្រចាំតំបន់ ។ ពេលនោះនៅមានការជួញដូរ ស្រានៅឡើយ ។ ស្ត្រីដែលទើបនឹងសម្រាលកូនរួចផឹកស្រានេះ ដើម្បីរំលាយឈាម ។ ប្អូនប្រុសខ្ញុំម្នាក់ទៀតជាស្មៀនឃុំនៅ ក្នុងរបបលន់នល់ ដូច្នេះហើយទើបគាត់និងអ្នកជាប់ទាក់ទិនទាំង ប៉ុន្មានត្រូវខ្មែរក្រហមយកទៅសម្លាប់គ្មានសល់ ។ ខ្ញុំឮសួរថាបង ប្អូនស្រីៗខ្ញុំពីរនាក់ទៀតត្រូវអង្គការសម្លាប់នៅលើភ្នំ ប៉ុន្តែខ្ញុំមិន ដឹងថាអ្នកដទៃទៀតយ៉ាងម៉េចទេ ។

នៅរវាងឆ្នាំ១៩៧២-៧៣ ខ្មែរក្រហមព្យាយាមទម្លាក់ គ្រាប់បែកលើភូមិប្រហែលជាង១០ដងដែរ ប៉ុន្តែមិនដែលប៉ះចំ ម្ដងណាឡើយ ។ នៅពេលខ្ញុំអាយុបាន១៥ឆ្នាំ គណៈភូមិបង្ខំឲ្យខ្ញុំ ចូលបដិវត្តន៍នៅឆ្នាំ១៩៧៤ ។ ដំបូងខ្ញុំទៅជាមួយនឹងបងប្រុស


រូបថតអាពាហ៍ពិពាហ៍របស់ សាយ ដូលី និង អ៊ុន ថា ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨

ខ្ញុំឈ្មោះ ហៀង ទៅថ្មពួននៅក្នុងស្រុកព្រៃឈរ ។ ខ្ញុំស្ម័គ្រចិត្តទៅ ព្រោះកាលណោះបើខ្ញុំហ៊ានចាំតែមួយថ្ងៃពីរទៀតខ្ញុំពិតជាត្រូវអង្គការបង្ខំឲ្យកាន់កាំភ្លើងចូលសមរភូមិច្បាំងហើយ ។ ក្រោយមកខ្ញុំត្រូវបញ្ជូនទៅភ្នំបាសិតឲ្យបើកឡានដឹកអាវុធ ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវផ្លាស់ទៅភ្នំពេញដឹកស្រូវបន្ទៃពីក្រសួងពាណិជ្ជកម្មទៅសមរភូមិ ។ ខ្ញុំធ្វើកិច្ចការនេះរហូតដល់ឆ្នាំ១៩៧៨ ។ នៅឆ្នាំ១៩៧៩ មានការច្បាំងគ្នាដ៏ធំមួយ ទើបអង្គការប្រជុំសម្រេចថាជម្លៀសប្រជាជនទាំងអស់ឲ្យទៅរស់នៅខេត្តបាត់ដំបង ។

ខ្ញុំបានចាកចេញពីភ្នំពេញនៅយប់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ខ្ញុំជាអ្នកដឹកអង្ករឲ្យកងទ័ពដែលកំពុងតែច្បាំងជាមួយកងទ័ពវៀតណាមនៅតាមព្រំដែន ។ ចម្បាំងនេះចប់នៅឆ្នាំ១៩៨០ ។ ខ្ញុំរស់នៅក្នុងជំរំនៅស្ទាច់ក្បែរព្រំដែនថៃរហូតដល់ឆ្នាំ១៩៩១-៩២ទើបខ្ញុំត្រឡប់មកផ្ទះវិញ ។

ខ្ញុំប្រាប់កូនៗខ្ញុំពីរបបខ្មែរក្រហម ពីភាពនឿយហត់នឹងការងារ និងពីរឿងហូបមិនគ្រប់គ្រាន់ ។ កូនៗខ្ញុំជឿអ្វីដែលខ្ញុំនិយាយពេលដែលវាឃើញរូបថតផ្សាយតាមទូរទស្សន៍ ។ ខ្ញុំទូន្មានប្រដៅកូនៗអំពីរឿងនេះជាញឹកញាប់ថាឲ្យខំរៀនមានចំណេះដឹង ។ នៅសម័យខ្មែរក្រហមមានអ្នកចេះដឹងតិចតួចណាស់ ហើយអង្គការចាត់ឲ្យកសិករក្រីក្រកាន់តំណែងមេដឹកនាំ ។ ◆◆◆

## ស្រេង ស្រឿ
## អ្នកបើកឡានកងទ័ព

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ស្រេង ស្រាន់ អាយុ៥០ឆ្នាំ ត្រូវជានៅស្រុកកងមាស ខេត្តកំពង់ចាម)*


ស្រឿ ថតប្រហែលក្នុងឆ្នាំ១៩៧៥

បងស្រឿ បួសបានបីឆ្នាំ ទើបសឹកធ្វើជាសិស្សសាលាធម្មការវិញ ។ មិត្តភក្តិគាត់បញ្ចុះបញ្ចូលគាត់ឲ្យចូលបដិវត្តន៍ នៅឆ្នាំ១៩៧៣ នៅពេលគាត់អាយុបាន២២ ឆ្នាំ ។ កាលណោះខ្មែរក្រហមនិយាយថាគាត់មិនអាចនៅតែម្នាក់ឯងពេលដែលអ្នកភូមិគ្រប់គ្នាចូលបម្រើកងទ័ពអស់នោះទេ ។

ពេលដែលគាត់ចាកចេញខ្ញុំយំ ព្រោះម្តាយខ្ញុំបានចែកឋានទៅហើយ ខ្ញុំមានតែគាត់ម្នាក់ប៉ុណ្ណោះ ។ កាលណោះប្រហែលពីរបីថ្ងៃមុនពេលពុកខ្ញុំដឹងថាបងប្រុសខ្ញុំចូលរួមចលនាបដិវត្តន៍ គាត់ខឹងខ្លាំងណាស់ គាត់ចេញទៅដើររកបងប្រុសខ្ញុំ ។ ឪពុកនិយាយថា ដំបូងប្រពន្ធស្លាប់ ឥឡូវនេះកូនប្រុសចង់រត់ចោលគាត់ទៀត ។

បងស្រឿ មកលេងផ្ទះបីបួនដងដែរនៅឆ្នាំ១៩៧៥ ។ ដោយសារគាត់បើកឡានឲ្យខ្មែរក្រហម ពេលគាត់មកផ្ទះ គាត់ជិះឡានឡង់រ៉ូវែរមកជាមួយនិរសាររបស់គាត់ ។ កាលណោះយន្តហោះមកទម្លាក់គ្រាប់បែកនៅតាមផ្លូវដែលគាត់ធ្វើដំណើរមកភូមិ ។ មានពេលមួយគាត់ខ្ទាតចេញពីឡាន ហើយទៅសម្ងំនៅក្នុងលេណដ្ឋាន ។ មានពេលខ្លះទៀត គាត់ចាំបាច់ត្រូវបើកឡានឲ្យលឿនដើម្បីគេចពីគ្រាប់បែក ។

យប់មួយពេលខ្ញុំកំពុងដេក បងស្រឿ មកគោះទ្វារដាស់ខ្ញុំ ។ គាត់បានយករូបថតទាំងអស់នេះមកជាមួយ ។ គ្រាន់តែឃើញគាត់ខ្ញុំរំភើបស្រក់ទឹកភ្នែក ។ គាត់ផ្តាំឲ្យខ្ញុំមើលថែទាំពុក ប៉ុន្តែតាមពិតពុកបានស្លាប់តាំងពីពេល បងស្រឿ មកផ្ទះលើកមុនម៉្លេះ ។ បងស្រឿ និយាយថា បើទោះជាគាត់ស្លាប់ក៏ខ្ញុំមិនដឹង ហើយខ្ញុំស្លាប់ក៏គាត់មិនដឹងដូចតែគ្នាហ្នឹង ។ គាត់ហាក់បីដូចជាមានការអៀនខ្មាសដែរ ។

ពេលគាត់មកលេងម្តងទៀត គាត់យកប្អូនប្រុសពីរនាក់ទៅភ្នំពេញជាមួយគាត់ ។ ខ្ញុំមិនបានទទួលដំណឹងអ្វីពីប្អូនទាំងពីរនោះទេ ។ ក្រៅពីនេះប្រពន្ធ បងស្រឿ ក៏បាត់ខ្លួនដែរ ចំណែកឯកូនស្រីតូចរបស់គាត់ក៏ស្លាប់ទៀត ។

ខ្មែរក្រហមចង់សម្លាប់ខ្ញុំ និងប្របាច់កសម្លាប់កូនស្រីខ្ញុំ ព្រោះតែបងប្រុសខ្ញុំជាកម្មាភិបាលជាន់ខ្ពស់ ។ អង្គការថាខ្ញុំហូបច្រើនដោយសារតែខ្ញុំមានសាច់ញាតិជាអ្នកធំៗ ។ ផ្ទុយទៅវិញ ខ្ញុំឃ្លានណាស់សឹងតែពរកូនមិនរួច ។ ក្រោយខ្ញុំសម្រាលបានកូនទីពីរ ខ្ញុំត្រឡប់ទៅរែកដីសង់ទំនប់ដូចមុនទៀត ។ សព្វថ្ងៃនេះសុខភាពខ្ញុំមិនសូវមាំទាំប៉ុន្មានទេ ។

◆◆◆

# ដួង ញ៉ៅ
## យុទ្ធជនភូមិភាគ១០៦

*(បទសម្ភាសន៍ជាមួយបងប្រុសឈ្មោះ ដួង អុល អាយុ៦២ឆ្នាំ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម)*



ដួង ញ៉ៅ (កណ្តាល) ថតនៅអង្គរវត្ត ប្រហែលក្នុងឆ្នាំ១៩៧៥

ប្អូនញ៉ៅ បានចាកចេញពីផ្ទះទៅខេត្តសៀមរាបជាមួយនឹងប្អូនប្រុសទីបីឈ្មោះ ធួន ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ ។ ញ៉ៅ ធ្វើជានិរសារឲ្យគណៈខេត្តឈ្មោះ សុទ្ធ ។ គេនិយាយថា សុទ្ធ ឈ្លោះប្រកែកគ្នា ហើយគាត់ក៏ត្រូវចាប់ខ្លួន ។ អ្នកនៅក្នុងភូមិទាំងមូលនិយាយពីរឿងនេះពីមាត់មួយទៅមាត់មួយ ។ ដោយសារ សុទ្ធ ត្រូវអង្គការចាប់ខ្លួននៅពេលយប់ ដូច្នេះយើងទាំងអស់គ្នាសន្និដ្ឋានថាគាត់ត្រូវសម្លាប់ចោលហើយ ។ ញ៉ៅ បាត់ខ្លួនតាំងពីពេលនោះមក ខ្ញុំក៏មិនដឹងថាហេតុអ្វីដែរ ។

ក្រោយថ្ងៃរំដោះ ប្អូនប្រុសខ្ញុំឈ្មោះ សឿន ត្រូវជម្លៀសចេញពីភូមិកំណើត ។ ខ្ញុំគិតថា សឿន បែបត្រូវអង្គការសម្លាប់ចោល ព្រោះពេលគាត់កំពុងតែភ្ជួរដី ស្រាប់តែខ្មែរក្រហមមកចងដៃគាត់ដឹកទៅភ្នំជាមួយនឹងមនុស្សពីរបីនាក់ទៀត ។ ខ្ញុំនិយាយអ្វីលែងចេញពេលដែលឃើញហេតុការណ៍នេះ ។ ខ្ញុំប្រាប់ខ្លួនឯងថាកុំឲ្យធ្វើអ្វីទាំងអស់ ព្រោះខ្លាចអង្គការយកខ្ញុំទៅវៃចោល ។ ◆◆◆

# យូ ណាន
## យុទ្ធជន

*(បទសម្ភាសន៍ជាមួយបងប្រុសឈ្មោះ យូ ណៃ អាយុ៦០ឆ្នាំ និង ប្អូនស្រីឈ្មោះ យូ ខេង អាយុ៤២ឆ្នាំ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម)*

ណាន ឈប់រៀនទៅចូលរួមបដិវត្តន៍ខ្មែរក្រហមក្រោយពេលឮសេចក្តីអំពាវនាវឲ្យទៅរំដោះស្តេចនៅឆ្នាំ១៩៧១ ។ ណាន ប្រាប់ពុកម៉ែថាចង់ទៅប្រយុទ្ធតស៊ូរំដោះប្រទេសជាតិ ហើយពុកម៉ែក៏យល់ព្រម ។ នៅភូមិយើងមានតែ ណាន ម្នាក់ទេដែលទៅចូលរួមចលនានេះ ។

ណាន មកលេងផ្ទះបានមួយរយៈខ្លីដែរ គឺប្រហែលនៅឆ្នាំ១៩៧៣-៧៤ ប៉ុន្តែគាត់មិនបាននិយាយអំពីការងារដែលគាត់កំពុងតែធ្វើទេ ។ ណាន យក ខេង ទៅធ្វើការនៅភ្នំពេញជាមួយ ប៉ុន្តែគាត់លាក់មិនឲ្យអ្នកណាដឹងថា ខេង ត្រូវជាប្អូនស្រីរបស់គាត់ទេ ។ ណាន ប្រាប់អង្គការថា ខេង ជាក្មេងកំព្រា ឪពុកម្តាយស្លាប់ចោល



យូ ណាន (ឆ្វេង) ថតនៅស្រុកកំណើតប្រពន្ធ ក្នុងឆ្នាំ១៩៧៥

អស់ ។

ណន មកលេងផ្ទះលើកទី២គឺនៅឆ្នាំ១៩៧៥ ។ គាត់មកលេងតែពេលថ្ងៃប៉ុណ្ណោះ ។ យើងហូបបាយជុំគ្នា តែខ្ញុំមិនបានសួរនាំគាត់អ្វីទេ ព្រោះយើងរវល់តែសប្បាយនឹងការជួបជុំនេះ ។ គាត់គ្រាន់តែនិយាយថាគាត់សុខសប្បាយតែប៉ុណ្ណឹង ។ គាត់បានយកម៉ាស៊ីនថតផ្ទាល់ខ្លួនមកថតរូបខ្លួនឯង ។

ណន មកផ្ទះជាលើកចុងក្រោយនៅឆ្នាំ១៩៧៦ ។ គាត់បើកឡានកុម្ម៉ង់ដេពណ៌ក្រហម ព្រោះគាត់ត្រូវដឹកបន្លែនិងផ្លែឈើយកមកចែកចាយ ។ ប្រពន្ធរបស់គាត់ឈ្មោះ រ៉ាយ ក៏មកជាមួយគាត់ដែរ ។ ខ្ញុំមិនដែលដឹងពីត្រកូលគ្រួសាររបស់ រ៉ាយ ទេ គឺអង្គការជាអ្នករៀបផ្សំផ្គុំអ្នកទាំងពីរ ។ ណន បានរំឭកយើងឲ្យធ្វើតែតាមអង្គការបញ្ជាទៅ កុំរឹងទទឹងប្រឆាំងឲ្យសោះ ។

ខ្ញុំដឹងថា ណន ត្រូវអង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៦ ពេលដែលខ្ញុំព្យាយាមទៅលេងគាត់ ។ ប្រពន្ធគាត់ក៏បាត់ខ្លួនដែរ ។ ប៉ុណ្ណឹងវាច្បាស់ថាគាត់បានស្លាប់ហើយ ។ ◆◆◆

## ឃឿង ប៊ួយស៊័រ
## លេខាអង្គភាពអនុសេនាធំ៥០២

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ឃឿង ហ៊ុចលៀង អាយុ៣៦ឆ្នាំ និងម្តាយឈ្មោះ បាក់ លី អាយុ៧៥ឆ្នាំ នៅស្រុកស្អាង ខេត្តកណ្តាល)*

មុនបដិវត្តន៍ ប៊ួយស៊័រ កាន់តំណែងជាប្រធានភូមិយើង ។ ជម្លោះបានកើតឡើងដោយសារគាត់មិនអនុញ្ញាតឲ្យប្រជាជននៅទីនេះរកស៊ីលក់ពោត និងជាងនេះទៅទៀតមានអ្នកភូមិចោទប្រកាន់ថាគាត់លួចស្រលាញ់កូនស្រីគេ ។ ដោយគាត់មិនចង់នាំកង្វល់ដល់គ្រួសារ គាត់ក៏ទៅចូលរួមជាមួយខ្មែរក្រហម ។ កាលណោះខ្ញុំមិនដឹងថាគាត់កាន់តំណែងអ្វីទេ ។

មានម្តងនោះមុនឆ្នាំ១៩៧៥ គាត់មកលេងផ្ទះជាមួយមិត្តភក្តិគាត់ម្នាក់ ។ គាត់យកម្សៅដេរនិងថ្នាំពេទ្យមក ។ កាលណោះគាត់ស្គមខ្លាំងណាស់ ។ គាត់មិនបាននិយាយអ្វីអំពីការងារគាត់ទេ ខ្ញុំគិតថាប្រហែលជាគាត់មិនចង់ឲ្យយើងដឹងហើយ ។ គាត់បានប្រាប់យើងថាគាត់នឹងមកម្តងទៀតពេលស្រុកបានសន្តិភាព ។ យើងមិនដែលបានដំណឹងអ្វីពីគាត់ចាប់តាំងពីពេលនោះមក ។


ឃឿង ប៊ួយស៊័រ រូបឆ្វេង ថតមុនឆ្នាំ១៩៧៥

មុនពេលខ្មែរក្រហមដួលរលំ មានកងទ័ពមួយចំនួនមកភូមិយើង ហើយបង្ខំឲ្យប្រជាជនធ្វើប្រវត្តិរូប ។ អ្នកដែលនៅផ្ទះមានតែមនុស្សចាស់អាយុ៨០ឆ្នាំប៉ុណ្ណោះ ។ អ្នកទាំងនោះត្រូវខ្មែរក្រហមសួរចម្លើយហើយសម្លាប់ចោល ។ កងទ័ពខ្មែរក្រហមថែមទាំងសួរប្រជាជនមួយចំនួនអំពីរឿងបងប្រុសខ្ញុំ ដូចជាសួរថាគាត់ជនជាតិអ្វី គាត់ជាមនុស្សយ៉ាងម៉េចជាដើម ។

ក្រោយមកយើងឮដំណឹងថាបងប្រុសខ្ញុំត្រូវបញ្ជូនទៅរៀនសូត្រនៅគុកព្រៃស និងបន្ទាប់មកត្រូវចាប់ខ្លួនបញ្ជូនទៅមន្ទីរ ស-២១ ។ ខ្ញុំគិតថាបងប្រុសខ្ញុំស្លាប់ហើយ ព្រោះអ្នកដទៃត្រឡប់មកផ្ទះអស់ហើយបាត់តែគាត់ជាង២០ឆ្នាំកន្លងទៅនេះមិនទាន់ឃើញវិលមកវិញ ។ ឥឡូវយើងមានសន្តិភាពហើយ បើគាត់នៅរស់គាត់ពិតជាមកវិញជាមិនខាន ។ ខ្ញុំមិនដែលឃើញរូបរាងគាត់យ៉ាងម៉េចសោះតាំងពីពេលនោះមក សូម្បីតែយល់សប្តិក៏មិនដែលឃើញដែរ ។

◆◆◆

## សេចក្ដីប្រកាសរកប្អូនប្រុសឈ្មោះ លឹម ឡុង

នាងខ្ញុំឈ្មោះ លឹម សុក អាយុ៥៣ឆ្នាំ រស់នៅភូមិកណ្ដាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង សូមសួររកប្អូនប្រុសឈ្មោះ លឹម ឡុង (កើតឆ្នាំមមី) បានចូលបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧២ ពេលដែលគាត់មានអាយុ១៨ឬ១៩ឆ្នាំ ។ មុនពេលចូលបដិវត្តន៍ ឡុង ជាកងសេនាជនឃុំ ។ រយៈពេល១ខែក្រោយពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះទូទាំងប្រទេស ឡុង បានមកលេងផ្ទះម្ដងក្នុងសម្លៀកបំពាក់កងទ័ព ។ ក្រោយពី ឡុង ត្រឡប់ទៅវិញក៏បាត់ដំណឹងរហូតមកដល់បច្ចុប្បន្ននេះ ។

បើបងប្អូនបានស្គាល់ឈ្មោះ លឹម ឡុង ឬសាមីខ្លួនបានឃើញសេចក្ដីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈឈ្មោះ នុយ ដានី ទូរស័ព្ទលេខ ០១២ ១៨០ ២៦ ៥២ ឬផ្ដល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ទូរសារលេខ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។

## សេចក្ដីប្រកាសរកកូនប្រុសឈ្មោះ ស្រ៊ុន ម៉ាប់

នាងខ្ញុំឈ្មោះ មុំ ណន អាយុ៧៣ឆ្នាំ រស់នៅភូមិកណ្ដាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ប្ដីឈ្មោះ នុយ ស្រ៊ុន (ស្លាប់ឆ្នាំ១៩៨២) សូមសួររកកូនប្រុសឈ្មោះ ស្រ៊ុន ម៉ាប់ ដែលបានចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៣ ។ ប្រហែលក្នុងខែ៦ ឬ៧ ឆ្នាំ១៩៧៦ ម៉ាប់ បានមកលេងផ្ទះម្ដងបន្ទាប់ពីគាត់ត្រូវរបួសសម្រាកពេទ្យព-២ អស់រយៈពេលជាច្រើនខែ ។ បន្ទាប់ពីពេលនោះមក សាច់ញាតិម្នាក់ឈ្មោះ ឃុត ឃួន ដែលបានទៅបម្រើបដិវត្តន៍ជាមួយ ម៉ាប់ ដែរ បានប្រាប់ខ្ញុំថា ម៉ាប់ ត្រូវអង្គការដាក់គុកនៅភ្នំជីនៅឆ្នាំ១៩៧៨ បន្ទាប់មកបញ្ជូនទៅភ្នំដងរែក ។ រហូតមកដល់បច្ចុប្បន្ននេះ ខ្ញុំមិនបានទទួលដំណឹងអ្វីអំពី ម៉ាប់ ទៀតទេ ។

បើប្អូនស្គាល់ឈ្មោះ ស្រ៊ុន ម៉ាប់ ឬសាមីខ្លួនបានឃើញសេចក្ដីប្រកាសនេះ សូមមេត្តាផ្ដល់ដំណឹងមកខ្ញុំតាមរយៈឈ្មោះ នុយ ដានី តាមលេខទូរស័ព្ទ ០១២ ១៨០ ២៦ ៥២ ។ សូមអរគុណ ។

## សេចក្ដីប្រកាសរកបងប្រុសឈ្មោះ ច្រឹង សឿ និងបងស្រីឈ្មោះ ច្រឹង សួ

នាងខ្ញុំឈ្មោះ ខែក អ៊ិន អាយុ៤៨ឆ្នាំ មានបងប្អូន៦នាក់ ប្រុស៣នាក់ ស្រី៣នាក់ ។ ឪពុកឈ្មោះ ខែក ហួន ស្លាប់ឆ្នាំ២០០៣ ម្ដាយឈ្មោះ មាស សុំ ស្លាប់កាលពី៦ឆ្នាំមុន ។ នាងខ្ញុំសូមសួររកបងប្រុសឈ្មោះ ច្រឹង សឿ និងបងស្រីឈ្មោះ ច្រឹង សួ ដែលបាត់ខ្លួនតាំងពីរបបខ្មែរក្រហម ។

កាលពីចុងឆ្នាំ១៩៧៨ បងប្រុស សឿន បានផ្ញើសំបុត្រមួយមកសួរសុខទុក្ខគ្រួសារ ដោយប្រាប់ថាគាត់កាន់ខាងកងពលនៅមេមត់ ។ ចំណែកបងស្រី សួ មានអ្នកស្គាល់គ្នាជួបនៅឆ្នាំ១៩៧៩ពេលកំពុងរត់ឡើងភ្នំនៅខេត្តមណ្ឌលគិរី ។ តាំងពីពេលនោះមក នាងខ្ញុំបាត់ដំណឹងពីបងទាំងពីររហូតមកដល់សព្វថ្ងៃនេះ ។

ប្រសិនបើបងទាំងពីរបានឃើញសេចក្ដីប្រកាសនេះ ឬញាតិមិត្តបានស្គាល់ឬបានឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្ដល់ព័ត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល